ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ នៅលើផ្លូវដ៏វែងអន្លាយឆ្ពោះទៅរកការពិតនិងយុត្តិធម៌

*រូបថតដោយ ផាត ពិសិដ្ឋ*

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៧៤ ខែកុម្ភៈ ឆ្នាំ២០០៦

# ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ សំបុត្រ ៖ នៅលើផ្លូវដ៏វែងឆ្ងាយឆ្ពោះទៅរកការពិតនិងយុត្តិធម៌........១

**ផ្នែកឯកសារ**

◆ អុង បែល ៖ និស្សិតច្បាប់អន្តរជាតិមកពីប្រទេសបារាំង........................៣

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១........................៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ រឿងរ៉ាវដែលមិនចេះសាបសូន្យ...................................................១០

**ផ្នែកច្បាប់**

◆ សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ..............២៨

**វេទិកាពិភាក្សាសាធារណៈ**

◆ យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា .................៣៤

◆ ការកំណត់និយមន័យថ្មីនៃអំពើប្រល័យពូជសាសន៍.........................៤២

◆ សេចក្ដីប្រកាសរួមស្ដីអំពីការបើកឲ្យដំណើរការ............................៥៥

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ កាត់ទោសឲ្យសមនឹងកំហុស ...................................................៥៦



បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជនរងគ្រោះក្រោមរបបខ្មែរក្រហម
នៅវាលពិឃាតបឹងជើងឯក

**មាជ រ៉ើម អាយុ៦៥ឆ្នាំ**
**មានការថប់អារម្មណ៍នៅពេលឃើញរូបថតកូននៅក្នុងសារមន្ទីរទួលស្លែង**



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ** ៖ ប៊ុនធី ពីរ៉ែន, ស៊ិរិ សាវីណា, អេង កុកថាយ, វ៉ាន់ថាន់ ពៅដារ៉ា, អៀ ម៉េងទ្រី, សោម វណ្ណៈ **អ្នកនិពន្ធនិងស្រាវជ្រាវ** ៖ លី សុផល, ណយ សុផារី **អ្នកបកប្រែ** ៖ បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយករង** ៖ សាន់ កល្យាណ **និពន្ធនាយកទូទៅ** ៖ ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ** ៖ គីម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ** ៖ រ័ត្ន គារាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# នៅលើដងផ្លូវដ៏វែងអន្លាយឆ្ពោះទៅរកការពិតនិងយុត្តិធម៌

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនកម្ពុជាទាំងអស់បានធ្វើដំណើរថ្មើរជើងដោយឥតឈប់ឈរចេញពីទីក្រុងទៅកាន់ទីជនបទ ពីភូមិឋានទៅកាន់បណ្តាខេត្តឆ្ងាយៗ និងពីវាលស្រែរបស់ខ្លួនទៅកាន់សមរភូមិនានា ។ នៅក្នុងឆ្នាំ១៩៧៩ អ្នករួចរស់ជីវិតពីរបបប្រល័យពូជសាសន៍បានធ្វើដំណើរដោយថ្មើរជើងម្តងទៀត ប៉ុន្តែពេលនេះគឺដើរត្រឡប់មកផ្ទះសម្បែងរបស់ខ្លួនវិញ ។

នៅក្នុងឆ្នាំ១៩៩៧ ប្រទេសកម្ពុជាបានចាប់ផ្តើមការធ្វើដំណើរម្តងទៀត ប៉ុន្តែការធ្វើដំណើរពេលនេះគឺស្វែងរកការពិតនិងយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មទាំងឡាយដែលប្រព្រឹត្តឡើងដោយមេដឹកនាំជាន់ខ្ពស់ដែលទទួលខុសត្រូវចំពោះការបង្កឲ្យមានភាពឈឺចាប់មកលើប្រជាជនកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រហូតមកដល់ថ្ងៃនេះគឺមានរយៈពេល២៧ឆ្នាំហើយបន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ។ យើងកំពុងតែបោះជំហានដ៏ធំមួយនៅលើផ្លូវដ៏វែងអន្លាយឆ្ពោះទៅរកការពិតនិងយុត្តិធម៌ ។

នៅថ្ងៃទី៦ ខែកុម្ភៈ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលប្រជាជនភាគច្រើនហៅអង្គជំនុំជម្រះក្តីនេះថា "**តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម**" បានចាប់ផ្តើមរៀបចំការិយាល័យរបស់ខ្លួនជាផ្លូវការនៅឯបន្ទាយកងយោធពលខេមរភូមិន្ទដែលស្ថិត នៅជាយក្រុងភ្នំពេញ ។ សម្រាប់ឆ្នាំនេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះនឹងជ្រើសរើសបុគ្គលិក ហើយនិងចាប់ផ្តើមការស៊ើបអង្កេតប្រមូលភ័ស្តុតាងសម្រាប់សវនាការជំនុំជម្រះក្តី ។ រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសង្ឃឹមថា ចៅក្រម ព្រះរាជអាជ្ញា និងមេធាវីសម្រាប់អង្គជំនុំជម្រះវិសាមញ្ញនេះ ត្រូវបានតែងតាំងនៅក្នុងរយៈពេល៦ខែខាងមុខទៀត ។ ប្រសិនបើអ្វីៗទាំងអស់ប្រព្រឹត្តទៅបានល្អ សវនាការដំបូងគួរតែត្រូវចាប់ផ្តើមនៅដើមឆ្នាំ២០០៧ ។

កម្ពុជា អង្គការសហប្រជាជាតិ និងប្រទេសជាច្រើនទៀតបានជួយប្រជាជនកម្ពុជាស្វែងរកការពិតនិងយុត្តិធម៌ដោយបានបំពេញការងារនេះអស់រយៈពេលជាច្រើនឆ្នាំមកហើយ ។ ថវិកាចំនួន៥៦លានដុល្លារសហរដ្ឋអាមេរិកដែលភាគច្រើនត្រូវចំណាយលើដំណើរការនេះ អង្គការសហប្រជាជាតិបានប្រមែប្រមូលពីប្រទេសជប៉ុន បារាំង អាល្លឺម៉ង់ ចក្រភពអង់គ្លេស អូស្ត្រាលី ហូល្លង់ កាណាដា គណៈកម្មាធិការអឺរ៉ុប ន័រវេ៉ អូទ្រីស ដាណឺម៉ាក ប៊ែលហ្ស៊ិក អៀរឡង់ ស្វីស សាធារណរដ្ឋកូរ៉េ លុចសំបួរ ថៃ អារម៉េនី ស៊ុយអែត និងណាមីប៊ី ។ សហរដ្ឋអាមេរិកបានសន្យានឹងរួមវិភាគទានថវិកាចំណាយក្នុងដំណើរការនេះដែរប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្លើយតបទៅនឹងបទដ្ឋានយុត្តិធម៌ដែលទទួលស្គាល់ដោយអន្តរជាតិនៅក្នុងឆ្នាំដំបូងរបស់ខ្លួន ។ ចាប់តាំងពីឆ្នាំ១៩៩៥មកម៉្លេះ សហរដ្ឋអាមេរិកបានផ្តល់ថវិការាប់លានដុល្លាររួចហើយសម្រាប់ការប្រមូលឯកសារនិងការស្រាវជ្រាវប្រវត្តិសាស្ត្រហើយនិងផ្តល់ព័ត៌មានសាធារណៈស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យ ។

អង្គការក្រៅរដ្ឋាភិបាលអង្គការសិទ្ធិមនុស្សជាតិនិងអន្តរជាតិនៅកម្ពុជាជាច្រើនក៏កំពុងតែគាំទ្រដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនេះដែរ ។ អង្គការទាំងនេះនឹងជួយផ្តល់ជាឯកសារដែលអាចប្រើប្រាស់ជាភ័ស្តុតាងបាននៅពេលជំនុំជម្រះ ជួយពិនិត្យមើលសកម្មភាពរបស់រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនិងជួយផ្តល់ប្រឹក្សាដល់អ្នកដែលទទួលរងនូវការឈឺចាប់ក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

មធ្យោបាយសំខាន់បំផុតដែលអង្គការក្រៅរដ្ឋាភិបាលអាចជួយបានប្រហែលជាត្រូវសហការជាមួយនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជាមួយអង្គការក្រៅរដ្ឋាភិបាលដូចគ្នា ដើម្បីធានាថា សាធារណជនបានទទួលព័ត៌មាននិងបានចូលរួមសវនាការកាត់ក្តីនេះ ។ សវនាការទាំងនេះគឺដើម្បីស្វែងរកការពិត និងយុត្តិធម៌ជូនជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការទាំងនេះគឺជាសវនាការរបស់ប្រជាជនកម្ពុជាគ្រប់រូប ប្រសិនបើគ្មាន

ការចូលរួមពីសំណាក់ប្រជាជនកម្ពុជាទេនោះ កម្ពុជានឹងមិនអាចវិនិច្ឆ័យបានថា តើសវនាការនេះមានភាព យុត្តិធម៌ គុណភាព និងតម្លាភាពជាសាធារណៈ ។

តើប្រជាជនកម្ពុជាអាចចូលរួមក្នុងសវនាការជំនុំជម្រះក្តីនេះតាមរបៀបណា? ប្រជាជនកម្ពុជាភាគច្រើនរស់នៅទីជនបទដាច់ស្រយាលឆ្ងាយៗ ហើយការធ្វើដំណើរមកកាន់ទីក្រុងភ្នំពេញត្រូវចំណាយលុយកាក់ច្រើនគួរសមដែរ ។ អង្គការក្រៅរដ្ឋាភិបាលជាច្រើននៅកម្ពុជាកំពុងតែបំពេញការងារដើម្បីធានាថាប្រជាជនកម្ពុជាអាចទទួលព័ត៌មានអំពីសវនាការនេះតាមរយៈការអានទស្សនាវដ្តីនិងអត្ថបទសរសេរនានាដែលត្រូវបានចែកចាយទៅតាមសាលាឃុំនិងសាលាស្រុកទូទាំងប្រទេសកម្ពុជា ។ អង្គការខ្លះទៀតនឹងផ្សព្វផ្សាយព័ត៌មានទាំងនេះតាមវិទ្យុ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងស្នើសុំសហការជាមួយស្ថានីយទូរទស្សន៍ជាតិកម្ពុជានិងស្ថានីយទូរទស្សន៍ផ្សេងៗទៀតក្នុងការផលិតកម្មវិធីដែលអាចនឹងជួយអប់រំប្រជាជនកម្ពុជាឲ្យបានយល់ដឹងអំពីដំណើរការអង្គជំនុំជម្រះនេះ ។

ទន្ទឹមគ្នានោះដែរ គម្រោងមួយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្តើមនៅក្នុងខែកុម្ភៈនេះ ដើម្បីជួយនាំប្រជាជនកម្ពុជាជាច្រើនពាន់នាក់ ទៅទស្សនាទីតាំងអគារសម្រាប់អង្គជំនុំជម្រះ ។ នៅក្នុងដំណាក់កាលដំបូងនៃគម្រោងនេះ យើងនឹងអញ្ជើញអ្នកភូមិចំនួន៣០០ទៅ៤០០នាក់ជារៀងរាល់ខែទៅទស្សនាទីតាំងអគារសម្រាប់អង្គជំនុំជម្រះ និងជួបបុគ្គលិកដែលបំពេញការងារនៅទីនោះ ។

អ្នកស្រុកអ្នកភូមិដែលយើងអញ្ជើញមកទស្សនាទីតាំងអគារនេះគឺប្រជាជនដែលយើងបានស្គាល់រួចហើយនៅក្នុងគម្រោងទាំងឡាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាពិសេសគម្រោង"ជួយជនរងគ្រោះដោយអំពើករុណាកម្ម" ដែលផ្តល់សេវាប្រឹក្សានិងសេវាព្យាបាលដល់អ្នកដែលដែលប៉ះពាល់ផ្លូវចិត្តធ្ងន់ធ្ងរនៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ហើយសព្វថ្ងៃនេះអ្នកទាំងនេះនៅតែប្រឈមមុខនឹងការប៉ះពាល់ផ្នែកស្មារតីនេះនៅឡើយ ។ អ្នកដែលនឹងមកកាន់ទីក្រុងភ្នំពេញគឺមានទាំងជនរងគ្រោះ និងកម្មាភិបាលខ្មែរក្រហមថ្នាក់ទាប ។ អ្នកផ្សេងទៀតដែលនឹងទៅទស្សនាទីតាំងអគារសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមមានសិស្សនិស្សិតដែលជាកូនចៅរបស់ជនរងគ្រោះ ដូនជី ព្រមទាំងទូននិងហាកិមមកពីសហគមន៍ចាមឥស្លាម ។

អ្នកភូមិទាំងនេះនឹងស្នាក់នៅក្នុងទីក្រុងភ្នំពេញរយៈពេលពីរថ្ងៃ ។ អ្នកភូមិនេះក៏នឹងមានឱកាសជួបជាមួយនឹងអ្នកច្បាប់និងមន្ត្រីតុលាការកម្ពុជា ក្នុងខណៈពេលដែលគាត់កំពុងស្នាក់នៅទីក្រុងភ្នំពេញ ។

ផ្នែកមួយនៃគម្រោងនេះនឹងជួយឲ្យអ្នកស្រុកអ្នកភូមិបានយល់ដឹងអំពីដំណើរការ និងនីតិវិធីរបស់សវនាការជំនុំជម្រះក្តីព្រមទាំងឲ្យគាត់ទាំងអស់ស៊ាំនឹងដំណើរការសវនាការជំនុំជម្រះក្តីនេះថែមទៀត ។ ជាជំហានបន្ទាប់ យើងនឹងនាំអ្នកភូមិទាំងនេះនិងអ្នកភូមិដទៃទៀតនៅទូទាំងប្រទេសកម្ពុជា ឲ្យចូលរួមស្តាប់សវនាការជំនុំជម្រះក្តីនេះរយៈពេលមួយសប្តាហ៍ ។

បន្ទាប់មកទៀត អ្នកភូមិទាំងនេះនឹងវិលត្រឡប់ទៅភូមិរបស់ខ្លួនវិញ និងចែករំលែកនូវអ្វីដែលគាត់បានឃើញនិងបានដឹងទៅឲ្យអ្នកជិតខាងរបស់គាត់ ។ យើងក៏មានគម្រោងចុះថតសកម្មភាពនៃការពិភាក្សារបស់គាត់ធ្វើជាឯកសារនិងធ្វើការចាក់ផ្សាយតាមវិទ្យុដើម្បីជាឱកាសសម្រាប់ប្រជាជនកម្ពុជាទាំងអស់ដឹងពីដំណើរការរបស់សវនាការនេះមកពីប្រជាជនដូចគ្នា គឺមិនមែនដឹងព្រមកពីមន្ត្រីតុលាការតែប៉ុណ្ណោះទេ ។

យើងទាំងអស់គ្នាចង់ឃើញសវនាការជំនុំជម្រះក្តីមានភាពយុត្តិធម៌ត្រឹមត្រូវសម្រាប់ប្រជាជនកម្ពុជាដែលខិតខំចូលរួមក្នុងសវនាការនេះដោយគ្មានការភ័យខ្លាចនឹងការបំភិតបំភ័យឬភាពមិនច្បាស់លាស់អ្វីណាមួយឡើយ ។ ការដឹងឮអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះតាមរយៈការសរសេរ ការស្តាប់វិទ្យុនិងទូរទស្សន៍ និងតាមរយៈសមាជិកក្រុមគ្រួសារ មិត្តភ័ក្តិនិងអ្នកជិតខាងរបស់ខ្លួននឹងជួយឲ្យប្រជាជន កម្ពុជាគ្រប់រូបយល់ដឹងកាន់តែច្បាស់ថាការពិតនិងយុត្តិធម៌គឺពិតជាមាននៅក្នុងប្រទេសកម្ពុជា ហើយជួយកសាងអនាគតត្រឹមត្រូវបានច្រើនជាងមុនសម្រាប់កូនចៅរបស់យើងគ្រប់ៗគ្នា ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# អ៊ុង បែល
# និស្សិតច្បាប់អន្តរជាតិមកពីប្រទេសបារាំង

អុង បែល ជាខ្មែរកម្ពុជាក្រោមដែលទទួលការសិក្សានៅភ្នំពេញ និងបន្តការសិក្សាដល់ប្រទេសបារាំងផ្នែកច្បាប់អន្តរជាតិ ។

បែល កើតថ្ងៃទី៣ ខែ១ ឆ្នាំ១៩៤២ នៅឃុំញាំឡាំង ខេត្តឃ្លាំង កម្ពុជាក្រោម មានឪពុកឈ្មោះ អុង សេន និងម្តាយឈ្មោះ ឡាំ ធីបូ ។ ក្នុងអាយុ១៨ឆ្នាំ បែល បានចាកចេញពីឪពុកម្តាយដើម្បីបន្តការរៀនសូត្រថ្នាក់មធ្យមសិក្សានៅវិទ្យាល័យដាង ថាញ់យ៉ាង ក្នុងខេត្តព្រែកឫស្សី កម្ពុជាក្រោម ។ នៅពេលប្រឡងជាប់ថ្នាក់មធ្យមសិក្សា បែល បានមកបន្តការសិក្សានៅទីក្រុងភ្នំពេញ ។ នៅក្នុងពេលធ្វើដំណើរមកភ្នំពេញ បែល និងអ្នកនាំផ្លូវត្រូវវៀតណាមចាប់យកទៅឃុំឃាំងអស់រយៈពេល៤០ថ្ងៃ នៅខេត្តក្រមួនស (កម្ពុជាក្រោម) ពីបទលួចឆ្លងដែន ។ រួចពីការឃុំឃាំង បែល បានផ្លាស់មកសិក្សានៅវិទ្យាល័យអូឡាក់ នៅព្រៃនគរវិញនាចុងឆ្នាំ១៩៥៨ ។

**ទំនាក់ទំនងជាមួយខ្មែរសេរី**

នៅព្រៃនគរ បែល ស្នាក់នៅវត្តចន្ទរង្សី ។ វត្តចន្ទរង្សីគឺជាជម្រករបស់ចលនាខ្មែរសេរី ។ កុដិមួយដែលកន្លែងជួបជុំគ្នារបស់ខ្មែរសេរីស្ថិតនៅក្រោមការគ្រប់គ្រងរបស់សង្ឃ ថាច់ ឌី និងក្រោមការទទួលខុសត្រូវធំរបស់អាចារ្យខេមរិន ។ ថាច់ ឌី បានស្វាគមន៍ និងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ បែល ដើម្បីអូសទាញ បែល ឲ្យចូលចលនាខ្មែរសេរី ។ ថាច់ ឌី បាន ប្រាប់ បែល ពីប្រវត្តិ និងគោលដៅរបស់ចលនាខ្មែរសេរី ។

ពាក់កណ្តាលឆ្នាំ១៩៥៩ បែល បានចូលចលនាខ្មែរសេរីតាមការណែនាំរបស់ ថាច់ ឌី ។ បែល មាននាទីជាអ្នកឃោសនាបំផុសឲ្យយុវជនស្អប់កុម្មុយនិស្ត និងស្រលាញ់លោកសេរី ។

នៅឆ្នាំ១៩៦០ បែល បានមកភ្នំពេញដើម្បីបន្តការសិក្សានៅវិទ្យាល័យស៊ីសុវត្ថិ ។ បែល ស្នាក់នៅវត្តមហាមន្ត្រី និងធ្វើការទាក់ទងជាមួយមេកុដិឈ្មោះថាច់ ហួយ ដែលជាប្អូនប្រុសរបស់ថាច់ ឌី ។ ថាច់ ឌី បានឲ្យ បែល ទាក់ទងឈ្មោះមនុស្សមួយចំនួននៅភ្នំពេញមានដូចជា នាជ រិន, ថាច់ ហួយ, ថាច់ ហេន, និងថាច់សាំង ដើម្បីបន្តសកម្មភាពនៅកម្ពុជា និងក្តាប់អំពីស្ថានភាពនយោបាយនៅស្រុកខ្មែរនិងតាមដានចលនាយុវជនដើម្បីរាយការណ៍ទៅ ថាច់ ឌី ។ ក្នុងរយៈពេលពីរឬបីអាទិត្យម្តង បែល និងអ្នក៦ទៀតតែងទៅជួបជុំគ្នានៅកុដិរបស់ ថាច់ ហួយ ដើម្បីពិភាក្សាវែកញែកពីកិច្ចការដែលត្រូវធ្វើ និងធ្វើជាសេចក្តីសន្និដ្ឋានសម្រាប់ផ្ញើទៅ ថាច់ ឌី ។ បែល បានទាក់ទងនិងអប់រំយុវជនខ្មែរឲ្យយល់ពីគោលបំណងរបស់ចលនាខ្មែរសេរីនៅកម្ពុជា ។

នៅចន្លោះឆ្នាំ១៩៦១-១៩៦៣ ការផ្សព្វផ្សាយពីចលនាខ្មែរសេរីដំបូងមានដំណើរការល្អប្រសើរ ។ ប៉ុន្តែដោយទ័ពវៀតណាមខាងត្បូងបានចូលលុកលុយប្រទេសកម្ពុជាដោយមានទាំងទ័ពខ្មែរសេរីផង បានធ្វើឲ្យមជ្ឈដ្ឋានយុវជនចាត់ទុកចលនាខ្មែរសេរីថា ជាចលនាក្បត់ជាតិ ។ ដោយស្ថានភាពលំបាកខ្លាំង បែល ក៏ធ្វើសកម្មភាពជាសម្ងាត់តែនៅក្នុងវិទ្យាល័យស៊ីសុវត្ថិប៉ុណ្ណោះ ។ បែល រួមនិងសិស្សដូចគ្នាមាន អឿ ឈួន, សេង ដុន, ពាង ធុនហាក់ និង សុខ មីសែល បានបង្កើត "ចលនាយុវជនចម្រើន" នៅវិទ្យាល័យស៊ីសុវត្ថិក្នុងបំណងប្រមែប្រមូលយុវជនឲ្យចេះរៀបចំជាក្រុមដើម្បីរំដោះកម្ពុជាចេញពីរបបសក្តិភូមិនិងប្រឆាំងនឹងចលនាបដិវត្តន៍កម្ពុជានិងលទ្ធិកុម្មុយនិស្ត ។

ពាក់កណ្តាលឆ្នាំ១៩៦៤ បែល បានប្រឡងធ្លាក់មធ្យមសិក្សាប័ត្រភាគ២ ។ បែល និងមិត្តភក្តិ ត្រូវបានបណ្តេញចេញពីសាលាព្រោះបង្កឲ្យមានភាពជ្រួលច្របល់នៅក្នុងសាលា ។

**ទំនាក់ទំនងជាមួយសេ.អ៊ី.អា**

នៅឆ្នាំ១៩៦៥ បែល បានដាច់ការទាក់ទងពីខ្សែខ្មែរសេរី ។ ក្រោយពេលចេញពីសាលា បែល ដើរបង្រៀនសិស្សតាមផ្ទះលួចលាក់ដើម្បីរកប្រាក់ចិញ្ចឹមខ្លួនឯង ព្រោះឪពុកម្តាយលែងផ្ញើ

ប្រាក់មកទៀតហើយ ។ បន្ទាប់មក បែល ធ្វើជាកម្មករនៅស្ពាតអូឡាំពិក និងធ្វើជាកម្មករផ្ទះថ្ម ។ រហូតដល់ឆ្នាំ១៩៦៧ បែល បានទៅធ្វើជាកម្មករចម្ការកៅស៊ូរដ្ឋនៅឡាបានសៀកក្នុងខេត្តរតនគិរី ។ នៅបានពីរខែ បែល ក៏ត្រឡប់មកវិញ ហើយខំប្រឹងរៀនដោយខ្លួនឯង នៅភ្នំពេញនៅផ្ទះរបស់ ឡាំ ខែល រហូតប្រឡងជាប់មធ្យមសិក្សាប័ត្រភាគ២នៅឆ្នាំ១៩៦៨ ។ នៅគ្រប់កន្លែងធ្វើការ បែល តែងឆ្លៀតពន្យល់ដល់អ្នកធ្វើការជាមួយឲ្យយកចិត្តទុកដាក់អំពីការជិះជាន់នៅក្នុងសង្គមនិងឲ្យយល់ស្របតាមចលនាខ្មែរសេរី ។

ដើមឆ្នាំ១៩៧០ បែល រៀននៅមហាវិទ្យាល័យច្បាប់ ។ ដោយសារមមាញឹកក្នុងការសិក្សា បែល មិនបានធ្វើសកម្មភាពអ្វីទេ ក្រៅពីស្តាប់សុន្ទរកថានយោបាយនៅក្នុងមហាវិទ្យាល័យច្បាប់ និងចងមិត្តភាពជាមួយនិស្សិតច្បាប់មួយចំនួនទៀតដូចជា សន ផាត ជាប្រធានសមាគមនិស្សិត, ធួ ថុន, កុយ ប៊ុច, ខូវ ម៉េងហ៊ាន, ប៊ុន សយ, ហ៊ី សុធារី, និងឡុង ឆឹន ។

ក្នុងពេលសិក្សា បែល ចាប់ផ្តើមមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ ឌុក រ៉ាស៊ី ជាសាស្ត្រាចារ្យនីតិរដ្ឋបាល ។ បែល តែងសុំយោបល់ពី ឌុក រ៉ាស៊ី ចំពោះមេរៀនណាទាក់ទងនឹងនយោបាយក្នុងនិងក្រៅប្រទេស និងរបបសង្គមនិយម និងសេរីនិយមនៅលើពិភពលោក ។ លុះក្រោយមកទំនាក់ទំនងនេះបានក្លាយទៅជាការពិភាក្សារឿងនយោបាយក្នុងប្រទេសនិងការតាមដានចលនានិស្សិតនៅតាមសាលាវិញ ។ ឌុក រ៉ាស៊ី បានណែនាំ បែល ឲ្យក្តាប់សភាពការណ៍ក្នុងចលនាយុវជននៅក្នុងសាលា និងធ្វើការសហការប្តូរយោបល់ជាមួយ សន ផាត ។

បែល បានជួយជ្រោមជ្រែងនិងផ្តល់គំនិតដល់ សន ផាត ក្នុងការរៀបចំចេញជាព្រឹត្តិបត្រប្រចាំសមាគមនិស្សិតសាលាច្បាប់មានឈ្មោះថា "នីតិ-សេដ្ឋសាស្ត្រ" ចេញផ្សាយជារៀងរាល់អាទិត្យ ។ ព្រឹត្តបត្រនេះបានទិតៀនចំពោះរដ្ឋាភិបាលសិរិមតៈ និងនិយាយប្រឆាំងនឹងបដិវត្តន៍កម្ពុជាថា នៅក្រោមយៀកកុង និងវៀតណាមខាងជើង ។

នៅដើមឆ្នាំ១៩៧០ បែល និង សន ផាត បានបំផុសនិស្សិតឲ្យធ្វើបាតុកម្មនៅក្រុងភ្នំពេញ ដើម្បីគាំទ្រក្បួនបាតុកម្មបណ្តេញពួកយៀកកុងដែលមកបោះទីតាំងនៅខេត្តស្វាយរៀងតាមគម្រោងការរបស់ ឌុក រ៉ាស៊ី ។ នៅថ្ងៃទី១៣ ខែ៣ ឆ្នាំ១៩៧០ បាតុកម្មក៏កើតមានឡើងនៅគ្រប់ទិសទី រហូតដល់មានបាតុកម្មដុតស្ថានទូតយៀកកុង និងវៀតណាមខាងជើងឲ្យខូចខាតយ៉ាងដំណំ ។ ក្រោយមក នៅថ្ងៃទី១៦ ខែ៣ ឆ្នាំ១៩៧០ បែល និង សន ផាត បានដឹកនាំនិស្សិតសាលាច្បាប់ធ្វើបាតុកម្មព័ទ្ធមន្ទីររដ្ឋសភា បង្ខំឲ្យតំណាងរាស្ត្រទាំងនោះសម្រេចចេញជាសេចក្តីថ្លែងការណ៍ជាផ្លូវការគាំទ្រដល់បាតុកម្មដែលធ្វើឡើងប្រឆាំងនឹងទ័ពយៀកកុងដែលស្ថិតនៅក្នុងទឹកដីខ្មែរ ។

ថ្ងៃទី១៨ខែ៣ឆ្នាំ១៩៧០ រដ្ឋប្រហាររបស់ លន់ នល់ ទម្លាក់សម្តេចសីហនុ បានប្រកាសឡើង ។ កងទ័ពខ្មែរសេរីដែលបានប្រែក្លាយទៅជាកងម៉ាយហ្គុក ត្រូវបានបញ្ជូនមកភ្នំពេញទាំងកង ៗ ។ បែល ក៏បានចូលរួមធ្វើសកម្មភាពគាំទ្រ និងចូលរួមធ្វើបាតុកម្មដែលដឹកនាំដោយសន ផាត ដែរ ។ បែល បានទៅជួប ថាច់ ហួយ ដើម្បីស៊ើបពីដំណឹងថាច់ ឌី ។ ជាចៃដន្យ បែល បានជួបថាច់ ឌី នៅតាមផ្លូវ តែពេលនេះ ថាច់ ឌី បាន ឡើងស័ក្តិ៣ ហើយ ។ បែល បានសួរនាំពីសភាពការណ៍ និងសួរពីកិច្ចការត្រូវបំពេញតទៅទៀត ប៉ុន្តែ ថាច់ ឌី និយាយក្នុងន័យលែងទុកចិត្ត និងសន្យាថាចាំជួបគ្នានៅថ្ងៃក្រោយ ។

ក្រោយមកចលាចលតែងកើតឡើងមិនដាច់នៅមហាវិទ្យាល័យច្បាប់ និងមហាវិទ្យាល័យអក្សរសាស្ត្រ ។ បែល ក៏បានឆ្លៀតចូលទៅក្នុងចលនាទាំងអស់នោះ ក្នុងបំណងអូសទាញឲ្យចលនាទាំងនោះដើរស្របតាមផែនការចលនាខ្មែរសេរី ពោលគឺធ្វើឲ្យអំណាចធ្លាក់មកក្នុងដៃ សឺង ង៉ុកថាញ់វិញ ។

នៅឆ្នាំ១៩៧០ បែល បានរៀបការជាមួយ ចៅ ច័ន្ទសារី ដែលធ្វើពេទ្យនៅក្នុងកងពលថ្មើរជើងលេខ៧ ។ បែល និងប្រពន្ធគាត់មានកូនពីរនាក់ ប្រុសអាយុ៥ឆ្នាំ និងស្រីអាយុ៤ឆ្នាំ ។

បែល ឈប់ធ្វើកុម្ម៉ង់ដូដែលគាត់បានធ្វើតាំងពីរដ្ឋប្រហារ ហើយបានចូលធ្វើទាហាននៅកងពលថ្មើរជើងលេខ៧វិញ ដើម្បីជាខែលការពារមិនឲ្យ ថាច់ ឌី ធ្វើបាប ។ បែល ចូលមកធ្វើការជាមួយ អ៊ុន កូវ ព្រោះ បែល យល់ឃើញថាកម្លាំងទាហានរបស់ អ៊ុន កូវ អាចទប់ទល់នឹងថាច់ ឌី បាន ។ អ៊ុន កូវ បានពាក់ស័ក្តិ

ពលបាលទោឲ្យ ប៉ែល ។ នៅក្នុងជួរទាហាននេះ ប៉ែល មិនមានការងារអ្វីច្បាស់លាស់ទេ ព្រោះជាប់រវល់រៀននៅសាលាច្បាប់ ហើយនេះជាឱកាសមួយដែល ប៉ែល អាចទាក់ទងជាមួយចលនាយុវជននៅមហាវិទ្យាល័យច្បាប់បានច្រើនជាងមុន ។

ពាក់កណ្តាលឆ្នាំ១៩៧០ សឺង នី ពាក់ស័ក្តិ៣ និង តុង ទិន ពាក់ស័ក្តិ៤ បានបង្កើតទំនាក់ទំនងជាមួយ ប៉ែល ឡើងវិញបន្ទាប់ពីមិនបានទាក់ទងគ្នាយ៉ាងយូរតាំងពី ប៉ែល នៅស្នាក់នៅវត្តចន្ទរង្សី ។ អ្នកទាំងពីរតែងតែអប់រំ ប៉ែល ឲ្យស្អប់កុម្មុយនិស្តនិងស្រលាញ់របបសេរី ព្រមទាំងបានពន្យល់ណែនាំពីលក្ខន្តិកៈរបស់ សេ.អ៊ី.អា ជាញឹកញាប់ផង ។ ដល់ចុងឆ្នាំ១៩៧០ ប៉ែល ត្រូវបានបញ្ចូលក្នុងខ្សែសេ.អ៊ី.អា និងមានតួនាទីដើរឃោសនាពង្រីកកម្លាំងសេ.អ៊ី.អា ក្នុងជួរនិស្សិតនៅមហាវិទ្យាល័យច្បាប់ ។ ប៉ែល បង្កប់ខ្លួនក្នុងចលនាយុវជន ទាក់ទងជាមួយនិស្សិតគ្រប់មជ្ឈដ្ឋានដើម្បីធ្វើការវិភាគគ្រប់កម្លាំងក្នុងបំណងទាញយកសេចក្តីសម្រេចចិត្តសម្រាប់ធ្វើជាមូលដ្ឋានក្នុងការប្រឆាំងនឹងកុម្មុយនិស្តជាទូទៅពិសេសចលនាបដិវត្តន៍នៅកម្ពុជា ។

នៅឆ្នាំ១៩៧២ ប៉ែល បានទាក់ទងជាមួយ វិញ អាន ចាងហ្វាងរោងពុម្ពរស្មីកម្ពុជានៅផ្លូវមុនីវង្ស ។ នៅចុងខែ៥ វិញ អាន បានណែនាំ ប៉ែល អំពីការតស៊ូរបស់ចលនាបដិវត្តន៍ឥណ្ឌូចិន និងបានបបួល ប៉ែល ទៅមើលតំបន់រំដោះ ដោយអនុញ្ញាតឲ្យប៉ែលនាំទាំងមិត្តភក្តិទៅផង ។ ប៉ែល បានហៅ ហ៊ី សុធារី និង ឡុង ឆឺន ទៅមើលតំបន់រំដោះលេខ១៥ តាមការណែនាំរបស់ វិញ អាន ។ នៅទីនោះ ប៉ែល និងមិត្តភក្តិទាំងពីរបានជួបប្រាស្រ័យនឹងទ្រង់ ភូរិស្សរា, ហ៊ូ យន់ និងអ្នកដទៃទៀត ដែលគាត់មិនដែលស្គាល់សោះ ។ ហ៊ូ យន់ បានថ្លែងអំណរគុណ ប៉ែល និងមិត្តភក្តិនឹងកោតសរសើរចំពោះយុវជនដែលបានចូលរួមសកម្មភាពក្នុងការប្រឆាំងនិងពួកក្បត់ ។ ប៉ែល មានការចាប់អារម្មណ៍ជាខ្លាំងនៅពេលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ហ៊ូ យន់ ឡើងធ្វើសុន្ទរកថា និងបានកោតសសើរចំពោះសេរីភាពក្នុងការរស់នៅរបស់រណសិរ្ស ។ ចាប់តាំងពីពេលនោះមក ប៉ែល បានកោតសរសើរនូវការចាត់តាំងរបស់ចលនាបដិវត្តន៍កម្ពុជា និងខស្បាហ៍ទាក់ទងប្តូរយោបល់ជាមួយ វិញ អាន ។

## សកម្មភាពនៅប្រទេសបារាំង

នៅចុងឆ្នាំ១៩៧២ ប៉ែល បានប្រឡងជាប់បរិញ្ញាប័ត្រច្បាប់ ។ ក្នុងបំណងការពារអធិបតេយ្យភាព និងសេរីភាពរបស់ខ្មែរកម្ពុជាក្រោម និងដោយមានការឧបត្ថម្ភជាប្រាក់ពីឪពុកម្តាយ ប៉ែល បានធ្វើដំណើរទៅសិក្សានៅប្រទេសបារាំងផ្នែកច្បាប់អន្តរជាតិនៅថ្ងៃទី៣០ ខែ១០ ឆ្នាំ១៩៧២ ។

ទៅដល់ប្រទេសបារាំង ប៉ែល នៅតែបន្តសកម្មភាពសេ.អ៊ី.អា. របស់ខ្លួនដើម្បីរាយការណ៍មកឲ្យ សឺង នី និង តុង ទិន ជានិច្ច ។ ដំបូង ប៉ែល ស្នាក់នៅផ្ទះជាមួយក្រុមរណសិរ្សរួបរួមជាតិនៅទីក្រុងប៉ារីស តែ ប៉ែល នៅតែនិយាយឃោសនាប្រឆាំងនឹងសម្តេចសីហនុ និងចលនាបដិវត្តន៍ ។ ប៉ែល បានទាក់ទងយ៉ាងជិតស្និទ្ធជាមួយ គាន់ វិច្ឆិកា សមាជិករណសិរ្សនិងជាអ្នកទំនុកបម្រុង ប៉ែល ពេលមករស់នៅក្រុងប៉ារីសដំបូង ។ ក្រោយពីហេតុការណ៍ "នៅផ្ទះខ្មែរ" បានផ្ទុះឡើងរវាងក្រុមរណសិរ្ស និងក្រុមសាធារណរដ្ឋនៅថ្ងៃទី៣ ខែ១ ឆ្នាំ១៩៧៣ ប៉ែល បានចេញទៅស្នាក់នៅកន្លែងផ្សេងពីសហគមន៍រណសិរ្សនិងមិនចូលរួមជាមួយក្រុមរណសិរ្សទៀត ។ ប៉ែល ក៏ចាប់ផ្តើមរកការងារធ្វើដោយខ្លួនឯងរហូតបានការងារធ្វើនៅក្នុងក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ។

នៅពាក់កណ្តាលឆ្នាំ១៩៧៣ ប៉ែល ចាប់ផ្តើមទាក់ទងយ៉ាងជិតស្និទ្ធជាមួយខ្មែរកម្ពុជាក្រោម ទ្រឿង មាលី ដែលមានឈ្មោះដើមទ្រឿង កៀកទៀង ហៅ មើយ ជាអតីតសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរ-អង់គ្លេសនៅភ្នំពេញ ។ ប៉ែល បានស្គាល់ ទ្រឿង មាលី តាំងពីខ្លួននៅកម្ពុជាក្រោម ។ ទ្រឿង មាលី បានណែនាំ ប៉ែល ឲ្យធ្វើសន្តិសុខនៅសណ្ឋាគាររបស់ខ្លួន ។ ប៉ែល ធ្វើការនៅពេលយប់និងសិក្សានៅពេលថ្ងៃ ។ ប៉ែល ខស្បាហ៍ទៅបណ្ណាល័យជាតិនៅប៉ារីស ដើម្បីស្រាវជ្រាវអំពីប្រវត្តិខ្មែរក្រោម ហើយ ប៉ែល ក៏បានសរសេរសំបុត្រផ្ញើឲ្យ សឺង នី អំពីលទ្ធផលនៃការស្រាវជ្រាវរបស់ខ្លួនដែរ ។ ក្រៅពីនេះ ប៉ែល ក៏ខស្បាហ៍ស៊ើបសួរសភាពការណ៍នៅប្រទេសកម្ពុជាពីបណ្តាញខ្មែរសេរីនៅទីក្រុងប៉ារីសថែមទៀត ។

នៅដើមឆ្នាំ១៩៧៤ ប៉ែល បានចូលរួមជាមួយ ទ្រឿង មាលី និង សឺន ស៊ូប៊ែរ កូនរបស់ សឺន សាន បង្កើតសមាគម

សម្ងាត់ក្រោមដំណើរការមួយឈ្មោះថា "សមាគមទូទៅនៃអាណិកជនកម្ពុជា" ក្នុងគោលបំណងទាក់ទងយុវជននិស្សិតគ្រប់មជ្ឈដ្ឋានគ្រប់វិស័យឲ្យចូលរួមធ្វើការពិភាក្សាគ្រប់បញ្ហាតាមការចេះដឹងនិងគោលជំហររៀងៗខ្លួន និងឲ្យស្អប់កុម្មុយនិស្តនិងបដិវត្តន៍កម្ពុជា ។ គ្រប់សមាជិកទាំងអស់ត្រូវធ្វើវិភាគទានតាមសមត្ថភាពដើម្បីឧបត្ថម្ភ គ្នាទៅវិញទៅមក ។ តាមរយៈសមាគមនេះ បែល បានធ្វើការស្ទាបស្ទង់ពីឥរិយាបថរបស់និស្សិតដែលមកទាក់ទងនឹងសមាគមនេះ ចំពោះស្ថានភាពនយោបាយនៅកម្ពុជា ។ បែល បានឃោសនាបញ្ចុះបញ្ចូលនិស្សិតសមាជិកសមាគមឲ្យប្រឆាំងនឹងនយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជារបស់សម្តេចសីហនុ ។

ចុងឆ្នាំ១៩៧៤ សឺន សាន បានធ្វើសេចក្តីប្រកាសសុំឲ្យ លន់ នល់ លាលែងពីតំណែងប្រធានាធិបតី ។ ក្រុមរបស់ សឺន សាន រួមមាន សាយ បូរី, ស៊ឹម វ៉ា, អ៊ុន តាំ, សុក ឆុង, ស្រី សាមន និង ទ្រឿង មាលី បានផ្តើមបង្កើត "សមាគមដើម្បីសន្តិភាពនៅកម្ពុជា" ក្នុងបំណងប្រមូលអាណិកជនគ្រប់ទីកន្លែងដើម្បីធ្វើការឃោសនាប្រឆាំងនឹងចលនាបដិវត្តន៍កម្ពុជាដោយមានបោះពុម្ពជាទស្សនាវដ្តីឈ្មោះ"អនុវត្តន៍"ដែលមាន ទ្រឿង មាលី ជាចាងហ្វាងការផ្សាយ ។ ទស្សនាវដ្តីនេះបោះផ្សាយនូវអត្ថបទដែលកាត់ចេញពីកាសែតអន្តរជាតិនិយាយប្រឆាំងនឹងចលនាបដិវត្តន៍នៅប្រទេសកម្ពុជា ។ ប៉ុន្តែក្រោយមកសមាគមនេះបានរំសាយទៅវិញដោយខ្វះសមាជិក ហើយមជ្ឈដ្ឋានបារាំងមិនគាំទ្រ ម្យ៉ាងគម្រោងការទាមទារឲ្យ លន់ នល់ លាលែងពីតំណែងក៏មិនបានសម្រេចទៀត ។

នៅដើមឆ្នាំ១៩៧៥ បែល បានធ្វើការឃោសនាយ៉ាងសកម្មក្នុងមជ្ឈដ្ឋាននិស្សិតដើម្បីឲ្យនិស្សិតទាំងនោះមានក្តីសង្ឃឹមលើរបបសាធារណរដ្ឋខ្មែរ ។ ពេលប្រជុំក្នុងសមាគមទូទៅនៃអាណិកជនកម្ពុជា បែល បានចាត់តាំងឲ្យ ម៉ែន សារិន, សាម យឿង, ហ៊ិន គូ និង ណាម តាលន់ និយាយអូសទាញឲ្យអង្គប្រជុំស្របគំនិតតាមខ្លួន ។ ក្រៅពីឃោសនាជាសម្ងាត់ បែល បានខ្នះខ្នែងអប់រំក្រុមរបស់ខ្លួននូវគោលនយោបាយធំៗដើម្បីឲ្យមានមូលដ្ឋានគ្រប់គ្រាន់ខាងផ្នែកទ្រឹស្តីក្នុងការនិយាយសសើរពីរបបសេរីនិយម ហើយប្រឆាំងនឹងរបបកុម្មុយនិស្ត ។

ក្រោយពីថ្ងៃជោគជ័យរបស់បដិវត្តន៍នៅឆ្នាំ១៩៧៥ ទ្រឿង មាលី និង សឺន ស៊ូប៊ែរ បានចេញមុខប្រឆាំងដោយចំហនឹងបដិវត្តន៍របស់ពួករណសិរ្សដែលបានជម្លៀសនិងកាប់សម្លាប់ប្រជាជន ។ ទ្រឿង មាលី បានបញ្ជាក់ប្រាប់ បែល ជាចំហថា ខ្លួនជាភ្នាក់ងារ សេ.អ៊ី.អា ដែលបង្កប់ខ្លួននៅក្នុងរណសិរ្សរួបរួមជាតិតាំងពីមុនឆ្នាំ១៩៧០ ។ សមាគមទូទៅនៃជនកម្ពុជាបានក្លាយទៅជាសំបុកមួយប្រឆាំងនឹងកុម្មុយនិស្តនិងការបដិវត្តន៍នៅកម្ពុជា ។ ទ្រឿង មាលី បានចាត់តាំង បែល ឲ្យធ្វើជាមេក្រុមទទួលកិច្ចពង្រឹងគោលជំហរប្រឆាំងនឹងកុម្មុយនិស្តនិងចលនាបដិវត្តន៍នៅកម្ពុជា និងធ្វើសកម្មភាពកសាងកម្លាំងសេ.អ៊ី.អា ដោយសម្ងាត់ ។

នៅថ្ងៃទី២៨ ខែ៥ ឆ្នាំ១៩៧៥ បែល បានសុំចូលជាសមាជិករណសិរ្សរួបរួមជាតិកម្ពុជា និងសុំប្តូរលិខិតឆ្លងដែនដើម្បីធ្វើដំណើរមកប្រទេសកម្ពុជា ដោយសារតែខ្លួនមានសុខភាពមិនសូវមាំមួននិងនឹករលឹកគ្រួសារ ។ តាំងពីពេលនោះមក បែល ឈប់ទៅរួមប្រជុំក្នុងសមាគមទៀត ប៉ុន្តែ ការទាក់ទងយ៉ាងជិតស្និទ្ធនឹង ទ្រឿង មាលី គឺនៅដដែល ។ ទ្រឿង មាលី បានអប់រំណែនាំនិងអូសទាញ បែល ឲ្យជួយសហការគ្នាដើម្បីចេញផ្សាយទស្សនាវដ្តីមួយ និងឲ្យជួយរកអ្នកដែលគួរទុកចិត្តដើម្បីជួយធ្វើកិច្ចការនេះ ។

នៅដើមឆ្នាំ១៩៧៦ បែល បានណែនាំ ម៉ែន សារិន, ម៉ី ធឿន និង សាម យឿង ឲ្យទៅធ្វើការជាមួយ ទ្រឿង មាលី បន្ទាប់ពីខ្លួនបានអប់រំនិងបញ្ចូលអ្នកទាំងបីទៅក្នុងខ្សែ សេ.អ៊ី.អា រួច ។ ក្រោយមកព្រឹត្តិបត្ររបស់ ទ្រឿង មាលី ក៏លេចចេញជារូបរាងឡើងមានឈ្មោះថា "អនុវត្តន៍" ។ ជាលទ្ធផល"សមាគមទូទៅនៃអាណិកជនកម្ពុជា" ត្រូវបានទទួលស្គាល់តាមផ្លូវច្បាប់នៅខែ៣ ឆ្នាំ១៩៧៦ ។

នៅខែ៥ បែល សុំបានលិខិតឆ្លងដែនមកស្រុកខ្មែរ ។ បែល បានសុំឲ្យ ទ្រឿង មាលី ជួយណែនាំអប់រំបន្តដល់ ម៉ែន សារិន, ហ៊ិន គូ, និង ណាម តាលន់ ។ តាំងពីពេលនោះមក បែល និង ទ្រឿង មាលី តែងតែទាក់ទងគ្នាជាសម្ងាត់ ដើម្បីពិភាក្សាអំពីសភាពការណ៍នៅស្រុកខ្មែរ ។

នៅខែ៧ បែល បានទាក់ទងសមាគមនៃអាណិកជនស្នេហាជាតិកម្ពុជាប្រចាំប្រទេសបារាំង ដែលមាន ហ៊ីង អ៊ុន ជាប្រធាន ។ បែល បានតាមដានព្រឹត្តិការណ៍នៅកម្ពុជាជារៀងរាល់ខែតាមរយៈទស្សនាវដ្តី "កម្ពុជារូបភាព" និងបានចូលរួមប្រជុំនៅក្នុងសមាគមដើម្បីតាមដានសភាពការណ៍និងចូលរួមសិក្សាទ្រឹស្តីម៉ាក៌បដិវត្តន៍នៅក្នុងស្រុកខ្មែរ ក្រោមការណែនាំយ៉ាងយកចិត្តទុកដាក់ពី ហ៊ីង អ៊ុន, ទូច, និង ចៅ សុខគុណ ។ បែល រៀនតាំងពីរបៀបនិយាយស្តី និងរបៀបប្រើពាក្យពេចន៍ជាមួយបងប្អូនកសិករដើម្បីចៀសវាងនូវការប្រើពាក្យណាដែលមានលក្ខណៈជាវណ្ណៈឬការជិះជាន់ ។

នៅខែ៨ បែល បានធ្វើទស្សនកិច្ចសិក្សានៅប្រទេសសង្គមនិយមមួយចំនួនដូចជាសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ប្រទេសសង្គមនិយមប៉ូឡូញ និងប្រទេសហុំងឡង់ ដើម្បីស្វែងយល់ពីការគ្រប់គ្រងក្នុងរបបសង្គមនិយម ។ បន្ទាប់ពីដំណើរទស្សនានេះ បែល បានដាក់ពាក្យសុំត្រឡប់មកកម្ពុជា ។

តែមុនចេញដំណើរមកស្រុកខ្មែរ ឡៀង មាលី បានស្កាត់ជួប និងដាក់ផែនការប្រឆាំងនឹងបដិវត្តន៍កម្ពុជាឲ្យ បែល អនុវត្តនៅកម្ពុជា ទី១) ក្តាប់សភាពការណ៍នៅកម្ពុជាឲ្យណែនគ្រប់វិស័យនយោបាយ សេដ្ឋកិច្ច និងផ្នែកយោធា ទី២) ទាក់ទងវិញ អាន, ថាច់ ឆួន និងពួកសិស្សនិស្សិតមួយចំនួនដែលធ្លាប់ធ្វើសកម្មភាពប្រឆាំងបដិវត្តន៍នៅកម្ពុជាដើម្បីពិភាក្សារកទិសដៅធ្វើសកម្មភាពអុកឡុកក្នុងសហករណ៍និងក្នុងសហជីព ។

## ការចាប់ខ្លួននិងចម្លើយសារភាព

ថ្ងៃទី២៩ខែ១០ឆ្នាំ១៩៧៦ បែល បានមកដល់កម្ពុជា ។ គាត់ត្រូវបានបញ្ជូនឲ្យទៅរស់នៅមន្ទីរក-១៥បឹងត្របែក ។ នៅទីនោះ បែល បានជួប តាន់ វិច្ឆិកា, លិប ស៊ិត និងមិត្តភក្តិផ្សេងទៀតដែលធ្លាប់ស្គាល់នៅក្រុងប៉ារីសចំនួន១៥នាក់ ។ បែល បានទទួលការអប់រំឲ្យលត់ដំខ្លួនទៅជាកម្មករកសិករដើម្បីដើរឲ្យទាន់មហាចលនាបដិវត្តន៍ ។ ក្រោយមក បែល បានចូលក្នុងក្រុមសិប្បកម្មដែលមាននាទីជាប្រធាន ។

ក្នុងរយៈពេលនៅមន្ទីរក-១៥ បែល មិនបានធ្វើសកម្មភាពអ្វីប្រឆាំងនឹងរដ្ឋអំណាចបដិវត្តន៍ទេ ព្រោះអ្នកដែលនៅក្នុងមន្ទីរសុទ្ធតែជាអ្នកដែលដឹងថា បែល ធ្លាប់ប្រឆាំងនឹងរណសិរ្សរួបរួមជាតិកម្ពុជាពេល បែល នៅបារាំង ។ នៅថ្ងៃទី១០ ខែ១១ បែល បានចូលរួមវគ្គសិក្សាដែលអង្គការចាត់តាំងឡើងសម្រាប់អ្នកមកដល់ថ្មី ហើយ បែល ក៏ត្រូវអង្គការចាប់ខ្លួននៅទីនោះ ។

បែល ត្រូវបានសួរចម្លើយច្រើនជាង៤លើកនៅមន្ទីរស-២១ ។ ចម្លើយសារភាពរបស់ បែល មានកាលបរិច្ឆេទ ថ្ងៃទី២០ ខែ១១ ឆ្នាំ១៩៧៦, ថ្ងៃទី១៧ ខែ១២ ឆ្នាំ១៩៧៦, ថ្ងៃទី១៥ ខែ១២ ឆ្នាំ១៩៧៦ និងថ្ងៃទី៥ ខែ១ ឆ្នាំ១៩៧៧ និងចម្លើយសារភាពខ្លះទៀតមិនមានកាលបរិច្ឆេទច្បាស់លាស់ទេ ។ ភាគច្រើននៃចម្លើយសារភាពរបស់ បែល តែងមានការសរុបសេចក្តីដោយអ្នកសួរចម្លើយឈ្មោះ សេង, ទុយ និង ខន ។ ចម្លើយសារភាពនៅថ្ងៃទី៥ ខែ១ ឆ្នាំ១៩៧៧ មានចំណាររបស់ ឌុច ថា "ស្មើកុំឲ្យលង់ទៅក្នុងរឿងចាស់ពេក ត្រូវគិតពីរឿងថ្មី" ។

នៅក្នុងចម្លើយសារភាពនីមួយៗ បែល បានបញ្ជាក់ពីទំនាក់ទំនងជាមួយក្រុមមនុស្សជាច្រើន ក្នុងសកម្មភាពផ្សេងៗគ្នាដោយមិនបានបញ្ជាក់ពីជំហរពិតប្រាកដរបស់ខ្លួនឡើយ ។ ការទាក់ទងរបស់ បែល បានឆ្លងពីមជ្ឈដ្ឋានយុវជន និស្សិត ដល់មជ្ឈដ្ឋានអ្នកនយោបាយ ប៉ុន្តែស្ទើរតែគ្រប់មុខងារ បែល ធ្វើក្នុងបុព្វហេតុគាំទ្រចលនាដែលមាននិន្នាការទៅរកលិទ្ធិសេរីនិយមដែលអាចរំដោះកម្ពុជាក្រោមចេញពីការកៀបសង្កត់របស់ពួកយៀកកុង ។

បែល បានសារភាពកំហុសដែលខ្លួនបានបម្រើឲ្យពួកក្បត់ និងបានកោតសសើរចំពោះការដឹកនាំរបស់បដិវត្តន៍កម្ពុជា ។ បែល បានសារភាពថា "បន្ទាប់ពីត្រឡប់មកដល់មាតុប្រទេសវិញ ខ្ញុំនឹកដល់អំពើក្បត់របស់ខ្ញុំដែលប្រព្រឹត្តផ្ទុយនឹងផលប្រយោជន៍ជាតិ កម្មករ-កសិករ និងចលនាបដិវត្តន៍កម្ពុជា ។ ឥឡូវនេះ ខ្ញុំមកដល់មាតុប្រទេសដែលប្រកបដោយសង្គមមួយថ្មី ហើយយុត្តិធម៌មានរូបភាពជាក់ស្តែងដែលពុំមែនមានតែក្នុងក្រដាស ។ ខ្ញុំប្តេជ្ញាកសាងសតិអារម្មណ៍ជាថ្មីកុំឲ្យធ្លាក់ខ្លួនទៅរកផ្លូវខុសម្តងទៀត ។ ខ្ញុំជឿថាក្រោមការណែនាំរបស់អង្គការ ខ្ញុំនឹងក្លាយទៅជាមនុស្សមានប្រយោជន៍ចំពោះប្រជាជាតិជាពុំខាន ។ ខ្ញុំមានការរំភើប ដោយបានឃើញនឹងភ្នែកនូវការយកចិត្តទុកដាក់របស់អង្គការចំពោះជនដែលបានដើរផ្លូវខុស" ។

## បញ្ជីឈ្មោះអ្នកពាក់ព័ន្ធនៅក្នុងចម្លើយសារភាពរបស់ អុង បែល

ថាច់ ឌី ព្រះសង្ឃនៅវត្តច័ន្ទរង្សី(កម្ពុជាក្រោម) ផ្នែកខាងឃោសនាខ្មែរសេរី ក្រោយមកពាក់សក្តិ៤ ◆ ថាច់ ហួយ ព្រះសង្ឃវត្តមហាមន្ត្រីភ្នំពេញ ខ្មែរសេរីអ្នក ទាក់ទង ◆ ថាច់ ហេន ក្រុមហ៊ុនទេសចរណ៍ ខ្មែរសេរី អ្នកឃោសនា ◆ នាជ រិន ខ្មែរសេរី អ្នកទាក់ទង ◆ ថាច់ សាំង ខ្មែរសេរី ភ្នំពេញ ◆ ថាច់ យ៉ាង ខ្មែរសេរី និស្សិតនៅកម្ពុជាក្រោម ◆ ថាច់ ណាំង ខ្មែរសេរី និស្សិតនៅកម្ពុជាក្រោម ◆ ត្រឹង កេះ ខ្មែរសេរី និស្សិតនៅកម្ពុជាក្រោម ◆ វិញ ថន ខ្មែរសេរី និស្សិតកម្ពុជាក្រោម ◆ អឿ ឈួន សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ សេង ផុន សិស្សមកពីខេត្តសៀមរាប ធ្វើការនៅរោងពុម្ព នៅក្រុងភ្នំពេញ ◆ ពាង ធុនហាក់ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ សុខ មីសែល សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ម៉ែន សុវណ្ណា សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ម៉ែន វង្សា សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ថាច់ ចាន់សសេរី សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ចៅ សុភាក់ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ នួន សុភាព សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ចៅ វ៉ាន សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ ពុត ជ្រៀ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ រស់ ចន្ទ្រាបុត្រ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ អ៊ុង គីមអយ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ អ៊ី វណ្ណៈ សិស្សវិទ្យាល័យស៊ីសុវត្ថិ ◆ សន ថាត ប្រធានសមាគមនិស្សិតមហាវិទ្យាច្បាប់ សេ.អ៊ី.អា. ◆ ធូ ថុន និស្សិតមហាវិទ្យាល័យច្បាប់ ◆ ខូវ ម៉េងហ៊ាន និស្សិតមហាវិទ្យាល័យច្បាប់ ◆ ប៊ុន សយ និស្សិតមហាវិទ្យាល័យច្បាប់ ◆ ហ៊ី សុធារី និស្សិតមហាវិទ្យាល័យច្បាប់ ◆ ឡុង ធីន និស្សិតមហាវិទ្យាល័យច្បាប់ ◆ ហ៊ុយ វ៉ោវ៉ា និស្សិតមហាវិទ្យាល័យច្បាប់ ◆ កុយ ប៊ុច និស្សិតមហាវិទ្យាល័យច្បាប់ ◆ ឌុក វ៉ាស៊ី តំណាងរាស្ត្រ និងជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យច្បាប់ ◆ សឹង នី សាស្ត្រាចារ្យ សេ.អ៊ី.អា. ខ្មែរសេរី ◆ គុង ទិន អគ្គរក្សសឹង ដុំកថាញ់ សេ.អ៊ី.អា. ខ្មែរសេរី ◆ ទ្រឿង មាលី ឈ្មោះដើម ទ្រឿង ភឿកទៀង ហៅ មើយ អតីតសាស្ត្រាចារ្យនៅវិទ្យាល័យខ្មែរ-អង់គ្លេសនៅភ្នំពេញ ក្រោយមកទៅរស់នៅប្រទេសបារាំង ◆ ម៉ែន សារិន និស្សិត សេ.អ៊ី.អា. នៅប្រទេសបារាំង ◆ ហ៊ិន គូ និស្សិត សេ.អ៊ី.អា. នៅប្រទេសបារាំង ◆ សឺន ស៊ូប៉ែ និស្សិត សេ.អ៊ី.អា. នៅប្រទេសបារាំង ◆ ណាម តាលន់ និស្សិត សេ.អ៊ី.អា. នៅប្រទេសបារាំង ◆ សាម យឿង និស្សិតនៅប្រទេសបារាំង ◆ ម៉ី ធឿន និស្សិត នៅប្រទេសបារាំង ◆ បូ ធីរៈ និស្សិត នៅប្រទេសបារាំង ◆ យឹម យូធន់ និស្សិតនៅប្រទេសបារាំង ◆ គិម តាំងសេង និស្សិត នៅប្រទេសបារាំង ◆ តាំង ឈុនឡាយ និស្សិត នៅប្រទេសបារាំង ◆ ជូ កាឡេង និស្សិត នៅប្រទេសកាណាដា ◆ ថាច់ ផួន អតីតសាស្ត្រាចារ្យនៅវិទ្យាល័យតាខ្មៅ សេ.អ៊ី.អា. ◆ វិញ អាន ភ្នាក់ងារយៀកកុងចាងហ្វាងរោងពុម្ពនៅភ្នំពេញ ◆ គិម កេត ភ្នាក់ងារយៀកកុងសក្តិ៤ កងពលថ្មើរជើងលេខ៧ ◆ ឃួន ដារិត និស្សិត នៅមន្ទីរ ក-១៥ បឹងត្របែក ◆ ង៉ោ ហាក់ទៀម អតីតសាស្ត្រាចារ្យ ◆ នួន យឿន សាស្ត្រាចារ្យ ◆ ផុង គីមហុង និស្សិត ◆ ថាច់ សេរីសុផាន់ គីផាត់ និស្សិត ។

**ណាយ សុផារី**

ប៊ូ ម៉េង អតីតអ្នកទោសនៅមន្ទីរស-២១កំពុងសាកសួរឯកឧត្តម ស៊ាន វិសុទ្ធ អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម





អគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ
(តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម)

ប្រជាជនមកធ្វើទស្សនកិច្ចអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៨៨៥ | រស់ ឆាត ហៅ សៀម | សមាជិកកងធំ | ពាណិជ្ជកម្មរដ្ឋ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៨៨៦ | ទេព អុល ហៅ យឹម | លេខាវរសេនាតូច | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៨៨៧ | ហៃ ស៊ាប ហៅ ផាត | និរសារ | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៨៨៨ | យឹម យឿន ហៅ ភព | យុទ្ធជន | ក្រសួងការបរទេស | ២៥-១-៧៧ | ១២-៥-៧៧ |
| ២៨៨៩ | សំ រិតវង់ ហៅ ជា | លេខាវរសេនាតូច | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៨៩០ | ព្រុំ បួ ហៅ ដាន | លេខាវរសេនាតូច | កងពល៣១០ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៨៩១ | អ៊ឹម ស្រ៊ុន ហៅ ធួន | យុទ្ធជន | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៨៩២ | អ៊ុម ពឹម ហៅ ជុន | លេខាវរសេនាតូច | កងពល៣១០ | ?-២-៧៧ | ១២-៥-៧៧ |
| ២៨៩៣ | ជុំ លីម ហៅ ពល | លេខាវរសេនាតូច | កងពល៣១០ | ២៧-២-៧៧ | ១២-៥-៧៧ |
| ២៨៩៤ | ហាវ ហួត ហៅ ហម | យោធាវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៨៩៥ | សួន អ៊ីច ហៅ សារិន | និរសារ | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៨៩៦ | ម៉េ ធឹង ហៅ ម៉ុល | ប្រធានបច្ចេកទេស | ឃ្លាំងរដ្ឋ | ៩-២-៧៧ | ១២-៥-៧៧ |
| ២៨៩៧ | មាន សុនីម ហៅ ឡេង | មេក្រុម | ផែកំពង់សោម | ២៣-១-៧៧ | ១២-៥-៧៧ |
| ២៨៩៨ | តាយ សេង | កម្មករចាស់ | រោងចក្រគ-៣ | ២៩-២-៧៧ | ១២-៥-៧៧ |
| ២៨៩៩ | ដួង ញ៉ូ ហៅ ធី | និរសារ | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៩០០ | អ៊ុត អាន | និរសារ | តំបន់១០៦ | ២១-២-៧៧ | ១២-៥-៧៧ |
| ២៩០១ | ទុយ វ៉ាន់ | លេខាវរសេនាតូច | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៩០២ | ហេង ចាន់ថន ហៅ ផល | មេក្រុម | ក្រសួងការបរទេស | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៩០៣ | អាត់ ញ៉ែម ហៅ វើង | ភ័ស្តុភារកងធំ | ឃ្លាំងរដ្ឋ | ២៥-២-៧៧ | ១២-៥-៧៧ |
| ២៩០៤ | មៀច សាត ហៅ ស៊ើន | ជំនួយការ | កងពល៣១០ | ២៦-២-៧៧ | ១២-៥-៧៧ |
| ២៩០៥ | ម៉ា វ៉ា | យុទ្ធជន | កងពល៣១០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩០៦ | គង់ អុន ហៅ សួន | សមាជិកកងធំ | កងពល៤៥០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩០៧ | អិត ផាន់ | សមាជិកកងហ | កងពល៤៥០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩០៨ | ដែក ផុន ហៅ ដី | យុទ្ធជន | កងពល៤៥០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩០៩ | លុយ វ៉ាយ ហៅ រុន | យោធាកងធំ | កងពល៤៥០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩១០ | គិញ ហួន | យុទ្ធជន | កងពល៤៥០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៩១១ | ប៊ិច ហឿន ហៅ ធាង | យុទ្ធជន | កងពល៤៥០ | ១០-៥-៧៧ | ១៤-៥-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៥១២ | មុំ សឿន ហៅ សេន | យុទ្ធជន | កងពល៣១០ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៣ | នុយ គី ហៅ ទ្រី | យុទ្ធជន | កងពល៣១០ | ១០-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៤ | សិត មុយ ហៅ មឿន | លេខាកងធំ | កងពល៣១០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៥ | នួន ឆេន | ជំនួយការ | កងពល៣១០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៦ | វ៉ែន វ៉ន | យុទ្ធជន | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៧ | នាង យឿន ហៅ យាក | យុទ្ធជន | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៨ | វ៉ាន់ ស៊ីង | យោធាកងហ | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥១៩ | ហែម អឿន ហៅ យិនណារិន | យុទ្ធជន | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២០ | ឌី ម៉ៅ ហៅ អាត | យោធាកងហ | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២១ | កុយ ហេង ហៅ រីន | សមាជិកកងហ | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២២ | គង់ ហ៊ិត | យោធាកងហ | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៣ | ថាំង ឡុច ហៅ ហ៊ាប | អនុនយោបាយ | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៤ | ទឹម អាត ហៅ សាន | មេពួក | កងពល៤៥០ | ១១-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៥ | លួន ឆែម ហៅ ថេន | សមាជិកក្រុម | កងពល៤៥០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៦ | ង៉ួយ តារារិទ្ធ ហៅ តារា | យុទ្ធជន | កងពល៤៥០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៧ | អ៊ុម វឿន ហៅ នាង | អនុក្រុម | កងពល៤៥០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៨ | ឡឹក ហៃ ហៅ ហ៊ាន | ភ័ស្តុភារ | កងពល៤៥០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥២៩ | ហួត វិន | យោធាកងហ | កងពល៤៥០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥៣០ | ទន់ កា ហៅ ទី (ស្រី) | យោធាកងធំ | កងពល៣១០ | ១៣-៥-៧៧ | ១៤-៥-៧៧ |
| ២៥៣១ | នុត សុវណ្ណ ហៅ ចារ (ស្រី) | ប្រពន្ធទីមទី | កងពល៣១០ | ៤-៣-៧៧ | ១៤-៥-៧៧ |
| ២៥៣២ | ទឹម យ៉ា ហៅ សឿន (ស្រី) | មេក្រុមពេទ្យ | កងពល៣១០ | ២១-៤-៧៧ | ១៤-៥-៧៧ |
| ២៥៣៣ | ឆេង យ៉ន ហៅ វ៉ន (ស្រី) | អនុប្រធានកងហ | កងពល៣១០ | ២១-៤-៧៧ | ១៤-៥-៧៧ |
| ២៥៣៤ | ព្រុំ ញ៉ ហៅ វឿន (ស្រី) | ប្រពន្ធ អឿន | កងពល៣១០ | ២៧-២-៧៧ | ១៤-៥-៧៧ |
| ២៥៣៥ | ទាង មន ហៅ មឿន (ស្រី) | ប្រពន្ធ អ៊ីឡេងហឿន | កងពល៣១០ | ២៨-៤-៧៧ | ១៤-៥-៧៧ |
| ២៥៣៦ | ទិន ហុង (ស្រី) | ភ័ស្តុភារ | កងពល៣១០ | ៨-៥-៧៧ | ១៤-៥-៧៧ |
| ២៥៣៧ | គឹម ឈឿន ហៅ យឿន (ស្រី) | អនុនយោបាយ | កងពល៣១០ | ៨-៣-៧៧ | ១៤-៥-៧៧ |
| ២៥៣៨ | ណាល់ ផល ហៅ វិន (ស្រី) | ប្រពន្ធ អែ សំបូរ ហៅ ឆន | កងពល៣១០ | ៥-៥-៧៧ | ១៤-៥-៧៧ |
| ២៥៣៩ | សូ ផុន (ស្រី) | ប្រពន្ធ សាវ៉ន | រោងចក្រ គ-២ | ១៩-៤-៧៧ | ១៤-៥-៧៧ |
| ២៥៤០ | គឹម ថុន ហៅ ដាតិ (ស្រី) | យុទ្ធនារី ប្រពន្ធ ហ៊ុត ហ៊ុនដី | រោងចក្របាន | ៩-៣-៧៧ | ១៤-៥-៧៧ |
| ២៥៤១ | ម៉ាន់ សុកយ៉េង (ស្រី) | ប្រពន្ធ យុក យាងលាង | រោងចក្រដ-២ | ១៦-៣-៧៧ | ១៤-៥-៧៧ |
| ២៥៤២ | ឡុង លីដូ (ស្រី) | ប្រពន្ធ តូចតែម | រោងចក្រក-ហ | ៨-៣-៧៧ | ១៤-៥-៧៧ |

**(នៅមានត)**

# រឿងរ៉ាវដែលមិនចេះសាបសូន្យ

## ស្រី យ៉ា
## អតីតមេបញ្ជាការរងយោធភូមិភាគពិសេស នៃរបបសាធារណរដ្ឋខ្មែរ

*ស្រី ហោះសង្វារ ហៅ សង្ហា បានបង្ហាញរូបថតពាសន្ទឹកនិង អត្តសញ្ញាណប័ណ្ណមួយសន្លឹករបស់ឪពុកគាត់ឈ្មោះ ស្រី យ៉ា ដែល ជាអតីតមេបញ្ជាការរងយុទ្ធភូមិភាគពិសេសក្នុងរបបសាធារណ រដ្ឋខ្មែរ ។ រូបថតទាំងនោះត្រូវបានបងស្រីរបស់ សង្ហា ឈ្មោះ ស្រី ពុធសាវឌី ជាអ្នកយកទៅរក្សាទុកនៅប្រទេសបារាំងតាំងពីមុន ឆ្នាំ១៩៧៥ ។ សង្ហា ទើបតែប្រមូលរូបថតនោះមកវិញក្រោយ ពេលរបបខ្មែរក្រហមដួលរលំ ។ សង្ហា គឺជាកូនប្រុសពៅរបស់ ស្រី យ៉ា ។ សង្ហា មានការស្ញប់ស្ញែងចំពោះឪពុករបស់គាត់ ណាស់ ។ ខាងក្រោមនេះគឺជាអ្វីដែល សង្ហា ចងចាំអំពីឪពុករបស់ គាត់ ÷*

ខ្ញុំនៅចាំសម្តីដែលប៉ាខ្ញុំនិយាយថា "ប៉ាជាមេទ័ព ប៉ាមិនអាច រត់ចោលប្រទេសជាតិទៅនៅស្រុកគេទេ ប៉ាសុខចិត្តស្លាប់នៅស្រុក ខ្មែរ" ។ នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ មានភាពជ្រួលច្របល់ ខ្លាំង ម៉ាក់របស់ខ្ញុំបានប្រាប់ប៉ាឲ្យរត់ភៀសខ្លួនទៅនៅប្រទេស ក្រៅ ប៉ុន្តែប៉ាខ្ញុំមិនព្រមទៅទេ ។ គាត់សុខចិត្តនៅភ្នំពេញ ទោះបី ជាដឹងថាខ្លួនគាត់ត្រូវស្លាប់ក៏ដោយ ។

ប៉ាជាមេទ័ពខ្លាំង ។ ប៉ាមិនដែលរារែកនៅសមរភូមិណា ឡើយ ។ ប៉ាបានឆ្លងគ្រោះថ្នាក់និងប្រយុទ្ធយ៉ាងស៊ិតស្វាញនៅ សមរភូមិជាច្រើន ។ ប៉ាស្រលាញ់ខ្ញុំណាស់ ខ្ញុំជាអ្នកជួយរៀបចំ សម្លៀកបំពាក់ឲ្យប៉ារាល់ពេលគាត់ចេញទៅសមរភូមិម្តងៗ ។

ប៉ាម៉ាក់ខ្ញុំមានស្រុកកំណើតនៅស្រុកត្បូងឃ្មុំ ខេត្តកំពង់ ចាម ។ បន្ទាប់ពីប៉ាចូលធ្វើគ្រូបង្រៀននៅសាលាកំពង់ចាម ប៉ា បានរៀបការជាមួយម៉ាក់ ។ ប៉ាខ្ញុំកាចណាស់ មានពេលមួយ សិស្សរបស់គាត់រៀនអក្សរមិនចេះ គាត់វាយសិស្សនោះ ។ សិស្សនោះនិយាយថា "មិនអីទេ ពេលណាអញបានចូលធ្វើ ទាហាន អញរករឿង គ្រូយ៉ា ឯងវិញម្តង" ។ ក្រោយមក ប៉ាខ្ញុំ បានចូលធ្វើនាយទាហានសកម្ម ចំណែកសិស្សនោះធ្វើជាកូន ទាហានរបស់ប៉ាខ្ញុំ ។ ពេលខ្ញុំមានអាយុ៦-៧ខែ ប៉ាខ្ញុំទៅរៀន ផ្នែកនាយទាហាននៅប្រទេសបារាំង ។

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុមគ្រួសារខ្ញុំបាន រៀបចំដំណើរកម្សាន្តទៅទីក្រុងកែប ។ យើងចេញដំណើរបានតែ បន្តិចក៏ទទួលដំណឹងពីភ្នំពេញថា មានរដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ ។ លុះស្អែកឡើងថ្នាក់លើរបស់ប៉ាដកគាត់ឲ្យ ទៅធ្វើខាងទាហានចម្បាំង ។ ក្រោយមកប៉ាខ្ញុំឡើងបានសក្តិ៤ កង វរសេនាតូចឆ័ត្រយោងទី១ ។ ប៉ាចូលប្រយុទ្ធស្ទើរគ្រប់សមរភូមិ ។ ក្នុងអំឡុងពេលប៉ាចេញច្បាំងសមរភូមិដែលប្រយុទ្ធខ្លាំងបំផុត គឺ សមរភូមិព្រៃទទឹង ។ ការប្រយុទ្ធគ្នាកាន់តែសាហាវឡើងៗ ខាង កងទ័ពលន់នល់ពិបាកទប់ទល់ជាមួយកងទ័ពយៀកកុង ។ នៅនាទី ចុងក្រោយខាងអគ្គសេនាធិការបានចាត់កម្លាំងបន្ថែមដើម្បីទៅ ជួយជាជំនួយ ។ ប៉ារបស់ខ្ញុំសម្រេចឲ្យយន្តហោះទម្លាក់គ្រាប់បែក ពីព្រោះ បើមិនដូច្នោះទេពិតជាស្លាប់ទាំងអស់គ្នា ។ ប៉ាខ្ញុំបានបញ្ជា ឲ្យកូនទាហានទាំងអស់រួមកម្លាំងគ្នាបាញ់បន្ថែមទៀតរហូតទទួល បានជ័យជម្នះ ។ ក្រោយពីទទួលបានជ័យជម្នះនៅសមរភូមិ ប៉ាខ្ញុំ ទទួលបានទង់សុវណ្ណជាលា (ទង់កិត្តិយស) ពីលោកសេនាប្រមុខ លន់ នល់ ។

ក្រោយមកប៉ាបានចូលប្រយុទ្ធនៅសមរភូមិពេជនិល ។ ពេលនោះកូនទាហានរបស់គាត់បានប្រយុទ្ធយ៉ាងតឹងតែងជាមួយ កងទ័ពខ្មែរក្រហម ប៉ុន្តែនៅតែវាយមិនបែក ។ ការប្រយុទ្ធនៅតែ មិនដឹងឈ្នះចាញ់ ។ ប៉ាបានចេញប្រយុទ្ធដោយផ្ទាល់ ។ គាត់បើក ឡានហ្ស៊ីបនិងកាន់កាំភ្លើងវែង ។ ប៉ាមិនទម្លាប់ប្រើកាំភ្លើងខ្លីទេ ។ នៅក្នុងសមរភូមិ ខ្មែរក្រហមបាញ់ត្រូវបង់កាំភ្លើងគាត់ បណ្តាល ឲ្យភ្លើងឆេះខោអាវគាត់ និងដួលនៅនឹងកន្លែង ។ ខោអាវគាត់ឆេះ រហែករយ៉ៃ ប៉ុន្តែអត់ត្រូវរបួសធំដុំទេ ។ ពេលនោះកូនទាហានក៏ គ្រាហ៍គាត់ឡើងឡានដកថយមកវិញ ។ ពេលនោះកាសែតកោះ សន្តិភាពក៏បានចុះផ្សាយព័ត៌មានអំពីគាត់ដែរ ។ ប៉ាខ្ញុំបានបង្ហាញ

ខោស៊ីបដែលរហែកឲ្យអ្នកកាសែតថត ។ ប៉ាបានយកខោអាវដែលរហែកនោះមកដាក់តាំងនៅផ្ទះទុកជាអនុស្សាវរីយ៍ ។

នៅល្ងាចថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ប៉ារបស់ខ្ញុំបានប្រាប់ម៉ាក់ថា កុំព្រួយបារម្ភអីគេឈប់ច្បាំងគ្នាហើយ ។ បើត្រូវជម្លៀសចេញពីភ្នំពេញគឺយើងចេញតែ៣ថ្ងៃប៉ុណ្ណោះ ហើយម្យ៉ាងទៀត អៀង សារី ជាមិត្តភក្តិធ្លាប់ធ្វើគ្រូបង្រៀនជាមួយគ្នា ។ ម៉ាក់ខ្ញុំក៏ប្រាប់ប៉ាវិញដែរថា គាត់បានឮព័ត៌មានផ្សាយតាមវិទ្យុបរទេសថា មានបញ្ជាឲ្យសម្លាប់ឧត្តមសេនីយ៍ចំនួនប៉ុន្មានរូបនៅក្នុងចំណោមនោះក៏មានឈ្មោះប៉ារបស់ខ្ញុំដែរ ។ ម៉ាក់បានប្រាប់ឲ្យប៉ាគេចខ្លួនទៅប្រទេសក្រៅមួយរយៈសិន ប៉ុន្តែប៉ាមិនព្រម ។

នៅព្រឹកម៉ោង៩ នាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមចូលពាសពេញទីក្រុងភ្នំពេញ ទាហានលន់នល់ ដោះសម្លៀកបំពាក់ទាហានចេញស្លៀកពាក់ជាស៊ីវិលវិញ ។ ពេលនោះប៉ាបានឲ្យតែកុងឡានមកទទួលយកគ្រួសារខ្ញុំទៅក្រសួងឃោសនាការពីព្រោះប៉ាយល់ថា នៅទីនោះគ្មានអ្នកណាអាចធ្វើអ្វីយើងបាន ។ ក្រុមគ្រួសារខ្ញុំនៅរង់ចាំប៉ាខាងមុខក្រសួងឃោសនាការមិនចេញទៅណាទេ ។ នៅប្រហែលវេលាម៉ោង១២ថ្ងៃត្រង់ ខ្ញុំបានឃើញបុរសម្នាក់មកជម្រាបសួរម៉ាក់ ដោយហៅម៉ាក់ថា លោកជំទាវ ។ គាត់បានប្រាប់ម៉ាក់ថា គាត់ឈ្មោះ កុយ ធួន ជាអតីតសិស្សរបស់ប៉ា ។ កុយ ធួន បានសុំឲ្យម៉ាក់ធ្វើដំណើរទៅស្ថានទូតបារាំង ។ គាត់អះអាងថា នៅទីនោះគ្មានអ្នកណាដេញចេញពីភ្នំពេញទេ ។ ម៉ាក់មិនទាន់ចេញពីក្រសួងឃោសនាការទេ ព្រោះគាត់ចង់នៅរង់ចាំប៉ា ។ នៅពេលនោះ ខ្ញុំបានឃើញមន្ត្រីស័ក្តិខ្ពស់របស់លន់នល់ស្លៀកខោទាហានពាក់អាវពណ៌សមកឈប់ឡាននៅទីនោះ ។ ប៉ាខ្ញុំក៏ចេញមកដែរ ។ ប៉ាដោះខោអាវទាហានចេញ ហើយយកទៅទុកនៅក្នុងឡាន ។ អៀង សារី ចេញមកចាប់ដៃអ្នកទាំងនោះ ។ ពេលនោះហើយដែលខ្ញុំបានឃើញមុខ អៀង សារី ច្បាស់ ។ ប៉ាប្រាប់យើងថា អៀង សារី ជាមិត្តភក្តិរបស់គាត់ ។ ប៉ាបានប្រាប់ម៉ាក់ឲ្យនាំបងប្អូនខ្ញុំទៅលាក់ខ្លួននៅស្ថានទូតបារាំង រួចហើយចូលទៅក្នុងវិញជាមួយអស់លោកទាំងនោះ ។ យើងបានធ្វើដំណើរមកដល់ស្ថានទូតបារាំង ។ នៅវេលាម៉ោង៤រសៀល ខ្មែរក្រហមបានភ្ជង់កាំភ្លើង ហើយដេញក្រុមគ្រួសារខ្ញុំចេញពីទីស្ថានទូត ។



ស្រី យ៉ា (រូបពាក់វ៉ែនតាខ្មៅ) ក្នុងរបប លន់ នល់ (១៩៧០-១៩៧៥)

យើងបានត្រឡប់មកផ្ទះវិញ ។ ម៉ាក់បានប្រាប់ពួកខ្ញុំថា "ឈប់គិតពីប៉ាឯងទៅ ប៉ាឯងប្រហែលជាស្លាប់ហើយ" ។ ម៉ាក់បានប្រមូលខោអាវទាហាន ព្រមទាំងឯកសារផ្សេងៗនិងរូបថតរបស់ប៉ាដុតចោលទាំងអស់ ។

ថ្ងៃទី១៨ ខែមេសា ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសារខ្ញុំចេញពីផ្ទះ ។ ពេលនោះ បងប្រុសខ្ញុំភ្លេចរបស់នៅក្នុងផ្ទះគាត់ក៏បកទៅយកវិញ ។ ខ្មែរក្រហមភ្ជង់កាំភ្លើងបម្រុងបាញ់គាត់ ម៉ាក់ខ្ញុំសំពះអង្វរកុំឲ្យបាញ់ ។ ម៉ាក់ខ្ញុំមិនចង់ទៅស្រុកកំណើតទេ ព្រោះនៅទីនោះមានអ្នកស្គាល់ច្រើន ។ គ្រួសារខ្ញុំបានធ្វើដំណើរទៅជាច្រើនកន្លែង ប៉ុន្តែគ្រប់កន្លែងដែលយើងទៅសុទ្ធតែមានអ្នកធ្លាប់ស្គាល់ពីមុនមក ។ គ្រួសារខ្ញុំបានទៅដល់ស្រុកស្អាង ។ នៅទីនោះ ខ្ញុំមានសាច់ញាតិជាច្រើនធ្វើជាកម្មាភិបាលខ្មែរក្រហម ។ ម៉ាក់ខ្ញុំសម្រេចចិត្តចាកចេញពីទីនោះ ព្រោះម៉ាក់គិតថាយូរបន្តិចទៀតប្រាកដជាមានគ្រោះថ្នាក់ ។ យើងបានធ្វើដំណើរទៅដល់អ្នកលឿង ប៉ុន្តែមិនអាចរស់នៅទីនោះបានដោយសារមានសាច់ញាតិធ្វើជាកម្មាភិបាលខ្មែរក្រហម ។ ម៉ាក់នាំកូនៗ ធ្វើដំណើរមកដល់ស្រុកកៀនស្វាយ ។ អង្គការបានសួរម៉ាក់អំពីស្រុកកំណើត ។ ម៉ាក់បានកុហកអង្គការថា ស្រុកកំណើតរបស់គាត់នៅខេត្តពោធិសាត់ ។ អង្គការក៏បញ្ជូនក្រុមគ្រួសារខ្ញុំទៅពោធិសាត់ ។ ក្រុមគ្រួសារខ្ញុំធ្វើដំណើរអស់រយៈពេល៦ខែទើបរកបានកន្លែងមួយ ដែលគ្មានអ្នកណាស្គាល់យើងទាល់តែសោះ ។ ប៉ុន្តែនៅទីនោះគ្រួសារខ្ញុំបានជួបប្រពន្ធលោកឧត្តមសេនីយ៍ទោ ហង់ ប៊ុនហេង ។ ពេលនោះម៉ាក់មិនអាចផ្លាស់ទីកន្លែងបានទៀតឡើយ ។ ៣-៤ថ្ងៃក្រោយមកអង្គការចាប់បងខ្ញុំម្នាក់ឈ្មោះ ស្រី សៃណាទិត្យ យកទៅសម្លាប់ចោល ដោយចោទប្រកាន់គាត់ថាជាតួកុននិងជាទាហានពាក់សក្តិ៣ ។ ម៉ាក់ខ្ញុំក៏មានគំនិតមួយថាយើងមិនអាចរស់នៅជុំគ្នាបានទេ ត្រូវតែនៅបំបែកគ្នា ។ តាំងពី ពេលនោះមកបងប្អូនខ្ញុំរស់នៅបែកគ្នា ។



ស្រី យ៉ា (រូបខាងឆ្វេង) ក្នុងរបប លន់ នល់ (១៩៧០-១៩៧៥)

ខ្ញុំរស់នៅទីនោះលាយចម្រុះគ្នាជាមួយប្រជាជនមូលដ្ឋាន ។ គ្រួសារខ្ញុំជាប្រជាជនថ្មី ។ បបរអង្ករមួយកំប៉ុងហូបគ្នា៣០នាក់ ចំណែកអ្នកមូលដ្ឋានអាចលួចដាំបាយចែកគ្នាហូបនៅពេលយប់បាន ហើយមិនដែលមានបញ្ហាអ្វីធំដុំទេ ។ ប្រជាជនថ្មីគ្រាន់តែដកដំឡូងយកមកស្ងោរ អង្គការតាមទាន់សម្លាប់ចោលភ្លាម ។ មានពេលមួយបងស្រីខ្ញុំឈ្មោះ សាលី បានយកមងមកឲ្យខ្ញុំដាក់ត្រីដើម្បីយកទៅដូរយកអង្ករហូប ។ ពេលខ្ញុំស្រង់ត្រី ឡើងពីទឹកកូនអ្នកមូលដ្ឋាន មកដណ្តើមត្រីពីដៃខ្ញុំ ។ វាថាមងនេះជារបស់វា ហើយត្រីនេះក៏ជារបស់វាដែរ ។ វាបានយកផ្តៅមកវាយត្រូវភ្នែកខ្ញុំឡើងក្រហមជាំ ។

ក្នុងរបប៣ឆ្នាំ៨ខែ ខ្ញុំស្ទើរតែស្លាប់ស្ទើររស់ ។ ខ្ញុំឈឺជាញឹក

ញាប់ ប៉ុន្តែដោយសារខ្ញុំខ្លាចម្ជុលចាក់ថ្នាំ ខ្ញុំចេះតែទ្រាំទៅធ្វើការទាំងឈឺ ។ អង្គការចាត់តាំងឲ្យខ្ញុំដឹកប្រឡាយនៅឆ្ងាយពីផ្ទះ ។ ខ្ញុំលីចបមិនរួចទេ ព្រោះខ្ញុំបាក់កម្លាំង ។ ពេលខ្លះខ្ញុំដូរបាយជាមួយកូនៗមិត្តភក្តិប៉ាខ្ញុំ ដើម្បីឲ្យអ្នកទាំងនោះ ជួយធ្វើការងារជំនួសខ្ញុំ ។ ថ្ងៃមួយខ្ញុំឈឺធ្ងន់ ហើយដួលសន្លប់នៅការដ្ឋាន ។ ពេលខ្ញុំដឹងខ្លួនវិញប្រធានកងប្រាប់ទៅថ្នាក់លើថាត្រូវតែបញ្ជូនខ្ញុំទៅសមរភូមិក្រោយវិញ ព្រោះខ្ញុំមិនដែលឈឺទេពីមុនមក ។ អ្នកទាំងនោះដឹកខ្ញុំមកភូមិ ។ ខ្ញុំមិនបានជួបម៉ាក់ខ្ញុំទេ ប្រជាជននៅទីនោះនិយាយថា ម៉ាក់ខ្ញុំឈឺ ។ តាមការពិតម៉ាក់ខ្ញុំនិងបងប្រុស ស្រី សៅរិទ្ធី ព្រមទាំងក្មួយខ្ញុំម្នាក់ទៀត បាត់ដំណឹងយូរណាស់មកហើយ ។

រូបខាងក្រោមនេះគឺជារូបថតក្រុមគ្រួសាររបស់ខ្ញុំ ។ យើងថតក្នុងពិធីរៀបការបងស្រីទី២ឈ្មោះ ស្រី ពុធសាលី ។ បងសាលីអតីតជាសិស្សនៅទីក្រុងភ្នំពេញ ។ បងសាលី ត្រូវអង្គការជម្លៀសទៅស្រុកបាកាន ខេត្តពោធិសាត់ ។ គាត់រស់នៅក្នុងកងចល័តមេម៉ាយ ប៉ុន្តែតាមរយៈអ្នកដែលរស់នៅក្នុងកងជាមួយគាត់បានប្រាប់ខ្ញុំថាអង្គការយកគាត់ទៅសម្លាប់ចោលនៅចុងឆ្នាំ១៩៧៨ ។ មុនពេល គាត់ស្លាប់ខ្មែរក្រហមសួរគាត់ថា បើប៉ានៅរស់ តើគាត់ចង់ទៅជាមួយប៉ាឬនៅជាមួយអង្គការ ។ ខ្ញុំមិនដឹងថាបងខ្ញុំឆ្លើយយ៉ាងម៉េចទេ ប៉ុន្តែអ្នកនៅទីនោះប្រាប់ខ្ញុំថាអង្គការយកគាត់ទៅហើយ ។ បងខ្ញុំបានឲ្យមាសសន្ទឹកដែលនៅជាប់នឹងខ្លួនទៅកម្មាភិបាលខ្មែរក្រហមដើម្បីជាថ្នូរនិងការរស់រានមានជីវិត ប៉ុន្តែគាត់នៅតែស្លាប់ ។ ប្តីរបស់គាត់ឈ្មោះ មី ប៉េងគា អតីតអ្នកបើកយន្តហោះពាក់ស័ក្តិ៣ ។ នៅមុនឆ្នាំ១៩៧៥ ប៉ាខ្ញុំបានបញ្ជូនគាត់ឲ្យទៅរៀនបើកយន្តហោះនៅប្រទេសថៃ ។ ពេលដែលខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុង គាត់មិនទាន់រៀនចប់នៅឡើយទេ ។ សព្វថ្ងៃគាត់កំពុងរស់នៅប្រទេសអាមេរិក ។

បងស្រីទី៣ឈ្មោះ ស្រី ពុធសាវឌី ត្រូវប៉ាម៉ាក់ខ្ញុំបញ្ជូនទៅរៀននៅប្រទេសបារាំងតាំងពីឆ្នាំ១៩៧៣ ។ គាត់បានយករូបថតទាំងនេះទៅតាមខ្លួន ។ ក្រោយពីរបបខ្មែរក្រហមដួលរលំគាត់បានផ្ញើរូបទាំងនេះត្រឡប់មកឲ្យខ្ញុំរក្សាទុក ។ បងស្រីទី៤ ឈ្មោះ ស្រី



រូបថតរៀបការកូនស្រីរបស់ ស្រី យ៉ាំ ក្នុងរបប លន់ នល់ (១៩៧០-១៩៧៥)

*ហោះស៊ីឡែន ។ ក្រោយពេលអង្គការចាប់បងសាលី អង្គការបានសួរបងឡែន ថាតើបងខ្ញុំចង់ទៅតាមឪពុកម្តាយទេ? បងខ្ញុំឆ្លើយថា ខំកសាងខ្លួនជាមួយអង្គការ៤-៥ឆ្នាំហើយគាត់សុខចិត្តនៅជាមួយអង្គការ ។ បងខ្ញុំក៏មានជីវិតរស់ ហើយសព្វថ្ងៃនៅប្រទេសបារាំង ។*

*បងប្រុស ស្រី សៃណាទិត្យ ។ មុនឆ្នាំ១៩៧៥ គាត់ជាអតីតជាសិស្សនៅសាលាប៉ាវណ្ណា នៅតាមផ្លូវកម្ពុជាក្រោម ។ នៅក្នុងជំនាន់នោះអត់មានឡាមកោរពុកមាត់ទេ ។ ពុកមាត់គាត់ដុះឡើងស្រមូម ហើយមុខមាត់គាត់ស្រដៀងនឹងតួកុនឈ្មោះ ពេជ្រ សាលឿន ។ ក្រោយមកអង្គការយក បងសៃណាទិត្យ ទៅសម្លាប់ចោលដោយចោទថា គាត់ឈ្មោះ ពេជ្រ សាលឿន ពាក់សក្តិ៣ ។*

*រហូតមកដល់ពេលនេះ ខ្ញុំនៅតែមិនអាចបំភ្លេចប៉ាម៉ាក់និងបងប្អូនដែលស្លាប់នៅក្នុងរបបខ្មែរក្រហម ។ ខ្ញុំធំដឹងក្តីនៅក្នុងរបបខ្មែរក្រហម ។ ដូច្នេះខ្ញុំមិនបានទទួលការអប់រំឲ្យបានជិតដល់ពីប៉ាម៉ាក់ខ្ញុំឡើយ ។ អ្វីដែលគាត់បន្សល់ទុកឲ្យខ្ញុំរហូតមកដល់សព្វថ្ងៃនេះគឺចំណេះដឹងនិងការតស៊ូព្យាយាម ។* ◆◆◆

## អែ ង៉ា ហៅ ទ្រី
## អតីតប្រធានផ្នែកអាហារដ្ឋាននៅសណ្ឋាគារសុខា

*កែវ ម៉ារ៉េត បានបង្ហាញរូបថតប្តីរបស់គាត់ឈ្មោះ អែ ង៉ា ហៅ ទ្រី ដែលថតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ ។ រូបថតនេះប្តីរបស់គាត់ ថតនៅពេលទទួលមេដាយក្នុងការសម្រេចលទ្ធផលការងារបានល្អ ។ ពិធីទទួលមេដាយប្រារព្ធនៅទីក្រុងភ្នំពេញ ។ នៅក្នុងពិធីនោះ ប្តីរបស់គាត់ស្លៀកសម្លៀកបំពាក់ចងក្បិនពណ៌លឿងទុំ និងពាក់អាវពណ៌ស ។ ម៉ារ៉េត បានយករូបថតនោះទៅដាក់ស៊ីម ។ ពេលម្តាយរបស់ ម៉ារ៉េត មកលេង គាត់បានឲ្យរូបថតនេះទៅម្តាយរបស់គាត់យកទៅស្រុកកំណើតនៅឯខេត្តកំពង់ចាម ។ ម៉ារ៉េត បានឃើញរូបថតនេះឡើងវិញនៅឆ្នាំ១៩៧៩ ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ កែវ ម៉ារ៉េត÷*

*ខ្ញុំនិងប្តីរបស់ខ្ញុំជាបងប្អូនជីទួតមួយរស់នៅក្នុងភូមិតែមួយ ។ គាត់គឺជាមនុស្សល្អ ស្លូតបូត ហើយខស្បាហ៍ក្នុងកិច្ចការងារណាស់ ។ យើងស្គាល់គ្នាតាំងពីនៅតូចៗ ។ នៅពេលធំដឹងក្តីឡើងឪពុកម្តាយទាំងសងខាងបានផ្សំផ្គុំឲ្យជាប្តីប្រពន្ធ ។ ពេលនោះការសម្រេចចិត្តរៀបការរបស់ខ្ញុំគឺតាមការរៀបចំរបស់ឪពុកម្តាយ ។ មុនពេលយើងរៀបការគាត់ធ្វើការផ្នែកបុគ្គលិកសណ្ឋាគារនៅទីក្រុងកំពង់សោម ចំណែកខ្ញុំរស់នៅខេត្តកំពង់ចាម ប្រកបរបរត្បាញហូល ធ្វើស្រែចម្ការជាមួយឪពុកម្តាយរបស់ខ្ញុំ ។ ខ្ញុំរៀនបានតែថ្នាក់ទី៧ចាស់ទេ ។ ខ្ញុំរៀបការនៅអាយុ១៨ឆ្នាំ ចំណែកប្តីរបស់ខ្ញុំអាយុ២៥ឆ្នាំ ។ ក្រោយពេលរៀបការហើយ ខ្ញុំបានទៅរស់នៅទីក្រុងកំពង់សោមជាមួយគាត់ ។*

*នៅឆ្នាំ១៩៧០ ប្តីខ្ញុំរបស់ខ្ញុំបានឡើងឋានៈជាប្រធានផ្នែកភោជនីយដ្ឋាន ។ ជីវភាពក្រុមគ្រួសារខ្ញុំបានល្អប្រសើរណាស់ ។ កាលណោះប្តីរបស់ខ្ញុំបានទទួលប្រាក់ទ្រទ្រង់សុខភាពទៀតផង ពីព្រោះនៅទីនោះគឺជាតំបន់ដែលសំបូរទៅដោយជំងឺគ្រុនចាញ់ ។*

*នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំឮប្រជាជននៅទីនោះថា ប្រទេសទទួលបានសន្តិភាពហើយ ។ ខ្ញុំមានចិត្តត្រេកអរណាស់ព្រោះខ្ញុំនឹងទៅជួបឪពុកម្តាយរបស់ខ្ញុំដែលបែកគ្នាតាំងពីឆ្នាំ១៩៧០មកម្ល៉េះ ពីព្រោះតាំងពីនោះមកខ្ញុំមិនអាចទាក់ទងទៅក្រុមគ្រួសារខ្ញុំនៅឯខេត្តកំពង់ចាមទេ ។ នៅថ្ងៃទី១៧ ប្តីរបស់ខ្ញុំជិះរ៉ឺស្ប៉ាទៅទិញថ្នាំនៅផ្សារ ទីផ្សារនិងហាងលក់ទំនិញទាំងអស់ត្រូវបានបិទទ្វារចំណែកលុយក៏ឈប់ចាយ ។ កងទ័ពអាវខ្មៅដកហូតយកម៉ូតូប្តីរបស់ខ្ញុំដោយឲ្យដើរត្រឡប់មកផ្ទះវិញ ។ ប្រជាជននៅទីក្រុងកំពង់សោម ត្រូវបានជម្លៀសចេញតាំងពីថ្ងៃទី១៧ ជាបន្តបន្ទាប់រហូត ។ កងទ័ពអាវខ្មៅប្រកាសថាឲ្យចេញពីផ្ទះដើម្បីទៅជួបឪពុកម្តាយ និងដើម្បីរៀបចំទីក្រុងសាជាថ្មី ។ ខ្ញុំជឿលើការឃោសនារបស់អ្នកទាំងនោះ ក្រុមគ្រួសារខ្ញុំចេញពីផ្ទះនៅថ្ងៃទី២៤ ពីព្រោះនៅមើលខុសត្រូវសណ្ឋាគារសិន រហូតដល់ភ្ញៀវចេញអស់ ។ ភ្ញៀវដែលមកស្នាក់នៅភាគច្រើនគឺជាអ្នកដែលមានតួនាទីធំៗ និងជនជាតិផ្សេងៗដូចជា ចិន បារាំង និងអាមេរិកាំង ។ ពេលខ្ញុំជម្លៀសចេញទៅខ្ញុំយកបានរបស់របរហូបចុកបន្តិចបន្តួចដែលមាននៅក្នុងផ្ទះទុកគ្រាន់ហូបនៅតាមផ្លូវ ។*

*ថ្ងៃដែលខ្ញុំចេញពីសណ្ឋាគារ នៅតាមផ្លូវមានសភាពស្ងាត់មិនអ៊ូអរដូចកាលពីថ្ងៃជម្លៀសដំបូងទេ ។ មានតែគ្រួសារខ្ញុំ និងគ្រួសារអ្នកដែលធ្វើការនៅក្នុងសណ្ឋាគារប៉ុន្មានគ្រួសារប៉ុណ្ណោះដែលចេញជាមួយគ្នានៅថ្ងៃនោះ ។ យើងមានបំណងធ្វើដំណើរ*

ទៅស្រុកកំណើត ប៉ុន្តែអង្គការជម្លៀសក្រុមគ្រួសារខ្ញុំទៅព្រៃទប់ ។ នៅទីនោះអង្គការចាត់តាំងឲ្យយើងរស់នៅតាមកងជាមួយប្រជាជនជម្លៀសផ្សេងទៀត ក្រោមការមើលខុសត្រូវរបស់ប្រជាជនមូលដ្ឋាន ។ ប្តីខ្ញុំចូលព្រៃកាប់ឈើធ្វើខ្ទម ។ ចំណែកខ្ញុំក្រងស្បូវដើម្បីប្រក់ដំបូលផ្ទះ ។ រយៈពេល១សប្តាហ៍ យើងបោះតង់ដើម្បីនៅជាបណ្តោះអាសន្នសិនទម្រាំតែសង់ខ្ទមរួច ។

នៅទីនោះអង្គការបានសួរនាំអំពីប្រវត្តិរូបរបស់យើង ។ ខ្ញុំប្រាប់ថា ប្តីរបស់ខ្ញុំជាអ្នកលក់ទឹកកកឈូស ចំណែកខ្ញុំជួយលក់ទឹកកកគាត់និងលក់បារីនៅក្បែរនោះ ។ ខ្ញុំមិនដឹងថាអង្គការជឿឬមិនជឿទេ ប៉ុន្តែខ្ញុំនៅតែនិយាយកុហក ។ អង្គការចែករបបអង្ករឲ្យម្នាក់មួយកំប៉ុងក្នុងមួយថ្ងៃ ។ ខ្ញុំមានកូន៥នាក់ រួមទាំងខ្ញុំនិងប្តីផង យើងទទួលបាន៧កំប៉ុងក្នុងមួយថ្ងៃ ។ យើងបានហូបគ្រប់គ្រាន់ដែរ ដោយមានត្រី សាច់ បន្លែផ្សេងៗធ្វើជាម្ហូប ។ ក្នុងមួយសប្តាហ៍អង្គការអនុញ្ញាតឲ្យប្រជាជនទៅរកត្រីម្តង ។ ខ្ញុំជាកូនអ្នកចម្ការ ។ ខ្ញុំចេះធ្វើតែចម្ការមិនចេះធ្វើស្រែទេ ។ មិត្តភក្តិប្តីខ្ញុំម្នាក់មកពីខេត្តបាត់ដំបងបានជួយបង្រៀនខ្ញុំស្ទូងស្រូវដោយចាក់ដីខ្សាច់នៅមុខផ្ទះហើយឲ្យខ្ញុំអនុវត្តផ្ទាល់នៅលើដីខ្សាច់នោះ ។ ប្តីរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យកាប់ដើមខ្លុងនៅក្នុងព្រៃ ចំណែកខ្ញុំស្ទូងស្រូវនៅក្នុងកងនារី ។


អៃ ភ៊ា ក្នុងឆ្នាំ១៩៦០

អង្គការចាត់តាំងយើងឲ្យធ្វើការងារជាច្រើនទៀត ។ ថ្ងៃមួយប្តីខ្ញុំមានជំងឺគ្រុនចាញ់ ហើយគ្មានថ្នាំព្យាបាល គឺមានតែថ្នាំបុកខ្មៅៗនិងថ្នាំដែលមានដបពណ៌ទឹកក្រូចយកមកចាក់ប៉ុណ្ណោះ ។ ពេលប្តីខ្ញុំឈឺគ្មានអ្នកណាទៅរកត្រីឲ្យហូបទេ ។ ខ្ញុំទៅជំនួសគាត់ ។ ខ្ញុំមិនដែលធ្វើការងារនេះពីមុនមកទេ ។ ខ្ញុំទៅរកត្រីតែម្នាក់ឯងខ្ញុំខ្លាចណាស់ ។

នៅរដូវស្រូវទុំ អង្គការចាត់តាំងឲ្យក្រុមគ្រួសារខ្ញុំនិងប្រជាជនជម្លៀសប្រមាណ៨គ្រួសារទៀតទៅជួយធ្វើស្រែនៅភូមិថ្មី ។ យើងធ្វើដំណើរនៅពាក់កណ្តាលយប់ ។ យើងចេះតែឆ្ងល់ថាភូមិថ្មីនៅទីណា ហើយលួចសួរគ្នាទៅវិញទៅមកប៉ុន្តែគ្មានអ្នកណាដឹងទេ ។ ឡានបានទៅដល់ស្រែអំបិល ។ យើងនៅទីនោះបានតែមួយថ្ងៃ អង្គការចាត់តាំងឲ្យទៅធ្វើដំណើរតាមកាណូតទៅដល់ភូមិចម្ការក្រោម ឃុំដងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ។ ប្រជាជននៅទីនោះនិយាយរដឹនៗ ។ ខ្ញុំស្តាប់មិនសូវបានទេ ។ ពេលណាយើងនិយាយជាមួយគេម្តងៗ យើងត្រូវយកចិត្តទុកដាក់ស្តាប់ ទើបគាត់ន័យយល់ ។ ខ្ញុំរស់នៅជាមួយតាយាយអ្នកមូលដ្ឋាន ។ គាត់ទាំងពីរចិត្តល្អណាស់ ។ ពេលទៅដល់គាត់បុកអង្ករហើយដាំបាយដំណើបឲ្យយើងហូបទាំងយប់ ។ ក្រោយមកទើបអង្គការឲ្យកូនខ្ទមតូចមួយរស់នៅ ហើយអង្គការឲ្យយើងហូបនៅតាមកង ។

ទៅដល់ទីនោះខ្ញុំធ្វើស្រែជាមួយអ្នកមូលដ្ឋាន ។ នៅក្នុងស្រែសម្បូរឈ្លើងណាស់ ។ ប្តីរបស់ខ្ញុំប្រាប់ខ្ញុំថា បើឈ្លើងទាមកុំស្រែកបើហ៊ានស្រែកអង្គការពិតជាយកទៅកសាងហើយ ។ ពេលមានឈ្លើងទាមក្មេងស្រីម្នាក់នៅក្បែរខ្ញុំ ជួយបេះឈ្លើងចេញឲ្យខ្ញុំ ។ ដល់ពេលឈ្លើងទាមច្រើនពេកធ្វើឲ្យស៊ាំនិងឈ្លើងអត់សូវខ្លាចដូចពីមុនទេ ។ ប្តីរបស់ខ្ញុំភ្ជួរស្រែ ។ មានពេលមួយអង្គការបានហៅប្តីរបស់ខ្ញុំទៅលត់ដំនៅជើងគោអស់រយៈពេល៣ខែ ។ ខ្ញុំយល់ថា លត់ដំគឺយកគាត់ទៅធ្វើទារុណកម្មឬធ្វើការងារធ្ងន់ហើយ ។ ក្នុងរយៈពេលលត់ដំ បើអ្នកណាអាចតស៊ូបានអ្នកនោះអាចមានជីវិតនៅរស់បើអ្នកណាតស៊ូមិនបាននឹងត្រូវស្លាប់ ។ ពេលប្តីខ្ញុំទៅលត់ដំអង្គការចាត់តាំងខ្ញុំជួយរកបន្លែឲ្យចុងភៅ ។ ខ្ញុំទៅដកព្រលឹតមានឈ្លើងទាមខ្ញុំច្រើនណាស់ ពីព្រោះខ្ញុំទៅដកនៅក្នុងបឹង ហើយបឹងនោះមានដើមស្មាច់ ។ ខ្ញុំចេះតែរង់ចាំមើលប្តីរបស់ខ្ញុំត្រឡប់មកវិញ ។ ពេលខ្ញុំត្រឡប់ពីរកបន្លែវិញ អ្នកភូមិបានប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំត្រឡប់មកវិញហើយ ។ គ្រាន់តែខ្ញុំក្រឡេកឃើញគាត់នៅក្នុងផ្ទះបាយ ខ្ញុំទន់ជង្គង់ដួលប្រួស ។ ខ្ញុំមើលប្តីខ្ញុំស្ទើរតែមិនស្គាល់ ។ គាត់ស្គម ហើយក្បាលជង្គង់ធំប៉ុនក្បាល ។ ពេលប្តីខ្ញុំមកដល់ភូមិវិញ អង្គការឲ្យគាត់ហូបបាយរឹង ។ ក្រពះរបស់គាត់ទទួលមិនបានទេ ព្រោះគាត់ធ្លាប់ហូបតែបបររាវ ។ គាត់ធ្លាក់ខ្លួនឈឺជាទម្ងន់ ។ ខ្ញុំស្វែងរកថ្នាំដើម្បីព្យាបាលគាត់រហូតជាសះស្បើយ ។

ប្តីរបស់ខ្ញុំចេះតែលួចខ្សឹបប្រាប់ខ្ញុំថា ពេលដែលគាត់មិននៅត្រូវចេះកាត់ចិត្ត ហើយប្រឹងប្រែងធ្វើការងារ ។ ពេលដែលគាត់ទៅលត់ដំគាត់ដឹងសភាពការណ៍នៅខាងក្រៅថាពិបាកណាស់ ។

កូនៗរបស់ខ្ញុំ៥នាក់ ត្រូវអង្គការឲ្យរស់នៅនឹងធ្វើការបែកគ្នាទាំងអស់ ។ កូនរបស់ខ្ញុំធ្លាប់តែរស់នៅមានឪពុកម្ដាយរៀបចំបាយទឹកឲ្យ ។ ដល់វាទៅរស់នៅក្នុងកងកុមារគ្មានអ្នកណារៀបចំឲ្យវាទេ ។ វាត្រូវស្វែងរកស៊ីចុកដោយខ្លួនឯង ។ កូនរបស់ខ្ញុំចេះតែរត់មកផ្ទះប្រធានកងតែងមកតាមត្រឡប់ទៅវិញ ហើយស្ដីឲ្យខ្ញុំថាមិនចេះប្រដៅកូនចេះតែនាំឲ្យកូនត្រឡប់មកផ្ទះ ។ ដោយវាចេះតែរត់មកផ្ទះច្រើនដងពេកប្ដីរបស់ខ្ញុំបាននាំវាត្រឡប់ទៅកងវិញដោយខ្លួនឯង ។ យើងរស់នៅទីនោះដោយលំបាកវេទនាណាស់ ។ យើងមានតែខោអាវម្នាក់មួយកំប្លេសម្រាប់ផ្លាស់ប្ដូរប៉ុណ្ណោះ ។ យើងគ្មានមុងទេ គឺមានតែភួយមួយសម្រាប់ដណ្ដប់កុំឲ្យមូសខាំ ។ យើងអត់មានអាហារហូបគ្រប់គ្រាន់ទេ មានតែបបររាវលាយជាមួយព្រលឹតនិងដើមចេក ។ អង្គការប្រកាសថាឲ្យយើងដាំបន្លែហូបខ្លួនឯង ។ បើយើងដាំបានច្រើន យើងក៏ទទួលបានផលហូបចុកច្រើនដែរ ។ ពេលដែលយើងដាំដំឡូងបានផលច្រើនអង្គការប្រកាសវិញថា អ្នកដែលមានដំឡូងត្រូវយកផលទាំងនោះមកទុកហូបសមូហភាព មិនអាចទុកហូបឯកជនបានទេ ។ មុនពេលកូនខ្ញុំចេញទៅធ្វើការម្ដងៗ កូនខ្ញុំតែងយំទារហូបដំឡូងជានិច្ច ។ ខ្ញុំមិនដែលហ៊ានដកយកទៅស្ងោរឲ្យកូនខ្ញុំហូបទេព្រោះខ្លាចអង្គការយកទៅសម្លាប់ចោល ។

មានពេលមួយ ប្ដីខ្ញុំត្រឡប់មកពីស្រែវិញ ទាំងហេវហត់អស់កម្លាំង ។ គាត់បានដកដំឡូងពគុម្ពដែលដាំនៅក្បែរជណ្ដើរផ្ទះយកទៅស្ងោរហូប ។ ពេលដែលខ្ញុំត្រឡប់មកពីស្ទូងវិញហៀបនឹងដូតទឹក គាត់ស្រែកឲ្យកូនខ្ញុំយកដំឡូងមកឲ្យខ្ញុំហូប ។ ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង សួរទៅគាត់ថា “ឪអារីបានដំឡូងមកពីណា?” គាត់ឆ្លើយថា គាត់គាស់នៅក្បែរជណ្ដើរផ្ទះ ដោយសារគាត់ឃ្លានខ្លាំងពេក ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំមិនដែលហ៊ានប៉ះពាល់ទេតាំងពីអង្គការប្រកាសមក ។ ទោះបីជាកូនយំឃ្លានយ៉ាងណាក៏ខ្ញុំមិនដែលយកមកឲ្យកូនហូបដែរ ។ ប្ដីខ្ញុំនិយាយថា បើអង្គការដឹងគ្រាន់តែយកយើងទៅកសាងប៉ុណ្ណោះ ព្រោះរបស់នោះយើងដាំដោយខ្លួនឯង ។ នៅពេលគាត់កំពុងស្ងោរដំឡូង ឈ្លបពីរនាក់បានមកឃើញ ហើយសួរគាត់ថា កំពុងធ្វើអ្វី? ប្ដីខ្ញុំឆ្លើយថា កំពុងដាំទឹក ។ ពេលនោះកន្លែងដីដែលគាត់ដកដំឡូងមានភាពខុសពីប្រក្រតី ។ ឈ្លបទាំងពីរនាក់នោះមានការសង្ស័យ ។ នៅវេលាម៉ោង១២យប់ ឈ្លបពីរនាក់បានមកស្រែកហៅគាត់ពីក្រោមផ្ទះឲ្យទៅជួយចាប់ក្របីដែលកំពុងស៊ីសំណាប ។ គ្រាន់តែឮដូច្នោះ ប្ដីខ្ញុំស្ទុះក្រោកឡើង ហើយអង្គុយចុះវិញភ្លាម ។ ខ្ញុំប្រាប់គាត់ថា ប្រញាប់ទៅកុំឲ្យបងមេកងគាត់ចាំនៅខាងក្រោមផ្ទះយូរ ។ គាត់យកបានតែក្រមាមួយប៉ុណ្ណោះ ។ គាត់ភ្លេចយកកញ្ចប់បារីគាត់ទៅ ។ ខ្ញុំមានកូនតូចៗ២នាក់នៅជាមួយខ្ញុំ ។ កូនមួយកំពុងបៅដោះខ្ញុំនិងមួយទៀតទារទៅតាមប៉ាវា ។ ប្ដីខ្ញុំនិយាយថា គាត់ទៅចាប់ក្របីតែមួយភ្លែតទេនឹងត្រឡប់មកវិញហើយ ។ ខ្ញុំទុកកូនចោល ហើយស្ទុះទៅមើលប្ដីខ្ញុំឃើញប្រធានឈ្លបដើរនៅខាងមុខ គាត់ដើរនៅកណ្ដាល ចំណែកឈ្លបពីរនាក់ដើរនៅពីក្រោយប្ដីរបស់ខ្ញុំ ។ កូនខ្ញុំយំទ្រហឹងពេញផ្ទះ ។ នៅយប់នោះនៅក្នុងភូមិរបស់ខ្ញុំ ឈ្លបហៅមនុស្ស៣នាក់ ម្នាក់ជាប្ដីរបស់ខ្ញុំ ម្នាក់ទៀតធ្វើគយ និងម្នាក់ទៀត ធ្វើការនៅសាលាក្រុងកំពង់សោម ។

ពេលដែលឈ្លបហៅប្ដីខ្ញុំទៅ ខ្ញុំមិនហ៊ានយំទេ ។ ស្អែកឡើងខ្ញុំទៅស្ទូង ប្រពន្ធរបស់បុរសដែលធ្វើការនៅសាលាក្រុងកំពង់សោមនិងដែលត្រូវហៅទៅជាមួយប្ដីខ្ញុំពីយប់មិញចេះតែសម្លឹងមើលមុខខ្ញុំ ហើយព្យាយាមមកជិតសួរខ្ញុំថា តើប្ដីរបស់ខ្ញុំទៅណា? ខ្ញុំប្រាប់ថា អង្គការហៅប្ដីខ្ញុំទៅចាប់ក្របីតាំងពីយប់មិនឃើញត្រឡប់មកវិញទេ ។ នារីនោះនិយាយថា ប្ដីវាក៏មិនដឹងយ៉ាងម៉េចដែរ ។ យើងក៏បែកគ្នា មិនហ៊ាននៅជជែកគ្នាយូរទេ ។ តាំងពីអង្គការយកប្ដីខ្ញុំទៅរបបហូបចុកត្រូវបានកាត់បន្ថយ បាយមួយចានហូបគ្នា៤នាក់ ។ ខ្ញុំចង់លួចលាក់ទុកផ្ញើកូននៅផ្ទះដែរ ប៉ុន្តែខ្ញុំមិនហ៊ាន ។ កូនរបស់ខ្ញុំស្គមនៅសល់តែស្បែកនិងឆ្អឹង ។ កូនទី៤ខ្ញុំឈ្មោះ សុរីវ៉ា ស្លាប់ដោយសារអត់អាហារ ហើយវាកើតពិស ។ អ្នកជិតខាង បានជួយរកថ្នាំមកព្យាបាលដែរ ប៉ុន្តែនៅតែមិនជា ។ ខ្ញុំយកវាទៅមន្ទីរពេទ្យទៅសុំទឹកដោះគោពីពេទ្យដើម្បីឲ្យកូនខ្ញុំផឹកមានកម្លាំង បន្តិចប៉ុន្តែពេទ្យថាអស់ហើយ ហើយឲ្យខ្ញុំទៅរកទឹកបាយឲ្យកូនខ្ញុំផឹកជំនួសវិញ ។ ពេលខ្ញុំទៅដល់រោងបាយ ខ្ញុំដួលសន្លប់បាត់ស្មារតី ហើយបានអ្នកនៅរោងបាយជួយយកអាសាខ្ញុំ ។ ពេលខ្ញុំដឹងខ្លួនមកវិញ ខ្ញុំយកទឹកបាយមកឲ្យកូនខ្ញុំ ប៉ុន្តែកូនខ្ញុំលែងដឹងខ្លួនទៅហើយ ។ ចំណែកកូនមួយទៀតឈឺជំងឺអុតស្វាយ

នៅកងកុមារ ។ ខ្ញុំប្រញាប់ត្រឡប់ទៅមើលវា ។ វាផ្តាំប្រាប់ខ្ញុំថាកុំទៅណាចោលវា ។

ចំណែកកូនខ្ញុំ២នាក់ទៀត ដែលនៅឆ្ងាយពីខ្ញុំត្រូវកូនអ្នកមូលដ្ឋានជេរដៀលថាជាកូន"ក្បត់" ។ កូនខ្ញុំរត់ពីកងមកផ្ទះសួរខ្ញុំថា "តើហេតុអ្វីបានជាចោទថាឪខ្ញុំក្បត់" ។ ខ្ញុំអួលណែនក្នុងទ្រូងយំមិនចេញ ខ្ញុំយកក្រមាបិទមាត់កូនមិនឲ្យវាយំ ។ អង្គការឮយើងយំប្រាកដជាស្លាប់អស់មួយពូជហើយ ។ ខ្ញុំចេះតែលួងលោមកូនខ្ញុំថា ប៉ាមិនក្បត់ទេ ។ ខ្ញុំមានបារី២កញ្ចប់ ខ្ញុំបានឲ្យបារីនោះទៅឲ្យពូសុក ដែលនៅក្បែរផ្ទះដើម្បីស៊ើបសួរដំណឹងអំពីប្តីរបស់ខ្ញុំ ។ គាត់ប្រាប់ថាឃើញប្តីខ្ញុំនៅមន្ទីរសន្តិសុខហើយមានរូបរាងស្គម ។ ខ្ញុំមិនដឹងថាសម្តីដែល ពូសុក ជាការពិតឬមិនពិតទេ ។

ក្រោយមក ខ្មែរក្រហមហៅអ្នកដែលប្តីត្រូវអង្គការហៅទៅធ្វើការឲ្យទៅរស់នៅកន្លែងថ្មី ដែលហៅថាដីខ្វាញ់ ។ យើងធ្វើដំណើរចេញពីស្រែអំបិលដោយឡានកាំមីញ៉ុងមកខេត្តកំពង់ស្ពឺ ហើយបានមកដល់ទួលរកា ។ យើងបានហូបបាយម្តងជាមួយសម្លកកូរគ្រោត ។ ពេលដែលខ្ញុំហូបបាយ ខ្ញុំនឹកឃើញដល់កូនខ្ញុំដែលស្លាប់ដោយគ្មានអ្វីហូប ។ យើងដើរបន្ត៤គីឡូម៉ែត្រទៀតចូលទៅក្នុងភូមិ ។ ទៅដល់ទីនោះ អ្នកភូមិដាំបាយឲ្យយើងហូបម្តងទៀត ជាមួយសម្លម្ជូរស្លឹកអម្ពិលមានរសជាតិឆ្ងាញ់ណាស់ ។ យើងស្នាក់នៅជាមួយប្រជាជនមូលដ្ឋាន ។ កូនខ្ញុំដែលកើតអុតស្វាយឈឺកាន់តែធ្ងន់ឡើងៗ កូនស្រីរបស់ខ្ញុំម្នាក់ទៀត ក៏ធ្លាក់ខ្លួនឈឺដែរ ។ អង្គការឲ្យយកវាមកព្យាបាលនៅពេទ្យថ្នល់ទទឹង ។ ដោយព្យាបាលមិនជាអង្គការផ្លាស់វាទៅពេទ្យអង្គសេរី ហើយកូនស្រីខ្ញុំត្រូវស្លាប់នៅទីនោះ ។ ពេទ្យឃើញកូនខ្ញុំបើកភ្នែកនិយាយថាកូនខ្ញុំមិនអីទេ ហើយមិនព្រមព្យាបាលឲ្យទៀត ។ ក្រោយមកកូនខ្ញុំបញ្ឈរភ្នែកស្លាប់ ពេទ្យចោទខ្ញុំថាមិនព្រមប្រាប់ពេទ្យ ។ ខ្ញុំដើរត្រឡប់មកថ្នល់ទទឹងវិញ ហើយធ្វើការនៅក្នុងកងដាំបន្លែ ។ ខ្ញុំនៅសល់តែកូន ៣នាក់ទេ ។ កូន២នាក់ធ្វើការនៅកងកុមារ ចំណែកកូនម្នាក់ទៀតនៅជាមួយខ្ញុំ ។ ពេលយប់កូនខ្ញុំតែងតែលួចមកដេកជាមួយខ្ញុំជានិច្ច ។ ខ្ញុំផ្តាំផ្ញើកូនថា បើឮស្នូរកាំភ្លើងកុំរត់ទៅទិសខាងលិចត្រូវរត់មករកម្តាយ ។ នៅពេលឮស្នូរកាំភ្លើងកូនខ្ញុំ២នាក់រត់មករកខ្ញុំ ។ ខ្ញុំឲ្យកូនខ្ញុំចាំនៅឯផ្ទះចំណែកខ្ញុំយកកាមែលទៅយកគុយទាវទុកហូបតាមផ្លូវ ។ ពេលដែលខ្ញុំទៅយកគុយទាវ អង្គការដេញកូនខ្ញុំ២នាក់ចេញ ។ ខ្ញុំនៅសល់តែកូនមួយជាប់នឹងខ្លួន ។ ខ្ញុំត្រូវអង្គការដេញឡើងទៅលើភ្នំត្រពាំងល្វា ហើយបានជួបកូនទាំងពីរនាក់នៅទីនោះកំពុងយំឱបគ្នា ។ ប្រធានកងប្រធានសហករណ៍រត់បែកខ្ញែកគ្នាអស់ ។ ខ្ញុំរត់បកក្រោយមកភូមិដែលខ្ញុំនៅវិញដើម្បីយកស្រូវខ្លះទុកហូបតាមផ្លូវ ។ ខ្ញុំមានបំណងដេកនៅទីនោះមួយយប់ ប៉ុន្តែមានអ្នកដំណើរដូចគ្នាប្រាប់ថាកុំដេកនៅទីនោះអី ខ្មែរក្រហមនឹងត្រឡប់មកយកអាហារវិញ ហើយនឹងសម្លាប់យើងចោល ។ យើងធ្វើដំណើរមកដល់ភ្នំពេញ ស្នាក់នៅទឹកថ្លាបានមួយរយៈខ្លី ក៏ផ្លាស់ទៅរស់នៅពោងពាយ ហើយបានជួបអ្នកស្គាល់គ្នាបបួលមកផ្ទះវិញ ។

ខ្ញុំបានត្រឡប់ទៅរស់នៅទីក្រុងកំពង់សោម ព្រោះខ្ញុំមានដីធ្លីនៅទីនោះស្រាប់ ។ នៅឆ្នាំ១៩៨២ ខ្ញុំបានទៅមើលសណ្ឋាគារដែលប្តីខ្ញុំធ្វើការពីមុន ។ ខ្ញុំឃើញកន្លែងនោះបាក់បែក ធ្វើឲ្យខ្ញុំនឹកឃើញដល់ប្តីរបស់ខ្ញុំ ។ ខ្ញុំសោកស្តាយចំពោះការបាត់បង់ប្តីរបស់ខ្ញុំណាស់ ។ គាត់ស្លាប់ដោយសារតែដំឡូងស្ងោរ ។

ពេលដែលឃើញរូបថតនេះ ខ្ញុំមានអារម្មណ៍ថាឃើញតែរូបថត ប៉ុន្តែមនុស្សនៅក្នុងរូបថតអត់ឃើញមក ។ ក្រោយពេលត្រឡប់មកពីរបបខ្មែរក្រហមមកវិញ ខ្ញុំនៅមានសង្ឃឹមថាប្តីរបស់ខ្ញុំនៅរស់ ពីព្រោះខ្ញុំមិនបានឃើញខ្មែរក្រហមសម្លាប់ប្តីខ្ញុំដោយផ្ទាល់ ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ខ្ញុំគ្មានសង្ឃឹមថាគាត់នៅរស់ទេ ។ បើគាត់នៅរស់គាត់ពិតជាវិលត្រឡប់មករកប្រពន្ធ និងកូនវិញហើយ ។ ចាប់តាំងពីរៀបការហើយ ខ្ញុំរស់នៅជាមួយគាត់បានតែរយៈពេល១៣ឆ្នាំប៉ុណ្ណោះ គាត់ក៏បាត់ខ្លួនរហូត ។ កូនស្រីទី២របស់ខ្ញុំ យល់សប្តិឃើញប្តីខ្ញុំឲ្យធ្វើបុណ្យបញ្ជូនអាហារឲ្យគាត់ផង ។ ខ្ញុំក៏ធ្វើបុណ្យឧទ្ទិសកុសលទៅឲ្យគាត់ ហើយក៏ឈប់យល់សប្តិឃើញរហូត ។ ◆◆◆

## ទេព ស៊ុយអ៊ាង

*ជីវិតពិតឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យរបស់អ្នកស្រី ទេព ស៊ុយអ៊ាង បានលាតត្រដាងតាមរយៈស្នាដៃនិពន្ធ "បំភ្លេចមិនបាន" ដែលបានផ្ញើមកវេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីចូលរួមប្រឡង*

ប្រកួតប្រជែងស្នាដៃនិពន្ធ ។ ស៊ុយអៀង បានផ្ញើសាច់រឿងនេះដោយភ្ជាប់ជាមួយនូវរូបថតមួយចំនួន ។ រូបថតទីមួយគឺជារូបថតអាពាហ៍ពិពាហ៍របស់ ស៊ុយអ៊ាង ថតនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ១៩៧៣ ។ រូបថត ទីពីរជារូបថតស-ខ្មៅ (ស៊ុយអ៊ាងអង្គុយប្តីឈរ) ថតក្រោយរៀបការរួចប្រហែលមួយខែ គឺនៅពេលដែលប្តីប្រពន្ធគាត់ទៅចូលរួមពិធីមង្គលការរបស់លោក ឡៅ ឈើវហ៊ុន ។ រូបនេះថត នៅហាងថតរូប “លុច្សថ្មី” ។

ខាងក្រោមនេះគឺជាការរៀបរាប់របស់ ស៊ុយ អ៊ាង ៖

នៅពេលខ្មែរក្រហមជម្លៀសគ្រួសារខ្ញុំពីភ្នំពេញ ខ្ញុំបានប្រមូលខោអាវនិងរូបថតរៀបការមួយសៀវភៅដោយគិតថាត្រូវយកទៅបង្ហាញឪពុកម្តាយក្មេកនៅស្រុក ពីព្រោះពេលខ្ញុំរៀបការគ្មានវត្តមានគាត់ទាំងពីរទេ ព្រោះស្រុកស្អាងជាតំបន់ស្ថិតនៅក្រោមការគ្រួតត្រារបស់ខ្មែរក្រហមតាំងពីឆ្នាំ១៩៧៣មក ។ នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានយកលេសធ្វើការបោសសម្អាតក្នុងភូមិ ដោយបានចូលផ្ទះម្តាយក្មេកខ្ញុំនៅស្រុកស្អាង ហើយរកឃើញសៀវភៅរូបថតនិងលិខិតឆ្លងដែនមួយចំនួនរបស់បងប្រុសបងស្រីខ្ញុំ និងសម្លៀកបំពាក់ជាច្រើនទៀត ។


ទេព ស៊ុយអៀង និងស្វាមី នៅឆ្នាំ១៩៧៣

នៅខែកុម្ភៈឆ្នាំ១៩៧៩ ខ្ញុំបបួលប្អូនធម៌ខ្ញុំម្នាក់ឈ្មោះ ឆេងណៃ ទៅភ្នំពេញដើម្បីទៅមើលផ្ទះខ្ញុំ នៅមុំវត្តមហាមន្ត្រី ខ្ញុំដើរសង្កេតជុំវិញផ្ទះ ឃើញជញ្ជាំងជុំវិញផ្ទះឆេះរោលឡើងខ្មៅ ប្រហែលដោយសារភ្លើងឆេះនៅជុំវិញនោះ កាលពីសម័យសង្គ្រាម ។ អីវ៉ាន់នៅក្នុងផ្ទះនៅកន្លែងដដែល ប៉ុន្តែពួករហែកអស់សំឡី-គរាយពេញផ្ទះត្រឹមជង្គង់ ។ ខ្ញុំដើរចូលក្នុងបន្ទប់យកដំបងវែកសំឡី-គ ស្រាប់តែឃើញសៀវភៅរូបថតមួយក្បាលនៅលើឥដ្ឋ ។ ខ្ញុំយកវាមកបោសសម្អាតហើយកាន់ជាប់នឹងដៃ ។ ខ្ញុំគ្មានយកអ្វីបានក្រៅពីរូបថតអនុស្សាវរីយ៍កាលពីនៅរៀននិងរូបថតរៀបការមួយចំនួនដែលខ្ញុំរក្សាទុកមកដល់សព្វថ្ងៃនេះ ។

រូបថតទាំងអស់នេះរំឭកខ្ញុំអំពីរឿងរ៉ាវគ្រួសារខ្ញុំ ។

ឪពុកខ្ញុំឈ្មោះ ស៊ាម ស៊ីក ម្តាយខ្ញុំឈ្មោះ វ៉ាល់ កាក់គីម ។ ឪពុកខ្ញុំស្រឡាញ់ខ្ញុំណាស់ ប៉ុន្តែគាត់ក៏ស្រឡាញ់ទ្រព្យសម្បត្តិណាស់ដែរ ។ ពេលជម្លៀសចេញពីភ្នំពេញ ឪពុកខ្ញុំមិនព្រមចាកចេញទៅជាមួយម៉ែនិងកូនៗទេ ។ គាត់ចង់នៅចាំផ្ទះនិងទ្រព្យសម្បត្តិរបស់គាត់ ។ម្យ៉ាងទៀត គាត់ជឿតាមពាក្យឃោសនារបស់ខ្មែរក្រហមថា ប្រជាជនទាំងអស់ត្រូវជម្លៀសចេញតែបីថ្ងៃនឹងបានត្រឡប់ចូលទីក្រុងភ្នំពេញវិញហើយ ។ ដូច្នេះគាត់សុខចិត្តសម្ងំលាក់ខ្លួននៅក្នុងផ្ទះ លុះត្រាតែកងទ័ពខ្មែរ

ក្រហមឃើញចូលទៅដេញទើបគាត់ព្រមចេញ ។ ប៉េ (ខ្ញុំហៅឪពុកថា ប៉េ) មានជំងឺស្ពឹកជើងយូរមកហើយ គាត់ដើរមិនបានឆ្ងាយទេ ។ នេះក៏ជាមូលហេតុមួយដែលធ្វើឲ្យគាត់មិនព្រមចាកចេញពីផ្ទះដែរ ។ លុះពេលគាត់ចាកចេញពីក្រុងភ្នំពេញមកនៅឃុំត្រើយស្លាជាមួយម៉ែ ជំងឺជើងគាត់រើឡើងវិញរហូតដល់កើតជាដំបៅរលួយ ។ មានម្តងនោះដោយគាត់ឈឺចាប់ពេកគាត់សុំឲ្យខ្ញុំកាប់ជើងដំបៅនោះចោល ។ ដំបូងខ្ញុំមិនដាច់ចិត្តទេ ខ្ញុំប្រកែកដាច់អហង្ការថាមិនធ្វើទេខ្លាចមានកម្មពៀរ ។ ម៉ែក៏ជួយខ្ញុំបដិសេធនឹងសំណើនេះដែរ ប៉ុន្តែ ប៉េ នៅតែមិនព្រម គាត់អង្វរខ្ញុំហើយអង្វរទៀត ។ គាត់ប្រាប់ខ្ញុំថា ខ្ញុំជាកូនស្រីដែលមានចិត្តក្លាហាន កិច្ចការប៉ុណ្ណេះខ្ញុំប្រាកដជាហ៊ានធ្វើ ។ ទីបំផុត ខ្ញុំគ្មានផ្លូវជ្រើសរើស ខ្ញុំដាច់ចិត្តកាប់ជើងគាត់ត្រឹមកជើង ។ ម៉ែបន្ទោសប៉េខ្លាំងណាស់ គាត់ខ្លាចខ្ញុំមានកម្មពៀរ កូនក្នុងផ្ទៃកើតមកមិនគ្រប់លក្ខណៈពីព្រោះពេលនោះ ខ្ញុំកំពុងតែមានផ្ទៃពោះកូនទីពីរផង ។

កាលពីដើម ម៉ែប្រកបរបរដួញដូរក្រណាត់មុងអា ។ នៅពេលគ្រួសារយើងជម្លៀសទៅរស់នៅឃុំត្រើយស្លា យើងមានក្រណាត់នេះមួយចំនួនសម្រាប់ប្តូរជាអង្ករនិងម្ហូបអាហារជាមួយប្រជាជនចាស់ ។ ប៉េជាចៅកែស៊ីក្លូ នៅពេលខ្មែរក្រហមជម្លៀសចេញពីភ្នំពេញ យើងនៅសល់ស៊ីក្លូមួយចំនួនសម្រាប់ដឹកអីវ៉ាន់ដែលអាចជួយបន្ធូរកម្លាំង យើងបានច្រើន ។ កាលពីដំបូងគ្រួសារខ្ញុំនៅសល់របស់របរប្រើប្រាស់ជាច្រើនអាចដូរយកអង្ករហូបបានមួយរយៈ ។ ផ្ទុយទៅវិញ គ្រួសារខ្លះយកលុយទៅទាំងបាវៗ ប៉ុន្តែគ្មានទិញបានអ្វីសោះ ព្រោះលុយអស់តម្លៃ ។

ខ្ញុំជាកូនពៅក្នុងគ្រួសារ ។ ខ្ញុំមានបងប្អូនបីនាក់ ។ បងប្រុសច្បង ស៊ាម ស៊ុយគៀង និងបងស្រីបន្ទាប់ ស៊ាម អ៊ាងជន ។ កាលពីក្មេងខ្ញុំរៀននៅវិទ្យាល័យព្រះស៊ីសុវត្ថិ ។ ខ្ញុំស្រឡាញ់ការសិក្សាណាស់ ប៉ុន្តែឪពុកម្តាយខ្ញុំអង្វរឲ្យខ្ញុំរៀបការមុនបងស្រីនៅឆ្នាំ ១៩៧៣ ។ ដោយស្រឡាញ់ការសិក្សាពេក ខ្ញុំលួចទៅរៀនទាំងមានផ្ទៃពោះបីខែ រហូតដល់ពោះធំទើបខ្ញុំព្រមឈប់រៀន ។ ចំណែកបងស្រីខ្ញុំមិនព្រមរៀបការទេ គាត់រៀននៅមហាវិទ្យាល័យវិទ្យាសាស្ត្រ និងនៅសាលាគរុវិជ្ជាជាន់ខ្ពស់(អក្សរកាត់ *ENS Ecole Normal Supérieur*) ។ គាត់ខ្លាចប្រឡងធ្លាក់ ទើបឲ្យខ្ញុំរៀបការមុន ។ ក្រោយពីឈប់រៀន ខ្ញុំនៅផ្ទះជួយមើល ការងារឪពុកម្តាយខ្ញុំខ្លះ និងមើលការខុសត្រូវលើរបររកស៊ីជួលស៊ីក្លូដែលឪពុកម្តាយខ្ញុំចែកឲ្យ ។ ប្តីខ្ញុំឈ្មោះ ហុង គីមទ្រី ជាគិលានុបដ្ឋាកនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ក្រុងភ្នំពេញ ។ គាត់មានស្រុកកំណើតនៅឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។

ប្តីប្រពន្ធខ្ញុំឥតដែលស្គាល់គ្នាសោះពីមុនមក ។ តាំងពីថ្ងៃដែលចៅមហាចូលស្តីដណ្តឹងលើកជំនូនរួចមក ឪពុកម្តាយខ្ញុំអនុញ្ញាតឲ្យអនាគតកូនប្រសាចេញចូលបរិភោគបាយម្តងម្កាលដែរ ផ្ទុយទៅវិញខ្ញុំមិនសប្បាយចិត្តទេ ចេះតែរករឿងគេចមុខរហូត ។ ការគេចមុខនេះធ្វើឲ្យប្តីខ្ញុំសង្ស័យថាខ្ញុំប្រហែលជាមានសង្សារនៅសាលារៀន ។ មានពេលខ្លះគាត់តាមដានខ្ញុំដល់សាលាទៀតផង តាមការពិតមកពីខ្ញុំនៅក្មេងពេកមិនស្គាល់អ្វីជាសេចក្តីស្នេហា ហើយឪពុកម្តាយខ្ញុំអប់រំកូនស្រីវិន័យតឹងតែងណាស់ដឹងពេលម៉ោងកូនចេញពីសាលាបើហ៊ានយឺតម៉ោងតែបន្តិចម្តាយខ្ញុំនឹងតាមទៅដល់សាលាមិនខាន ។ រហូតដល់ថ្ងៃរៀបការក្នុងឆ្នាំ១៩៧៣ ពិធីរៀបការប្រព្រឹត្តឡើងតែមួយថ្ងៃគត់ ។ ពិធីរៀបការប្រព្រឹត្តទៅរហូតដល់ម៉ោង២០យប់និងមិនមានការប្រគុំតន្ត្រីរាំរែកពេលយប់ទេ ។ លុះដល់រាត្រីផ្សំដំណេកទើបយើងបានស្គាល់គ្នា សួរគ្នាទៅវិញទៅមកជាច្រើនធ្វើឲ្យយើងយល់ចិត្តគ្នា ។ កាលពីមុនរៀបការខ្ញុំធ្លាប់តែហៅគាត់ថា“លោកគ្រូពេទ្យ” ហើយគាត់ហៅខ្ញុំថា“អាអ៊ាង” ដល់ពេលរៀបការរួចយើងក៏ចាប់ ហៅគ្នាថា “អូន-បង” យ៉ាងផ្អែមត្រជាក់ ។ ក្រោយពីរៀបការរួចបានមួយឆ្នាំ ខ្ញុំឆ្លងទន្លេបានកូនប្រុសមួយសស្អាតមុខដូចប្តីខ្ញុំ ។ ខ្ញុំដាក់ឈ្មោះកូននេះថា ទេពភីរ៉ូ ។ សំណាងអាក្រក់ណាស់ ពេលដែលខ្ញុំទើបតែទៅរស់នៅឃុំត្រើយស្លា បានប្រហែលជា៣ខែ ភីរ៉ូ កើតកញ្ជ្រឹលរហូតដល់ស្លាប់ ។ ខ្ញុំនិងប្តីសោកស្តាយកូននេះខ្លាំងណាស់ ព្រោះជាកូនប្រុសដំបូង ហើយជាសំណព្វចិត្តតែមួយគត់របស់យើង ។

## ការជម្លៀស

ពេលជម្លៀសចេញពីក្រុងភ្នំពេញ គ្រួសារយើងបម្រុងនឹងធ្វើដំណើរសំដៅទៅឃុំទឹកវិល ស្រុកស្អាង ដែលជាស្រុកកំណើតរបស់ឪពុកម្តាយខ្ញុំ ប៉ុន្តែនៅតាមផ្លូវយើងបានទទួលដំណឹងថាឪពុកក្មេកខ្ញុំឈឺធ្ងន់ យើងក៏បង្វែរទិសដៅមកឃុំត្រើយស្លាស្រុកស្អាង

វិញ ។ ប្ដីខ្ញុំ ខ្ញុំនិងកូន រស់នៅភូមិ លេខ៧ឬភូមិព្រែកបាឡាត់ឆឹង ជាមួយម្ដាយក្មេកខ្ញុំ ។ រីឯម្ដាយបងស្រីប្រុសខ្ញុំរស់នៅភូមិលេខ៣ ឬភូមិព្រែកយូហ៊ីង ជាមួយគ្រួសារមាប្ដីខ្ញុំឈ្មោះ តិច ។ គាត់ចិត្តល្អណាស់ ជួយយកអាសាគ្រួសារខ្ញុំគ្រប់បែបយ៉ាង ។ ក្រោយមកម្ដងជាពីរដងយើងចង់ផ្លាស់ចេញពីឃុំត្រើយស្លាទៅរស់នៅភូមិណាដែលគ្មានអ្នកស្គាល់ ប៉ុន្តែមិនបានសម្រេចទាល់តែសោះ ។ បើយើងទៅរស់នៅកន្លែងឆ្ងាយគ្មានអ្នកស្គាល់យើងដែលជាប្រជាជនថ្មីអាចមានសង្ឃឹមរួចផុតពីការកាប់សម្លាប់ ។

ក្រោយពីយើងចាកចេញពីភ្នំពេញបានប្រមាណពីរបីថ្ងៃ ប៉ើ បានចាកចេញពីផ្ទះនៅភ្នំពេញមកតាមយើងដែរ ។

ម៉ែ និង ប៉ើ ជួបជុំគ្នាវិញមិនបានប៉ុន្មានផង នៅឆ្នាំ១៩៧៦ ប៉ើ បានទទួលមរណភាព ។ គាត់ឈឺមិនមានចំណីអាហារនិងថ្នាំសង្កូវគ្រប់គ្រាន់ ។ ខ្ញុំមកមិនទាន់ដង្ហើមរបស់គាត់ទេ ។ យើងគ្មានក្ដារត្រឹមត្រូវសម្រាប់ដាក់សពរបស់ប៉ើឡើយ ។ ខ្ញុំយំឱបសព ប៉ើ រហូតទាល់តែប្ដីខ្ញុំទាញចេញ ។ សពរបស់ប៉ើត្រូវកប់ដោយមិនមានពូនដីធ្វើជាផ្នូរ ព្រោះអង្គការត្រូវការដីធ្វើស្រែ ។ កាលនោះ អង្គការមិនអនុញ្ញាតឲ្យយើងកាប់ឈើធ្វើជាមឈូសដាក់សពទេ ប៉ុន្តែយើងអាចមានសិទ្ធិកាប់ឫស្សីមកក្រងរុំសពហើយយកទៅកប់នៅវាលស្រែ ។

### ការសម្រាលកូនទីពីរ

ក្រោយមកមិនយូរប៉ុន្មាន ខ្ញុំមានផ្ទៃពោះ ។

ពេលខ្ញុំចាប់មានផ្ទៃពោះ ភីរម្យ នៅខែដំបូងខ្ញុំចាញ់រហូត ។ ខ្ញុំសម្រាកនៅផ្ទះ មិនបានចេញទៅធ្វើការទេ ។ ខ្ញុំឃ្លានតែម្ជូរនិងបង្អែម ។ កាលនោះខ្ញុំចាំថា មានស្ត្រីមានផ្ទៃពោះស្របាលនឹងខ្ញុំប្រមាណជា៩នាក់ទៀតដែរ ។ នៅខែទីពីរ ពេលដែលខ្ញុំបានធូរស្រាលប្រធានក្រុមឲ្យខ្ញុំទៅធ្វើការនៅតាមវាលវិញ ។ ដំបូង ប្ដីខ្ញុំធ្វើការនៅក្នុងភូមិ ឬនៅព្រៃជិតៗផ្ទះ ដល់ពេលខ្ញុំមានផ្ទៃពោះមិនយូរ ប៉ុន្មាន អង្គការបានបញ្ជូនគាត់ទៅកាប់ព្រៃឆ្ងាយពីផ្ទះ ។ ខ្ញុំព្រួយបារម្ភពីគាត់ណាស់ ។ ខ្ញុំធ្វើការងារជាច្រើនដែលខ្ញុំមិនធ្លាប់ធ្វើពីមុនមកដូចជា ដកសំណាប ស្ទូងស្រូវ ដាំដំឡូង ជម្រះស្មៅ និងចាប់កណ្ដុរ ជាដើម ។ ខ្ញុំជាមនុស្សខ្លាចសត្វល្អិតណាស់ សូម្បីតែជីងចក់ក៏ខ្ញុំខ្លាចដែរ ។ ពេលមួយនោះ ប្រធានក្រុមខ្ញុំបានបែងចែកកម្លាំងក្នុងក្រុមឲ្យដើរចាប់កណ្ដុរ ព្រោះកណ្ដុរបានបំផ្លាញស្រូវអស់មួយភាគធំ ។ ខ្ញុំដើរចាប់កណ្ដុរជាមួយប្រធានក្រុម ប៉ុន្តែទម្រាំនឹងចាប់បានខ្ញុំធ្វើឲ្យគាត់ខឹងខ្ញុំជាខ្លាំង ដោយសារតែខ្ញុំខ្លាចជ្រុលពេកមិនហ៊ានចាក់កណ្ដុរ ។ ប្ដីខ្ញុំដឹងថាខ្ញុំខ្លាចកណ្ដុរ គាត់បានជួយរកបានកណ្ដុរមួយសំបុកក្រហមរងាលរៀបទុកដាក់ឲ្យខ្ញុំនៅកន្លែងមួយដោយទុកសញ្ញាសំគាល់ផង ។ ខ្ញុំរកបានហើយធ្វើជាដើរទៅក្បែរគេផ្សេងទៀតដើម្បីឲ្យគេជឿថា ខ្ញុំជាអ្នករកបានកណ្ដុរនោះ ។ ខ្ញុំបានឡើងមកភូមិសម្រាកមុនគេ ។ ខ្ញុំក៏ខ្លាចខ្មោចណាស់ដែរ ប៉ុន្តែដោយសារ ក្រពះទាមទារ ខ្ញុំហ៊ាន ចុះទៅក្នុងស្រះទឹករាវក្ដាមខ្យង និងបេះព្រលិតនៅពេលយប់តែម្នាក់ឯង ។

ភីរម្យ កើតមកចំពេលប្រទេសកំពុងមានសង្គ្រាមមិនមានចំណីអាហារថ្នាំសង្កូវឬ ពេទ្យគ្រប់គ្រាន់ទេ ហេតុនេះ ភីរម្យ មានជម្ងឺមកបៀតបៀនរហូតមិនសូវលស់ពេល ។ រហូតដល់អាយុ៣ឆ្នាំហើយ ភីរម្យនៅតែមិនទាន់បេះដើរទៀត ។

តាំងពីក្មេងមក ខ្ញុំមិនដែលស្គាល់ថាស្ត្រីទាស់ក្រោយសម្រាលកូននោះថាជាអ្វីទេ ទើបតែពេលខ្ញុំសម្រាលកូនទីពីរនេះខ្ញុំទាស់ចំណីឈឺរីងស្គមស្គាំងហើយរាកជាច្រើនដងទៀត ។ ខ្ញុំពិបាកក្នុងខ្លួនណាស់ទាល់តែបាននារីពេទ្យម្នាក់ឈ្មោះ លុច ឲ្យថ្នាំកែរោគទាស់គឺស្លឹកទៀប៧ត្រួយទំពាឲ្យម៉ត់ និងស្រាមួយពែងទើបបានធូរស្រាល ។

មានពេលមួយនោះ ខ្ញុំពុលដំឡូងឈើដែលជាអាហារថ្ងៃត្រង់របស់ខ្ញុំ ។ ក្រោយពីហូបហើយខ្ញុំមានអាការៈរោយថ្កាមងងុយដេកនិងស្វាបមិនឈប់សោះ ។ ខ្ញុំពឹងមិត្តម្នាក់ឲ្យជួយកោសខ្យល់ឲ្យខ្ញុំ ប៉ុន្តែនៅតែមិនបានគ្រាន់បើទៀត ។ ខ្ញុំងងឹតមុខបែកពពុះមាត់ ទន់ខ្លួនដូចសំឡី ។ មិត្តភក្តិនៅទីនោះបានជួយគ្រាហ៍ខ្ញុំដាក់រទេះទៅពេទ្យព្រែកតាឃ្លោក ។ ពេលខ្ញុំកំពុងដេកនៅពេទ្យ មិត្តរីនបានយកប្រេង កាតមកបញ្ច្រុកខ្ញុំ ។ ពេលនោះខ្ញុំលេបចូលមួយក្អឹក ហើយខ្ញុំស្រែកឆោឡោឡើងថាជាប្រេងកាត ។ មិត្តរីន សម្លុតខ្ញុំថា មិនមែនប្រេងកាតទេ គឺជាថ្នាំពេទ្យ ។ ក្រោយមក មិត្ត រីនធុំក្លិនប្រេងកាត គាត់ឆែកមើលកែវថ្នាំនោះ ហើយលាន់មាត់ថាមិនដឹងអ្នកណាយកកែវប្រេងកាតមកដាក់នៅជិតដៃ ។ គាត់ប្រឡំស្មានថាកែវនោះជាកែវថ្នាំ ។

### ការចាប់ខ្លួនបងប្រុសនិងប្ដីរបស់ខ្ញុំ

បងគៀងជាអតីតគ្រូបង្រៀននៅភ្នំពេញ ។ នៅរដូវចូល

ឆ្នាំខ្មែរ ឆ្នាំ១៩៧៧ អង្គការអនុញ្ញាតឲ្យប្រជាជនសម្រាកពីការងារចំនួនបីថ្ងៃ ប៉ុន្តែពុំមានរៀបចំជាពិធីបុណ្យអ្វីទេ ។ បងគៀង និងប្តីខ្ញុំបានត្រឡប់ពីកងចល័តមកផ្ទះវិញ ។ គាត់ប្រមូលគ្នាជាក្រុមលេងបាល់ទាត់ ។ បងគៀង លេងឈ្នះរហូតធ្វើឲ្យប្រធានភូមិចង់ដឹងពីប្រវត្តិពិតរបស់គាត់ ។ ក្រោយមកមិនយូរប៉ុន្មាន អង្គការបានប្រាប់បងគៀង ឲ្យទៅរែកខ្សាច់នៅក្បាលកោះ ។ គាត់ចេញទៅដោយគ្មានយកអីវ៉ាន់ទៅជាមួយទេ គឺគាត់យកតែថ្នាំជក់មួយដៃនិងខោអាវមួយចង្កេះប៉ុណ្ណោះ ។ ម៉ែហាក់ដូចជាដឹងថានាំបងប្រុសទៅគ្មានថ្ងៃនឹងត្រឡប់មកវិញ គាត់អង្វរខ្ញុំឲ្យសុំច្បាប់ប្រធានកងមួយព្រឹក ដើម្បីទៅតាមមើលនៅក្បាលកោះថាមានកសិករនៅរែកខ្សាច់មែនឬទេ ប៉ុន្តែខ្ញុំបដិសេធនឹងគាត់ ។ ការបាត់ខ្លួនរបស់ បងគៀង ធ្វើឲ្យម៉ែចេះតែរវើរវាយរហូតដល់ថ្នាក់ បោកក្បាលខ្លួនឯងទៀតផង ។ ដំណាលគ្នានឹងការបាត់ខ្លួនរបស់បងគៀង អតីតគ្រូបង្រៀនពីរនាក់ទៀតក៏ត្រូវបាត់ខ្លួនដែរ ។ ការបាត់ខ្លួនជាមនុស្សជាបន្តបន្ទាប់ ធ្វើឲ្យខ្ញុំចាប់ព្រួយបារម្ភពីវាសនារបស់ប្តីខ្ញុំ ព្រោះគាត់ជាអតីតគ្រូពេទ្យ ហើយប្រជាជននៅក្នុងភូមិសុទ្ធតែដឹងពីមុខងាររបស់គាត់ ។


ទេព ស៊ុយអៀង និងស្វាមី នៅឆ្នាំ១៩៧៣

ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ កាណូតចេះតែមកដឹកប្រជាជនថ្មីជារៀងរាល់យប់ ។ ម្តាយខ្ញុំដេកស្តាប់តែស្នូរម៉ាស៊ីនកាណូត ព្រោះកាណូតបានដឹកកូនគាត់យកទៅម្តងហើយ គាត់ខ្លាចដឹកយកកូនប្រសាគាត់(ប្តីខ្ញុំ) ទៅទៀត ។ គាត់បានប្រាប់ខ្ញុំនិងប្តីខ្ញុំឲ្យប្រុងប្រយ័ត្ន កុំធ្វេសប្រហែស ។

នៅរដូវស្ទូង នៅការដ្ឋានមានម៉ាស៊ីនភ្លើងបំភ្លឺតាមវាលស្រែ ប្រណាំងគ្នានឹងសំឡេងវិទ្យុទ្រហឹងអឹងកងពេញស្រែ ។ យប់នោះពេលធ្វើការរួច ខ្ញុំឈរចាំប្តីខ្ញុំនៅលើភ្លឺស្រែប៉ុន្តែមិនឃើញគាត់ឡើងមកសោះ ។ អ្នកផ្សេងឡើងផុតអស់ទៅហើយនៅតែមិនឃើញគាត់ ។ ខ្ញុំក៏ឡើងទៅផ្ទះ ប៉ុន្តែពេលមកដល់ផ្ទះម្តាយក្មេកខ្ញុំស្រែកផងយំផងថាប្តីខ្ញុំត្រូវអង្គការចាប់ដាក់កាណូតយកទៅបាត់ហើយ ។ ខ្ញុំដួលសន្លប់មួយរំពេចពេលឮដំណឹងនេះ ។ ពេលខ្ញុំដឹងខ្លួនឡើង ម៉ែរៀបរាប់ដំណើររឿងដែលឈ្លប ដុន ចាប់ប្តីខ្ញុំថា ប្តីខ្ញុំត្រូវឈ្លបចងហើយបណ្តើរដាក់កាណូតយកទៅបាត់ ។ ប៉ុន្តែមុននឹងទៅប្តីខ្ញុំបានអង្វរសុំឈ្លប ដុន មកសំពះលាម្តាយនិងមើលមុខកូនជាលើកចុងក្រោយ ។ ក្រោយពីយកប្តីខ្ញុំទៅ ឈ្លបដុនបានមកឆែករកនាឡិការបស់ប្តីខ្ញុំទៀត ប៉ុន្តែខ្ញុំបានកុហកថាខ្ញុំរកមិនឃើញ

ទេ ។ ខ្ញុំឲ្យម្តាយក្មេកខ្ញុំយកនាឡិកានោះផ្ញើទុកនៅអ្នកផ្សេងដែលទុកចិត្ត ។

ខ្ញុំហាក់ដូចជាគ្មានព្រលឹងក្នុងខ្លួនសោះក្រោយពីប្តីខ្ញុំទៅបាត់បាយទឹកមិនចង់ហូបធ្វើឲ្យម៉ែខឹងខ្ញុំ ហើយរំលឹកប្រាប់ខ្ញុំពីពាក្យសន្យាដែលខ្ញុំបាននិយាយជាមួយប្តីថាខ្ញុំនឹងរស់នៅរឹងប៉ឹងតស៊ូនឹងជីវិតគ្មានរាថយ ។ ពេលឮម្តាយខ្ញុំរំលឹកពីរឿងនេះខ្ញុំដឹងខ្លួនឡើងខំប្រឹងទប់ជំហរខ្លួនឯងហូបបាយនិងធ្វើការវិញ ។ ក្រោយមក ខ្ញុំក៏បានលួចកោរសក់ដើម្បីកាន់ទុក្ខជូនប្តីខ្ញុំ ។

## មរណភាពម្តាយខ្ញុំ

ដើមឡើយ ម៉ែជាស្រីរឹងប៉ឹងនិងមាំមួនណាស់ក៏ប៉ុន្តែចាប់ពីគាត់ដួលបោកក្បាលសន្ទប់នៅលើទូកម្តងមក គាត់ប្រែជាទន់ខ្សោយ ហើយធ្លាក់ខ្លួនឈឺដេកនៅលើកន្ទេលរហូត ។

ដើមឆ្នាំ១៩៧៨ ម៉ែចាប់ធ្លាក់ខ្លួនឈឺធ្ងន់ ។ គាត់ខស្យាហ៍ដួលបោកក្បាលចេញឈាមនិងសន្លប់ជាញឹកញាប់ ។ ចាប់ពីនោះមកខ្ញុំបានច្បាប់អនុញ្ញាតឲ្យមកធ្វើការនៅក្បែរផ្ទះដើម្បីមើលជំងឺគាត់ ម៉ែមានជំងឺចម្លែកហើមនិងប៉ោងពោះដូចស្រ្តីមានផ្ទៃពោះគ្រប់ខែហើយឃ្លានគ្រប់មុខ ។ រំលងបានប្រហែលជាមួយខែ ម៉ែស្លាប់យ៉ាងអាណោចអាធ័មបំផុត ។ គាត់សំណាងណាស់មានមឈូសដាក់សព ។

ចុងឆ្នាំ១៩៧៨ ស្គរកាំភ្លើងខិតចូលមកកាន់តែជិតភូមិព្រែកបាឡាត់ឆឹង ។ ប្អូនថ្លៃខ្ញុំម្នាក់ត្រូវបញ្ជូនទៅសមរភូមិដើម្បីប្រយុទ្ធជាមួយកងទ័ពវៀតណាមដែលចូលមកកាន់តែជិត ។ កុមារនៅតាមកងត្រូវអង្គការរំសាយឲ្យមករស់នៅតាមភូមិវិញ មន្ទីរពេទ្យក៏ត្រូវរំសាយដែរ ។ មួយរយៈក្រោយមក កងស្រ្តីនិងកសិករបានឡើងមករស់នៅភូមិវិញជាបណ្តើរៗព្រោះមិនឃើញប្រធានភូមិចុះទៅត្រួតពិនិត្យដូចមុន ។ ស្រមោលប្រធានភូមិនៅសល់តែមេក្រុមតូចតាច ដែលនៅភូមិជាមួយប្រជាជន ។ ឃ្លាំងស្រូវនៅវត្តតាម៉មនិងឃ្លាំងសេដ្ឋកិច្ចនៅជិតផ្ទះខ្ញុំត្រូវប្រជាជនដណ្តើម គ្នាចូលយកស្រូវ និងអីវ៉ាន់ប្រើប្រាស់តាមតែលទ្ធភាពរៀងខ្លួន ។

នៅដើមឆ្នាំ១៩៧៩ បងស្រីខ្ញុំឈ្មោះ ជន បានត្រឡប់មកផ្ទះវិញ ។ ខ្ញុំបាត់ដំណឹងពីគាត់ពីរ-បីឆ្នាំមកហើយ ។ មុននេះគាត់សម្ងំលាក់ខ្លួនកែឈ្មោះកែអាយុ ធ្វើការនៅក្នុងកងចល័តដែលគ្មានអ្នកស្គាល់គាត់ ។ ពេលជួបមុខគាត់ខ្ញុំមើលសឹងតែមិនស្គាល់ ។ ការងារធ្ងន់ធ្ងរ ម្ហូបអាហារមិនគ្រប់គ្រាន់ ធ្វើឲ្យគាត់ធ្លាក់ខ្លួនឈឺស្គម ។ ក្រោយមកប្រហែលជាកន្លះខែ បងជន បានចូលទៅធ្វើការនៅ មន្ទីរពេទ្យស្រុកស្អាង ។ ចាប់ពីនោះមក គាត់មានសុខភាពល្អមានសាច់ឈាមពេញបរិបូណ៌ឡើងវិញ ។

ខ្ញុំនៅតែមិនអាចបំភ្លេចបានជាមួយអនុស្សាវរីយ៍ទាំងឡាយដែលប្តីខ្ញុំបន្សល់ទុកឲ្យខ្ញុំ ទោះបីសព្វថ្ងៃខ្ញុំបានមករស់នៅប្រទេសបារាំងហើយក៏ដោយ ។ ពេលខ្ញុំមានផ្ទៃពោះកូនទីពីរ គឺក្នុងសម័យប៉ុលពត បងទ្រី សុខចិត្ត ហត់នឿយរកធ្យូង រកថ្នាំបុសឈើវល្លិយកមកទុកឲ្យប្រពន្ធនៅពេលឆ្លងទន្លេ ។ គាត់ជាអ្នកបង្កើតកូនឲ្យខ្ញុំដោយផ្ទាល់ដៃ ។ គាត់ឆ្លៀតពេលយប់នៅដេកថែភ្លើងឲ្យ ប្រពន្ធក្រោយពីធ្វើការពេលថ្ងៃយ៉ាងហត់នឿយ ។ ពេលបានចំណីមកគាត់មិនហ៊ានហូបទេ ខំលាក់លៀមទុកនៅពេលយប់ស្ងាត់ចែកឲ្យប្រពន្ធ ។ ប្តីខ្ញុំមិនសុខចិត្តយករួចខ្លួនម្នាក់ឯង មិនមានការទទួលខុសត្រូវប្រពន្ធកូន ហើយរត់ទៅរស់នៅតែម្នាក់ឯងដោយទុកឲ្យគ្រួសារនៅឯភូមិលំបាកនោះទេ ។ គាត់ការពារគ្រួសារជានិច្ច ។ សព្វថ្ងៃនេះពេលដែលខ្ញុំញាំស្ពៅ ខ្ញុំតែងតែអង្គុយស្រក់ទឹកភ្នែកនឹកប្តីតែម្នាក់ឯង នឹកឃើញកាលពីខ្ញុំចាញ់កូនចង់ញាំស្ពៅ គាត់ឡើងបេះនៅលើដើមរបួសចេញឈាមពេញដើមទ្រូង ។ កាលនោះខ្ញុំអង្វរគាត់ថាកុំឲ្យឡើងបេះ ប៉ុន្តែគាត់មានះបង់ធ្វើឲ្យខាងតែបាន ។

**ប៊ាន ពីច័ន និង ស៊ីរី សាទីណា**

នៅក្នុងបន្ទប់សវនាការ ប្រជាជនកំពុងសាកសួរឯកឧត្តម ស៊ាន វិសុទ្ធ អំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម



# ស្វែងរករូបថតជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានថតនៅរវាងឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧៥

ថ្មីៗនេះមជ្ឈមណ្ឌលឯកសារកម្ពុជាបានបោះពុម្ពផ្សាយសៀវភៅមួយក្បាលដែលមានចំណងជើងថា “ជីវិតក្នុងភាពនឹងថ្កល់” ដែលបង្ហាញអំពីរូបថតជាច្រើនដែលបន្សល់ទុកពីសម័យខ្មែរក្រហម ។ សៀវភៅនេះរៀបរាប់អំពីដំណើរជីវិតរបស់បុរស៣៥នាក់និងស្ត្រី១៦នាក់មកពីខេត្តកំពង់ចាម កណ្តាល កំពង់ធំ និងតាកែវ ដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហម ។ មនុស្សចំនួន៣៩នាក់ ក្នុងចំណោម៥១នាក់ដែលបានចុះនៅក្នុងសៀវភៅនេះបានស្លាប់នៅមន្ទីរសន្តិសុខ ស-២១ ហើយមានតែ៩នាក់ប៉ុណ្ណោះដែលមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។

នៅក្នុងពេលឆាប់ៗខាងមុខនេះ យើងនឹងអានអត្ថបទស្តីពីរឿងរ៉ាវរបស់មនុស្សមួយចំនួននៅក្នុងសៀវភៅនេះផ្សាយតាមរលកធាតុអាកាសវិទ្យុ *FM102MHz* ទីក្រុងភ្នំពេញ វិទ្យុ *FM93.25MHz* ខេត្តកំពត វិទ្យុ *FM99MHz* ខេត្តព្រះវិហារ និងវិទ្យុ*FM* ១០៣.២៥*MHz* ខេត្តបាត់ដំបង ។

ក្នុងការសរសេរសៀវភៅនេះ យើងបានធ្វើសម្ភាសន៍អតីតកម្មាភិបាលខ្មែរក្រហម ប្រជាជនមូលដ្ឋាន និងសមាជិកក្រុមគ្រួសាររបស់អ្នកទាំងនោះ ។ សាក្សីរបស់យើងបានឲ្យរូបថតជាច្រើនមកយើង ដែលភាគច្រើននៃរូបថតទាំងនោះបានថតមុនពេលខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ប៉ុន្តែក៏មានរូបថតកម្មាភិបាលមួយចំនួនបានថតក្នុងអំឡុងពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហមដែរ ។

សៀវភៅដែលរួមមានទាំងរូបថតនិងរឿងរ៉ាវអមជាមួយនេះបានទទួលជំនួយពី “ទាយជ្ជទានជាតិដើម្បីប្រជាធិបតេយ្យ” ។ សៀវភៅនេះបង្ហាញថា អ្នកដែលបានចូលបម្រើបដិវត្តន៍ខ្មែរក្រហមមានក្តីសង្ឃឹមនិងការចង់បានដូចជាប្រជាជនកម្ពុជាដទៃទៀត ហើយអ្នកទាំងនោះក៏បានជួបប្រទះនូវការលំបាកជាច្រើនដែរ រួមទាំងការបាត់បង់មនុស្សជាទីស្រលាញ់របស់ខ្លួនផង ។ យើងសង្ឃឹមថាសៀវភៅនេះនឹងជួយឲ្យប្រជាជនកម្ពុជាយល់ថា ទាំងជនរងគ្រោះនិងជនដៃដល់គឺជាមនុស្សដូចគ្នា ។

ឥឡូវនេះ យើងមានគម្រោងសរសេរសៀវភៅថ្មីមួយក្បាលទៀតដែលរៀបរាប់អំពីដំណើររឿងរបស់ប្រជាជនថ្មីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រសិនបើលោកអ្នកឬសាច់ញាតិណាម្នាក់របស់លោកអ្នកជាប្រជាជនថ្មី ហើយចង់រួមចំណែកចែករំលែករឿងរ៉ាវនៅក្នុងសៀវភៅនេះយើងនឹងទៅសម្ភាសលោកអ្នកដោយផ្ទាល់ ។ យើងសូមស្វាគមន៍ចំពោះការចូលរួមចំណែករបស់ប្រជាពលរដ្ឋខ្មែរទាំងក្នុងនិងក្រៅប្រទេស ហើយដោយសារតែរូបថតទាំងនេះជាផ្នែកមួយដែលមានសារសំខាន់សម្រាប់សៀវភៅ យើងគ្រាន់តែស្នើសុំការជួយជ្រោមជ្រែងពីសំណាក់ប្រជាពលរដ្ឋដែលស្ម័គ្រចិត្តចែករំលែករូបថតរបស់ខ្លួនតែប៉ុណ្ណោះ ។ រូបថតទាំងនោះចាំបាច់ ត្រូវតែជារូបថតដែលបានថតមុនឬក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងនឹងថតចម្លងរូបថតរបស់អស់លោកអ្នកបន្ទាប់មក នឹងប្រគល់ រូបថតដើមជូនទៅលោកអ្នកវិញ ។



ឈឹម រ៉េត និងក្រុមគ្រួសារ

សូមលោកអ្នកទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈទូរស័ព្ទលេខ០២៣ ២១១ ៨៧៥ ឬផ្ញើលិខិតមកប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញឬទាក់ទងតាមអ៊ីមែល truthpivoine@dccam.org ។

សូមអរគុណ ។

# ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញនៅក្ន

*អ្នកចូលរួមនៅក្នុងដំណើរទស្សនកិច្ចមានចំនួន ៤៨០ នាក់ មកពីខេត្តកំពង់ចាម កំពង់ឆ្នាំង កំពត កំពង់ធំ ក្រចេះ កណ្ដាល ព្រៃវែង*









# ងតុលាការកម្ពុជា នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦

*ស្វាយរៀង កំពង់សោម ព្រះវិហារ កោះកុង សៀមរាប ពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ស្ពឺ តាកែវ និងភ្នំពេញ ។*




ដូនជីពេលដើរទស្សនាវាលពិឃាតបឹងជើងឯក

# សំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ក្រុមខណ្ឌលិខិតូបករណ៍និងស្ថាប័ននានា

## ១) សេចក្តីផ្តើម

ជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្សមានសិទ្ធិទទួលសំណងមកវិញ ។ អង្គការសហប្រជាជាតិចាត់ទុកថានេះជាសិទ្ធិសំខាន់មួយក្នុងចំណោមសិទ្ធិសំខាន់បីគឺ “សិទ្ធិទទួលការដឹងឮ សិទ្ធិទទួលបានយុត្តិធម៌ និងសិទ្ធិទទួលបានសំណង” ក៏ប៉ុន្តែភាពទន់ខ្សោយនិងគោលជំហរមិនច្បាស់លាស់របស់ជនរងគ្រោះក្នុងការស្វែងរកសំណងអាចជាឱកាសល្អមួយដែលធ្វើឲ្យការរំលោភសិទ្ធិមនុស្សរីកកាន់តែធំឡើងទៀត ។ ក្នុងអត្ថបទរបស់ គ្រីស្ទាន ធមមឺសឆាត ស្តីអំពី “សំណងជនរងគ្រោះដែលទទួលរងការរំលោភសិទ្ធិធ្ងន់ធ្ងរ” បានអះអាងថា ៖

បច្ចុប្បន្ននេះ គ្មានគោលការណ៍មូលដ្ឋាននៃច្បាប់ទំនៀមទម្លាប់អន្តរជាតិណាមួយចែងអំពីសំណងចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរក្រោមច្បាប់អន្តរជាតិឡើយ ។ ដូចបានពន្យល់ខាងលើ ការទាមទារបែបនេះគ្មានមូលដ្ឋានក្នុងការអនុវត្តន៍ច្បាប់ទេ ។

តាមរយៈគេហទំព័រណែលនេះ សំណងជនរងគ្រោះដោយការរំលោភសិទ្ធកំពុងតែទាញចំណាប់អារម្មណ៍ពីប្រទេសនានានៅលើពិភពលោក រួមបញ្ចូលទាំងប្រទេសជាសមាជិកអង្គការសហប្រជាជាតិផង ។ ប្រហែលជាប្រទេសនីមួយៗ កត់សម្គាល់ឃើញថា និន្នាការស្វែងរកវិធីដើម្បីទទួលសំណងពីការរំលោភសិទ្ធិមនុស្សហាក់ដូចជាមានភាពល្អប្រសើរជាងមុន ហើយការបង្កើតប្រព័ន្ធច្បាប់ក្នុងការសម្រេចសំណងទាំងកម្រិតតំបន់និងអន្តរជាតិ ដោយផ្អែកលើហេតុផលថា ប្រសិនបើប្រព័ន្ធច្បាប់មួយប្រព្រឹត្តទៅមិនបានល្អទេនោះ ប្រព័ន្ធនេះប្រាកដជាផ្អែកលើប្រព័ន្ធមួយផ្សេងទៀត ឬអាចនិយាយម្យ៉ាងទៀតថាជម្រើសសម្រាប់ទាមទារសំណងពីការរំលោភសិទ្ធិមនុស្សកំពុងតែដំណើរការ ។ លិខិតូបករណ៍ច្បាប់ដែលជាប់ទាក់ទិនកំពុងតែត្រូវបានបង្កើតឡើងខណៈដែលលិខិតូបករណ៍ច្បាប់សម្រាប់អនុវត្តកំពុងតែត្រូវបានបង្កើតឡើងដែរ ។ ផ្អែកលើនិន្នាការនេះ ប្រទេសមួយចំនួនក៏បានដោះស្រាយបញ្ហាសំណងរួចរាល់ ហើយប្រទេសមួយចំនួនទៀតពុំទាន់បានដោះស្រាយនៅឡើយ ។

ម្យ៉ាងទៀត ប្រទេសនីមួយៗអាចអង្កេតឃើញថា ការស្វែងរកសំណងអាចនឹងរកឃើញចំពោះមុខតុលាការយុត្តិធម៌

អន្តរជាតិដែលជាស្ថាប័នច្បាប់ដ៏សំខាន់មួយជួយជំរុញអនុវត្តកិច្ចការរបស់អង្គការសហប្រជាជាតិ ដោយរាប់បញ្ចូលគំនិតស្តីអំពីសិទ្ធិមនុស្ស ។ តាមប្រព័ន្ធច្បាប់អឺរ៉ុបនិងអន្តរអាមេរិក សំណងលើការរំលោភសិទ្ធិមនុស្សអាចរៀបចំសំណុំរឿងបញ្ជូនទៅទាំងគណៈកម្មការនិងតុលាការរៀងៗខ្លួន និងអាចដោះស្រាយតាមប្រព័ន្ធច្បាប់អាហ្វ្រិក ។ ទន្ទឹមនឹងនោះដែរ គណៈកម្មការស្វែងរកការពិតនៃប្រទេសនីមួយៗកំពុងតែឆ្ពោះទៅរកការពិតហើយ ។

អ្វីដែលប្រសើរជាងការសិក្សាអំពីសារសំខាន់នៃសំណងក្នុងក្របខណ្ឌសិទ្ធិមនុស្សគឺមានក្នុងនិក្ខេបបទនេះ ហើយដែលផ្តោតជាសំខាន់ទៅលើក្របខណ្ឌសំណងក្នុងវិសាលភាពលិខិតូបករណ៍ច្បាប់និងស្ថាប័នស្តីអំពីសិទ្ធិមនុស្ស ។ ខាងក្រោមនេះគឺជាចំណុចសំខាន់ដែលត្រូវយកបានពិភាក្សាទៅតាមផ្នែក ៖ ផ្នែកទី១ សេចក្តីផ្តើម, ផ្នែកទី២ ដំណោះស្រាយក្របខណ្ឌក្នុងលិខិតូបករណ៍ច្បាប់ស្តីអំពីសិទ្ធិមនុស្សលើបញ្ហាសំណង, ផ្នែកទី៣ នីតិវិធីសំណងតាមស្ថាប័នសំខាន់ៗ និងផ្នែកទី៤ សេចក្តីសន្និដ្ឋាន ។

## ២) លិខិតូបករណ៍ច្បាប់មូលដ្ឋានពាក់ព័ន្ធនឹងសំណង

ដើម្បីឲ្យដឹងថាតើការរំលោភសិទ្ធិមនុស្សផ្តល់ផលវិបាកអ្វីខ្លះក្នុងការផ្តល់សំណងជូនជនរងគ្រោះដែរឬអត់នោះ ដំណាក់កាលដំបូងត្រូវពិនិត្យជាសំខាន់ទៅលើប្រភពលិខិតូបករណ៍ច្បាប់ដែលមានស្រាប់ទាក់ទិននឹងបទបញ្ញត្តិស្តីអំពីសំណង ឬការសងជំងឺចិត្ត ។ ឧបករណ៍ច្បាប់សំខាន់ៗខុសៗគ្នាពីកម្រិតសាកលទៅកម្រិតតំបន់ ។

### ក) លិខិតូបករណ៍ច្បាប់អង្គការសហប្រជាជាតិ

ផ្តើមចេញពីធម្មនុញ្ញអង្គការសហប្រជាជាតិ "ការជំរុញឲ្យមានការគោរពសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន" គឺជាគោលបំណងសំខាន់មួយដែលត្រូវបានទទួលស្គាល់ថាជាឯកសារគ្រប់គ្រងច្បាប់នៅលើពិភពលោក ។ ទោះបីជាបទបញ្ញត្តិនៃធម្មនុញ្ញសហប្រជាជាតិមិនបានពិភាក្សាអំពីសំណងក្នុងបរិបទសិទ្ធិមនុស្សក៏ដោយ ក៏ធម្មនុញ្ញនេះចែងអំពីពេលវេលាកំណត់ដែលធម្មនុញ្ញនេះដាក់កាតព្វកិច្ចទៅលើរដ្ឋជាសមាជិក ដើម្បីបញ្ជាក់បន្ថែមលើសច្ចភាពនៃ "សិទ្ធិមនុស្សជាមូលដ្ឋាន សេចក្តីថ្លៃថ្នូរនិងតម្លៃមនុស្ស សិទ្ធិស្មើគ្នារវាងស្ត្រីនិងបុរស និងសិទ្ធិស្មើគ្នារវាងប្រទេសតូចនិងប្រទេសធំ" ។ មាត្រា៥៥ នៃធម្មនុញ្ញអង្គការសហប្រជាជាតិក៏ប្រើប្រាស់ពាក្យដូចគ្នានេះដែរ ដោយសង្កត់ធ្ងន់លើកាតព្វកិច្ចក្នុងការជំរុញការគោរពសិទ្ធិមនុស្ស ។ មាត្រានេះបានចែងថា "អង្គការសហប្រជាជាតិត្រូវតែជំរុញឲ្យមានការគោរពជាសាកលនិងការត្រួតពិនិត្យសិទ្ធិនិងសេរីភាពជាមូលដ្ឋានសម្រាប់ជនគ្រប់រូបដោយគ្មានការបែងចែកពូជសាសន៍ ភេទ ភាសា និងសាសនាឡើយ ។

តាមពិត ពាក្យដែលទំនងជានិយាយច្បាស់លាស់អំពីសំណងត្រូវបានរកឃើញនៅក្នុងឯកសារផ្សេងទៀត ។ លក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិដែលជា"ស្ថាប័នយុត្តិធម៌សំខាន់របស់អង្គការសហប្រជាជាតិ" មានសមត្ថកិច្ចលើ "រឿងក្តីដែលភាគីជម្លោះនិយាយសំដៅលើនិងគ្រប់បញ្ហាដែលមានចែងជាពិសេសនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ឬក្នុងសន្ធិសញ្ញានិងអនុសញ្ញាដែលចូលជាធរមាន" ដោយរាប់បញ្ចូល "ដែនយុត្តាធិការរបស់តុលាការលើបញ្ហាច្បាប់ដែលជាប់ទាក់ទិន គឺសារជាតិឬទំហំនៃសំណងចំពោះបទល្មើសលើកាតព្វកិច្ចអន្តរជាតិ" ។ ជាលទ្ធផល ខ្លឹមសារនៃសិទ្ធិសេរីភាពជាមូលដ្ឋានចែងក្នុងលិខិតូបករណ៍ច្បាប់អង្គការសហប្រជាជាតិបានចែងពាក្យសំណងកាន់តែច្បាស់លាស់ជាងមុន ។

ជាលិខិតូបករណ៍ច្បាប់សំខាន់មួយដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនិងប្រកាសនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ដែលមាន៣០មាត្រានិយាយអំពីសិទ្ធិសេរីភាពជាមូលដ្ឋានរបស់មនុស្ស សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្សគឺជាភ័ស្តុតាង ។ មាត្រា៨នៃសេចក្តីប្រកាសនេះចែងថា "ជនគ្រប់មានសិទ្ធិទទួលបាននូវសំណងដែលមានប្រសិទ្ធភាពតាមរយៈសាលាជំនុំជម្រះក្តីជាតិដែលមានសមត្ថកិច្ចចំពោះអំពើរំលោភបំពានសិទ្ធិមូលដ្ឋានដែលរដ្ឋធម្មនុញ្ញឬច្បាប់ផ្តល់ជូន" ។

ដោយផ្អែកលើធម្មនុញ្ញនិងសេចក្តីប្រកាសនេះ អនុសញ្ញា សេចក្តីប្រកាស និងអនុសាសន៍នានារបស់អង្គការសហប្រជាជាតិត្រូវបានកែតម្រូវជាបន្តបន្ទាប់អំពីសំណងលើការរំលោភបំពានសិទ្ធិមនុស្ស ។ ជាក់ស្តែង អនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចុះថ្ងៃទី២១ ខែធ្នូ

ឆ្នាំ១៩៦៥ បានដាក់ជូនភាគីរដ្ឋជាហត្ថលេខីនូវកាតព្វកិច្ចធានាដល់ជនទាំងឡាយដែលនៅក្នុងដែនយុត្តាធិការរបស់ខ្លួនក្នុងការស្វែងរកសំណងពីការរំលោភបំពានសិទ្ធិនិងសេរីភាពជាមូលដ្ឋានក្នុងអំពើរើសអើងពូជសាសន៍ណាមួយនោះ ។ មាត្រា៦នៃអនុសញ្ញានេះមានសេចក្តីដូចក្រោម ៖

*ភាគីរដ្ឋជាហត្ថលេខីត្រូវធានាដល់ជនទាំងឡាយដែលនៅក្នុងដែនយុត្តាធិការរបស់ខ្លួន នូវការការពារនិងការសងជំងឺចិត្តប្រកបដោយប្រសិទ្ធភាពតាមរយៈតុលាការជាតិដែលមានសមត្ថកិច្ចនិងស្ថាប័នរដ្ឋដទៃទៀត ប្រឆាំងរាល់អំពើរើសអើងពូជសាសន៍ដែលបំពានលើសិទ្ធិមនុស្សនិងសេរីភាពមូលដ្ឋានផ្ទុយទៅនឹងអនុសញ្ញានេះ ព្រមទាំងសិទ្ធិក្នុងការស្វែងរកសំណងត្រឹមត្រូវនិងគ្រប់គ្រាន់ចំពោះការខូចខាតណាមួយដែលទទួលរងដោយសារការរើសអើងបែបនេះ ។*

មួយឆ្នាំក្រោយមក កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយត្រូវបានកែតម្រូវដោយមហាសន្និបាតអង្គការសហប្រជាជាតិ ហើយកតិកាសញ្ញានេះបានបោះជំហានបន្តដោយផ្តល់កាតព្វកិច្ចជូនភាគីរដ្ឋជាហត្ថលេខីនៃកតិកាសញ្ញានេះ ឲ្យធានា“សំណងជំងឺចិត្តដែលមានប្រសិទ្ធភាព” ដល់ជនដែលត្រូវរំលោភបំពានសិទ្ធិនិងសេរីភាពជាមូលដ្ឋាន ។ មាត្រា៩នៃកតិកាសញ្ញានេះសង្កត់ធ្ងន់ទៅលើសិទ្ធិទទួលបានសំណងដែលចូលជាធរមានសម្រាប់ជនរងគ្រោះដោយការឃាត់ខ្លួននិងការឃុំខ្លួនខុសច្បាប់ ។ ស្រដៀងគ្នានេះដែរ មាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិនេះ និយាយអំពីការសងជំងឺចិត្តដល់ជនរងគ្រោះដោយសារការគ្រប់គ្រងមិនល្អរបស់តុលាការ ។

អនុសញ្ញាប្រឆាំងទារុណកម្មនិងផ្តន្ទាទោស ការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៨៤ ដែលគិតត្រឹមថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៣ មានរដ្ឋជាសមាជិកចំនួន១៣៤ បានបង្ហាញពីសិទ្ធិដូចដែលមានចែងអំពីសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះដោយការធ្វើទារុណកម្មនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែរ ។ យោងតាមបទបញ្ញត្តិនេះ មិនត្រឹមតែជនរងគ្រោះប៉ុណ្ណោះទេដែលទទួលបានសំណងជំងឺចិត្តអ្នកក្រោមបន្ទុករបស់ជនរងគ្រោះក៏មានសិទ្ធិទទួលបានសំណងផងដែរ ។ មាត្រា១៤នៃអនុសញ្ញានេះចែងថា ៖

*ភាគីរដ្ឋជាហត្ថលេខីនីមួយៗត្រូវធានាក្នុងប្រព័ន្ធច្បាប់របស់ខ្លួនថា ជនរងគ្រោះដោយអំពើទារុណកម្មទទួលបានសំណងមកវិញ ឬទទួលបានសំណងត្រឹមត្រូវនិងគ្រប់គ្រាន់ដោយរាប់បញ្ចូលនីតិវិធីសម្រាប់ការស្តារឡើងវិញយ៉ាងពេញលេញតាមតែអាចធ្វើទៅបាន ។ អ្នកនៅក្រោមបន្ទុករបស់ជនរងគ្រោះក៏មានសិទ្ធិទទួលបានសំណងដែរ ។*

ទោះបីជាមានការទាមទារសំណងចំពោះការរំលោភសិទ្ធិមនុស្សហើយក៏ដោយ អង្គការសហប្រជាជាតិបានអនុម័តសេចក្តីប្រកាសជាបន្តបន្ទាប់ទៀត ។ ជាក់ស្តែង សេចក្តីប្រកាសអំពីគោលការណ៍មូលដ្ឋានយុត្តិធម៌សម្រាប់ជនរងគ្រោះដោយឧក្រិដ្ឋកម្មនិងការរំលោភបំពានត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិកែតម្រូវនៅឆ្នាំ១៩៨៥ ហើយសេចក្តីប្រកាសនេះបានផ្តល់សិទ្ធិជនរងគ្រោះរួមទាំងក្រុមគ្រួសារនិងអ្នកនៅក្រោមបន្ទុករបស់ជនរងគ្រោះ មានសិទ្ធិទទួលបានការគាំពារដោយត្រឹមត្រូវនិងយុត្តិធម៌និងមានសិទ្ធិទទួលបានសំណង ។ ទាក់ទិននឹងសេចក្តីប្រកាសស្តីអំពីការការពារជនគ្រប់រូបពីការចាប់ពង្រត់ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩២ ដែលសង្កត់ធ្ងន់ទៅលើកាតព្វកិច្ចរបស់រដ្ឋជាសមាជិកនៃធម្មនុញ្ញអង្គការសហប្រជាជាតិនៃមាត្រា៥៥ និងដែលបានបង្ហាញអំពីសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណង ។ មាត្រា១៩នៃសេចក្តីប្រកាសនេះចែងថា ៖

*ជនរងគ្រោះនិងក្រុមគ្រួសារដោយអំពើចាប់ពង្រត់ត្រូវទទួលបានសំណងនិងមានសិទ្ធិទទួលបានសំណងគ្រប់គ្រាន់ រួមមានសំណងសម្រាប់បំពេញនីតិសម្បទាតាមដែលអាចធ្វើទៅបាន ។ ប្រសិនបើជនរងគ្រោះស្លាប់ អ្នកនៅក្រោមបន្ទុករបស់ជនរងគ្រោះក៏មានសិទ្ធិទទួលបានសំណងដែរ ។*

ទន្ទឹមគ្នានោះដែរ គោលការណ៍និងសេចក្តីណែនាំស្តីអំពីសំណងត្រូវបានសម្រេចដូចបានឃើញខាងក្រោមនេះ ។ ជាក់ស្តែង អនុសាសន៍នៃគោលការណ៍ដែលធ្វើដោយក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិលើសេចក្តីសម្រេចលេខ ១៩៨៩/៦៥ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៨៩ ពន្យល់

អំពីការទប់ស្កាត់ ការស៊ើបអង្កេត និងនីតិវិធី រួមមានការរំលោភបំពានច្បាប់តាមអំពើចិត្តនិងភ្លាមៗ ។ កថាខណ្ឌទី២០នៃគោលការណ៍នេះចែងថា "ក្រុមគ្រួសារនិងអ្នកនៅក្រោមបន្ទុករបស់ជនរងគ្រោះដោយសារការបំពានច្បាប់តាមអំពើចិត្តមានសិទ្ធិទទួលបានសំណងត្រឹមត្រូវនិងគ្រប់គ្រាន់ក្នុងរយៈពេលដ៏សមហេតុសមផលមួយ ។

ទាក់ទិននឹងបញ្ហាសំណងលើការរំលោភសិទ្ធិមនុស្ស ក្រុមប្រឹក្សាសង្គមនិងសេដ្ឋកិច្ចនៃអង្គការសហប្រជាជាតិស្នើសុំឲ្យស្ថាប័នត្រួតពិនិត្យរបស់ខ្លួនសិក្សាទៅលើបញ្ហានេះ ហើយរបាយការណ៍ត្រូវផ្ញើជូនជាបន្តបន្ទាប់ ។ ដោយត្រូវបានស្គាល់ជាគោលការណ៍និងសេចក្តីណែនាំមូលដ្ឋានស្តីអំពីសិទ្ធិទទួលបានសំណងសម្រាប់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងច្បាប់មនុស្សធម៌នៅក្នុងរបាយការណ៍របស់លោក ថែវ វ៉ានបូវេន ក្រៅពីសិទ្ធិទទួលបានសំណង "សំណងអាចនឹងត្រូវបានប្រកាសជាបុគ្គលនិងនៅទីកន្លែងសមរម្យដោយជនរងគ្រោះ អ្នកនៅក្រោមបន្ទុកឬអ្នកដែលមានទំនាក់ទំនងជិតស្និទ្ធនឹងជនរងគ្រោះ" ។ តាមរបាយការណ៍ដែលត្រូវបានពិនិត្យជាចុងក្រោយដែលរៀបចំដោយ លុីស ជ័ញនេត លើសេចក្តីសម្រេចអនុគណៈកម្មការ ១៩៩៦/១១៩ គោលការណ៍ទាំងនេះត្រូវបានដាក់ចេញនូវជំហានមួយបន្ថែមទៀត ៖ "ការរំលោភសិទ្ធិមនុស្សណាមួយដែលតម្រូវឲ្យមានសំណងចំពោះជនរងគ្រោះឬអ្នកទទួលមត៌កនៃជនរងគ្រោះ ភាគីរដ្ឋជាអ្នកសងសំណងនេះ និងឱកាសដល់ជនរងគ្រោះក្នុងការស្វែងរកសំណងពីជនដៃដល់" ។

តាមកិច្ចប្រជុំលើកទី៥៧ ថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ គណៈកម្មការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិបានអនុម័តដោយគ្មានការបោះឆ្នោតលើសេចក្តីសម្រេចលេខ១៩៩៧//២៩ ស្តីអំពីសិទ្ធិទទួលបានសំណងចំពោះការខាតបង់ការសងជំងឺចិត្តនិងនីតិសម្បទាសម្រាប់ជនរងគ្រោះដោយសារការរំលោភបំពានលើសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន ។ តាមសេចក្តីសម្រេចនេះ គណៈកម្មការអំពាវនាវម្តងទៀតឲ្យសហគមន៍អន្តរជាតិយកចិត្តទុកទៅលើសិទ្ធិទទួលបានសំណងចំពោះការខាតបង់សំណងជំងឺចិត្តនិងនីតិសម្បទាសម្រាប់ជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្ស ។

តាមលទ្ធផលនៃរបាយការណ៍របស់ ជីរីហ្វ បាសុីអូនី គណៈកម្មការសម្រេចកែតម្រូវគោលការណ៍ណែនាំជាមូលដ្ឋានដូចបានរៀបរាប់ខាងលើ ។ គោលការណ៍នេះចែងថា "គួរតែជំរុញឲ្យមានសំណងភ្លាមៗមានប្រសិទ្ធភាពនិងគ្រប់គ្រាន់លើការរំលោភបំពានលើសិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ សំណងគួរតែសមាមាត្រទៅនឹងទម្ងន់នៃការរំលោភបំពាននិងទុក្ខទោស" ។ម្យ៉ាងទៀត គោលការណ៍ណែនាំជាមូលដ្ឋានបង្ហាញថា "ក្នុងករណីដែលការរំលោភពុំបង្កដោយបំពាននេះរដ្ឋជាសមាជិកភាគីក្តីដែលទទួលខុសត្រូវលើការរំលោភបំពាន គួរតែផ្តល់សំណងទៅឲ្យជនរងគ្រោះឬភាគីរដ្ឋប្រសិនបើភាគីរដ្ឋបានផ្តល់សំណងដល់ជនរងគ្រោះរួចហើយ" ។

## ៣) លិខិតុបករណ៍ច្បាប់អន្តរជាតិថ្នាក់តំបន់

ទោះបីជាយ៉ាងណាក៏ដោយ បញ្ហាសំណងមិនទាន់បញ្ចប់នៅឡើយនៅក្នុងឯកសាររបស់អង្គការសហប្រជាជាតិ ។ តាមថ្នាក់តំបន់ លិខិតុបករណ៍ច្បាប់ដែលមិនគួរជឿជាច្រើនទាក់ទិននឹងសំណងជនរងគ្រោះដោយការរំលោភបំពានសិទ្ធិមនុស្សត្រូវបានអនុម័តជាពិសេសក្នុងប្រព័ន្ធសិទ្ធិមនុស្សអាហ្វ្រិកអន្តរអាមេរិកនិងអឺរ៉ុប ។

លិខិតុបករណ៍ច្បាប់ដំបូងគឺប្រព័ន្ធសិទ្ធិមនុស្សនៅអឺរ៉ុបដែលជាសមិទ្ធិផលដ៏ត្រចះត្រចង់នៃក្រុមប្រឹក្សាអឺរ៉ុប ។ តាមឈ្មោះដើមជាអនុសញ្ញាការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានអនុសញ្ញានេះជាលិខិតុបករណ៍ច្បាប់ដ៏សំខាន់បំផុតដែលចេញពីលក្ខន្តិកៈឆ្នាំ១៩៤៩នៃក្រុមប្រឹក្សានេះ ដោយផ្អែកលើនីតិរដ្ឋធានាមានលទ្ធិប្រជាធិបតេយ្យនិងបទដ្ឋានអប្បបរមាដើម្បីការពារសិទ្ធិមនុស្ស ។ ដូចបានពោលក្នុងបុព្វកថានៃអនុសញ្ញានេះ ទាំងនេះជាលិខិតុបករណ៍ច្បាប់ខ្លះៗដែលប្រទេសនៅទ្វីបអឺរ៉ុបបោះជំហានជាលើកដំបូងសម្រាប់ការអនុវត្តន៍ច្បាប់រួមលើសិទ្ធិជាក់លាក់មួយចំនួនដែលមានបង្ហាញក្នុងសេចក្តីប្រកាសជាសកលស្តីអំពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិឆ្នាំ១៩៤៨ ។

ជាក់ស្តែងតាង នៅក្នុងមាត្រា១៣នៃអនុសញ្ញាអឺរ៉ុប សិទ្ធិទទួលបាននៃសំណងត្រូវបានដកស្រង់មួយផ្នែកពីមាត្រា៨នៃ

សេចក្តីប្រកាសជាសកល និងដែលមានចែងក្នុងអនុសញ្ញាថា “ជនទាំងឡាយដែលត្រូវរំលោភបំពានសិទ្ធិនិងសេរីភាពដូចដែលចែងក្នុងអនុសញ្ញានេះត្រូវទទួលបានសំណងដែលមានប្រសិទ្ធភាពចំពោះមុខអាជ្ញាធរជាតិ ទោះបីជាការរំលោភបំពានត្រូវបានប្រព្រឹត្តក៏ដោយ” ។ ដោយឡែកមាត្រា៥(៥)នៃអនុសញ្ញានេះសង្កត់ធ្ងន់លើបញ្ហានេះថា “ជនរងគ្រោះដោយការចាប់ខ្លួននិងការឃុំខ្លួនដែលផ្ទុយទៅនឹងមាត្រានេះមានសិទ្ធិទទួលបានសំណងជំងឺចិត្ត” ។

ម្យ៉ាងវិញទៀត មាត្រា៣ស្តីអំពី“សំណងលើការកាត់ទោសមិនត្រឹមត្រូវ” ពិធីសារបន្ថែមលេខ៧នៃអនុសញ្ញាការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដូចដែលបានធ្វើវិសោធនកម្មដោយពិធីសារបន្ថែមលេខ១១ សង្កត់ធ្ងន់ថា ៖

*ប្រសិនបើជនណាម្នាក់ត្រូវបានកាត់ទោសពីបទឧក្រិដ្ឋ បន្ទាប់មកបានអត់ឱនទោសដោយហេតុថាអង្គហេតុពិតដែលរកឃើញថ្មីៗបង្ហាញច្បាស់ថាតុលាការមានការថ្លោះធ្លោយ ជននោះនឹងបានទទួលសំណងជំងឺចិត្តដោយយោងលើច្បាប់ឬការអនុវត្តនៃរដ្ឋដែលពាក់ព័ន្ធ លើកលែងតែមានភស្តុតាងបង្ហាញថាជននោះបានបិទបាំងការពិតទាំងស្រុងឬដោយផ្នែកក្នុងពេលកាត់ទោស ។*

លិខិតូបករណ៍ច្បាប់ទីពីរគឺប្រព័ន្ធសិទ្ធិមនុស្សនៅអាហ្វ្រិក ។ សំណុំឯកសារជាមូលដ្ឋានក្នុងប្រព័ន្ធច្បាប់អឺរ៉ុបស្តីអំពីសិទ្ធិមនុស្សមិនខុសពីសំណុំឯកសារក្នុងប្រព័ន្ធច្បាប់អន្តរអាមេរិកទេ ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងប្រព័ន្ធច្បាប់អន្តរអាមេរិក ការធានានិងការគាំពារសិទ្ធិមនុស្សត្រូវបានចែងក្នុងសេចក្តីប្រកាសឆ្នាំ១៩៤៨ស្តីអំពីសិទ្ធិនិងករណីយកិច្ចរបស់ជនគ្រប់រូប និងក្នុងអនុសញ្ញាអាមេរិកឆ្នាំ១៩៦៩ស្តីអំពីសិទ្ធិមនុស្សដែលជាលិខិតូបករណ៍ច្បាប់សំខាន់ដំបូង ។ សិទ្ធិដែលបានបង្ហាញក្នុងឧបករណ៍ទាំងនេះត្រូវបានពិនិត្យនិងការពារតាមរយៈការប្រតិបត្តិរបស់គណៈកម្មការអន្តរអាមេរិកស្តីអំពីសិទ្ធិមនុស្ស ដែលជាស្ថាប័នសំខាន់ដែលបង្កើតឡើងក្រោមធម្មនុញ្ញនៃអង្គការរដ្ឋអាមេរិក និងតុលាការសិទ្ធិមនុស្សអន្តរអាមេរិកដែលបង្កើតក្រោមអនុសញ្ញានេះ ។

ទាក់ទិននឹង“ខ”ស្តីអំពីសំណង ឬសំណងជំងឺចិត្តដល់ជនរងគ្រោះដែលត្រូវរំលោភបំពានសិទ្ធិអនុសញ្ញាអាមេរិកស្តីអំពីសិទ្ធិមនុស្សដែលចូលជាធរមាននៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៦៩ ចែង“ខ”មួយចំនួនតួយ៉ាងមាត្រា១០នៃអនុសញ្ញានេះស្តីអំពី“សិទ្ធិទទួលបានសំណង” ចែងថា “ជនគ្រប់រូបមានសិទ្ធិទទួលសំណងស្របតាមច្បាប់ប្រសិនបើជននោះត្រូវបានកាត់ទោសដោយការវិនិច្ឆ័យថ្លោះធ្លោយរបស់តុលាការ” ។ ទន្ទឹមនឹងនោះ មាត្រា២១ដែលនិយាយយោងលើ“សិទ្ធិមានទ្រព្យសម្បត្តិ” ដែលសំណងត្រូវតែមានក្នុងករណីដែលទ្រព្យសម្បត្តិរបស់ជននោះត្រូវបានដកហូត ។ មាត្រានេះបានចែងថា “គ្មានជនណាម្នាក់ត្រូវបានដកហូតទ្រព្យសម្បត្តិទេ លើកលែងតែការចំណាយជាសំណងដែលត្រឹមត្រូវដោយហេតុផលអត្ថប្រយោជន៍សាធារណៈឬសង្គម និងក្នុងករណីយោងលើទម្រង់ដែលច្បាប់បង្កើតឡើង” ។

យោងតាមអនុសញ្ញាអន្តរជាតិទប់ស្កាត់និងកាត់ទោសអំពើទារុណកម្មដែលចូលជាធរមាននៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៨៥ រដ្ឋជាសមាជិកនៃអនុសញ្ញានេះមានកាតព្វកិច្ច “បញ្ចូលក្នុងច្បាប់ជាតិរបស់ខ្លួនដោយធានាឲ្យមានសំណងសមរម្យសម្រាប់ជនរងគ្រោះដោយអំពើទារុណកម្ម” ។ មាត្រា៩នៃអនុសញ្ញានេះចែងថា “គ្មាន“ខ”ណាមួយនៃមាត្រានេះធ្វើឲ្យអាក់ខានសិទ្ធិទទួលបានសំណងដែលជនរងគ្រោះមានក្រោមច្បាប់ជាតិដែលមានស្រាប់ឡើយ” ។ នៅក្នុងអនុសញ្ញាអន្តរអាមេរិកស្តីអំពីការទប់ស្កាត់ការកាត់ទោសនិងការលុបបំបាត់អំពើរំលោភបំពានលើស្ត្រី ដែលត្រូវបានស្គាល់ថាជាអនុសញ្ញាក្រុង បេលែម ឌូ ប៉ារ៉ា រដ្ឋជាសមាជិកនៃអនុសញ្ញានេះមានករណីយកិច្ចបង្កើតយន្តការរដ្ឋបាល និងច្បាប់ចាំបាច់ដើម្បីធានាឲ្យស្ត្រីដែលជួបប្រទះការរំលោភបំពានមានសិទ្ធិទទួលបានសំណងដោយយុត្តិធម៌និងមានប្រសិទ្ធភាព ។

ដោយសង្កត់ធ្ងន់បន្ថែមលើអនុសញ្ញានេះ កាតព្វកិច្ចនៃរដ្ឋជាសមាជិកនៃធម្មនុញ្ញអង្គការរដ្ឋអាមេរិក មានចែងក្នុងគោលការណ៍ទី៩នៃសេចក្តីប្រកាសគោលការណ៍ស្តីអំពីសេរីភាពក្នុងការបញ្ចេញមតិ ។ គោលការណ៍នេះចែងថា “...វាគឺជាករណីយកិច្ចរបស់រដ្ឋក្នុងការទប់ស្កាត់និងស៊ើបអង្កេតហេតុការណ៍ដែលកើតឡើង នាំជនដៃដល់មកកាត់ទោស និងធានាឲ្យជនរងគ្រោះ

ទទួលបានសំណងតាមការកំណត់" ។ ជាចុងក្រោយ មានតែតុលាការសិទ្ធិមនុស្សអន្តរអាមេរិកដែលមានលក្ខណៈដូចតុលាការអឺរ៉ុបទេ ដែលអាចជំទាស់ថាតើសំណងគួរតែផ្តល់ឲ្យភាគីរងគ្រោះឬមិនគួរ ។

លិខិតូបករណ៍ច្បាប់ទីបីគឺប្រព័ន្ធសិទ្ធិមនុស្សនៅអាហ្វ្រិក ។ ប្រព័ន្ធច្បាប់តំបន់របស់អាហ្វ្រិកដែលលើកកម្ពស់និងគាំពារសិទ្ធិមនុស្សក្នុងរដ្ឋជាសមាជិកនៃអង្គការឯកភាពអាហ្វ្រិកត្រូវបានចាត់ទុកជាលិខិតូបករណ៍ច្បាប់ដែលវ័យក្មេងបំផុតបើធៀបទៅនឹងប្រព័ន្ធច្បាប់អន្តរអាមេរិកនិងអឺរ៉ុប ។ ការទាមទារសិទ្ធិមនុស្សនិងសិទ្ធិប្រជាជនព្រមទាំងសិទ្ធិសង្គមនិងវប្បធម៌ត្រូវបានចែងក្នុងធម្មនុញ្ញអាហ្វ្រិកស្តីអំពីសិទ្ធិមនុស្សនិងសិទ្ធិប្រជាជនដែលត្រូវបានអនុម័តនៅថ្ងៃទី២៧ ខែមិថុនា ១៩៨១ និងចូលជាធរមាននៅថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៨៦ ។

ដើម្បីជំរុញនិងការពារសិទ្ធិមនុស្ស មាត្រា៣០នៃធម្មនុញ្ញនេះបានបង្កើតគណៈកម្មការអាហ្វ្រិកស្តីអំពីសិទ្ធិមនុស្សនិងសិទ្ធិប្រជាជន ដែលជាស្ថាប័នមួយនៃអង្គការឯកភាពអាហ្វ្រិក ហើយមាត្រា៤៥ បានផ្តល់ឲ្យគណៈកម្មការនេះនូវអំណាចយ៉ាងទូលំទូលាយរួមបញ្ចូលទាំងអំណាចក្នុងការបកស្រាយធម្មនុញ្ញនិងអំណាចបំពេញការកិច្ចដទៃទៀតដែលប្រមុខរដ្ឋនិងរដ្ឋាភិបាលនៃសភាអង្គការឯកភាពអាហ្វ្រិកបានចាត់តាំង ។

នៅក្នុងរដ្ឋធម្មនុញ្ញអាហ្វ្រិកពុំមានបញ្ញត្តិដែលចែងអំពីសំណងជាសម្ភារៈឬសំណងជំងឺចិត្តជនរងគ្រោះដែលត្រូវរំលោភបំពានសិទ្ធិទេ ក្រៅពីមាត្រាដែលបញ្ជាក់ច្បាស់អំពីសិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិថា "ក្នុងករណីលួចឆក់ប្លន់ជនទាំងឡាយដែលត្រូវដកហូតទ្រព្យសម្បត្តិ មានសិទ្ធិទទួលទ្រព្យមកវិញដោយស្របច្បាប់និងមានសិទ្ធិទទួលសំណងគ្រប់គ្រាន់" ។

"ខ"មួយទៀតចែងក្នុងពិធីសារបន្ថែមនៃធម្មនុញ្ញអាហ្វ្រិកស្តីអំពីសិទ្ធិមនុស្សនិងសិទ្ធិប្រជាជនលើការបង្កើតតុលាការអាហ្វ្រិកលើសិទ្ធិមនុស្សនិងសិទ្ធិប្រជាជនដែលបានអនុម័តដោយប្រមុខរដ្ឋនិងរដ្ឋាភិបាលនៃអង្គការឯកភាពអាហ្វ្រិក នៅខែមិថុនា ឆ្នាំ១៩៩៨ ។ មាត្រា២៧កថាខណ្ឌទី១នៃពិធីសារនេះចែងថា "ប្រសិនបើតុលាការរកឃើញថាមានការរំលោភបំពានលើសិទ្ធិមនុស្សនិងសិទ្ធិប្រជាជន តុលាការនឹងចេញដីកាបង្គាប់ឲ្យសងចំពោះការរំលោភបំពាននេះ" ។

ការបង្កើតច្បាប់ថ្មីទាក់ទិននឹងសំណងមានចែងនៅក្នុងលក្ខន្តិកៈក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ដែលអនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨ ដោយសន្និសីទទំនាក់ទំនងការទូតនៃអង្គការសហប្រជាជាតិស្តីអំពីការបង្កើតតុលាការឧក្រិដ្ឋកម្មអន្តរជាតិនៅទីក្រុងរ៉ូមប្រទេសអ៊ីតាលី ។ តាមលក្ខន្តិកៈនេះ លក្ខខណ្ឌសំណងចំពោះជនរងគ្រោះត្រូវបានចែងក្នុងមាត្រា៧៥ដែលមាន៥កថាខណ្ឌ ។ កថាខណ្ឌទី១ចែងថា ៖

*តុលាការត្រូវបង្កើតគោលការណ៍ស្តីអំពីសំណងសម្រាប់ជនរងគ្រោះ ដោយរាប់បញ្ចូលសំណងជាទ្រព្យសម្បត្តិ ជាប្រាក់ និងនីតិសម្បទា ។ ផ្អែកលើមូលដ្ឋាននេះ តាមសេចក្តីសម្រេចរបស់ខ្លួន តុលាការអាចកំណត់វិសាលភាពនិងទំហំនៃការខូចខាតនិងស្នាមរបួសរបស់ជនរងគ្រោះ ដោយផ្អែកលើសំណើឬញត្តិទៅតាមពេលវេលាខុសប្រក្រតីនិងថ្លែងបញ្ជាក់គោលការណ៍តុលាការកំពុងអនុវត្ត ។*

មុនពេលដែលលក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិចែងអំពីមាត្រាខាងលើនេះ លក្ខន្តិកៈនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាំងដា ត្រូវបាននិយាយយោងលើសិទ្ធិជាម្ចាស់ទ្រព្យសម្បត្តិដែលសមនឹងទទួលបានសំណង ។ មាត្រា២៣(៣) នៃលក្ខន្តិកៈនេះបានបញ្ជាក់ថា "ក្រៅពីការកាត់ទោសឲ្យជាប់ពន្ធនាគារ អង្គជំនុំជម្រះក្តីមានសិទ្ធិចេញបញ្ជាឲ្យមានការសងទ្រព្យសម្បត្តិ និងនីតិវិធីដែលស្របតាមការប្រព្រឹត្តបទឧក្រិដ្ឋដោយរាប់បញ្ចូលទាំងការបង្ខិតបង្ខំចំពោះម្ចាស់កម្មសិទ្ធិផង ។ ម៉្យាងទៀតនីតិវិធីនិងភ័ស្តុតាងដែលតុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉ាំងដាបានប្រើប្រាស់គាំទ្រឯកសារយោងខាងលើនេះទាំងស្រុង ។ ច្បាប់ ១០៦ ស្តីអំពី "សំណងជនរងគ្រោះ" ក្នុងកថាខណ្ឌ(ខ) ចែងថា "ទាក់ទិននឹងច្បាប់ជាតិ ជនរងគ្រោះឬជនដែលទាមទារតាមរយៈជនរងគ្រោះអាចដាក់ពាក្យបណ្តឹងទៅតុលាការជាតិ ឬអង្គការដែលមានសមត្ថកិច្ចដើម្បីទទួលបានសំណង ។ ***(នៅមានត)***

**ខ៉ាន់ថាន់ ពៅដារ៉ា**

# យុត្តិធម៌និងការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសកម្ពុជា

*(តពីលេខមុន)*

## ៣) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា

តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាអង្គការសហប្រជាជាតិនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤ តាមសំណើរបស់រដ្ឋាភិបាលថ្មីនៃប្រទេសរ៉្វាន់ដានិងក្រុមស្រាវជ្រាវពិសេសអំពីស្ថានភាពប្រទេសរ៉្វាន់ដា ។ តុលាការនេះបង្កើតឡើងដើម្បីកាត់ទោសបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះការរំលោភបំពានច្បាប់អន្តរជាតិអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលកើតឡើងនៅក្នុងប្រទេសរ៉្វាន់ដានិងនៅប្រទេសជិតខាងពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ។ បំណងសំខាន់របស់តុលាការនេះគឺលុបបំបាត់ប្រពៃណីលើកលែងទោស និងជំរុញឲ្យមានការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅប្រទេសរ៉្វាន់ដា ។ លោក កូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិបញ្ជាក់អំពីសារសំខាន់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិដូចខាងក្រោមនេះ ÷

*ខ្ញុំនិងសហគមន៍អន្តរជាតិសង្ឃឹមថា យុត្តិធម៌ដែលផ្តល់ដោយតុលាការអន្តរជាតិពិតជាអាចចូលរួមចំណែកក្នុងដំណើរការផ្សះផ្សានិងបង្រួបបង្រួមជាតិនៅប្រទេសរ៉្វាន់ដា ។ ការព្យាបាលសុខភាពផ្លូវចិត្តត្រូវការសន្តិភាព សន្តិភាពត្រូវការយុត្តិធម៌ ហើយយុត្តិធម៌ត្រូវការការគោរពសិទ្ធិមនុស្សនិងច្បាប់ទម្លាប់ ។*

ចាប់តាំងពីថ្ងៃចាប់បដិសន្ធិនៅខែវិច្ឆិកាឆ្នាំ១៩៩៤ តុលាការព្រហ្មទណ្ឌអន្តរជាតិបានចាប់ខ្លួនជនសង្ស័យចំនួន៦៥នាក់ ។ សមាសភាពជនសង្ស័យដែលត្រូវចាប់ខ្លួនរួមមានអតីតរដ្ឋមន្ត្រីចំនួន១២រូប និងអតីតមន្ត្រីបម្រើការងារក្នុងក្រសួងមន្ទីរ កងកម្លាំងប្រដាប់អាវុធ អ្នកជំនួញ មេដឹកនាំសាសនា និងអ្នកសារព័ត៌មាន ។

**ជនសង្ស័យដែលត្រូវចាប់ខ្លួន**

| | |
|---|---|
| *ជំនុំជម្រះក្តីរួច* | ១៨ |
| *រង់ចាំការជំនុំជម្រះក្តី* | ៣១ |
| *រង់ចាំការបញ្ជូនខ្លួន* | ២ |
| *បណ្តឹងឧទ្ធរណ៍* | ៤ |
| **ចំនួនជនជាប់ចោទសរុបនៅអារូហ្សា** | **៥៥** |
| *រង់ចាំការបញ្ជូនខ្លួន* | ០ |
| *សាលក្រម (ទីក្រុងម៉ាលី)* | ៦ |
| **ចំនួនជនជាប់សង្ស័យសរុប** | **៦១** |
| *ដោះលែង* | ៣ |
| *ស្លាប់* | ១ |
| **ចំនួនដែលត្រូវបានចាប់ខ្លួនសរុប** | **៦៥** |

## ៤) ចំណុចខ្លាំងនិងចំណុចខ្សោយ

យុត្តិធម៌មានសារសំខាន់សម្រាប់គ្រប់ប្រទេសជាតិ ជាពិសេសប្រទេសរ៉្វាន់ដាដែលធ្លាប់ទទួលរងគ្រោះដោយអំពើប្រល័យពូជសាសន៍ ។ យុត្តិធម៌អាចជួយឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយ និងបង្កើតក្តីសង្ឃឹមសម្រាប់ការបង្រួបបង្រួមជាតិ ។ ការស្វែងរកយុត្តិធម៌អាចជួយលុបបំបាត់វប្បធម៌លើកលែងទោស កសាងច្បាប់ទម្លាប់ និងចៀសវាងការគុំកួន ការសងសឹក ការកាប់សម្លាប់គ្នាទៅវិញទៅមក ។ ការស្វែងរកយុត្តិធម៌ជួយជំរុញឲ្យមានកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ គោរពសិទ្ធិមនុស្ស និងកសាងប្រទេសរ៉្វាន់ដាឲ្យក្លាយជានីតិរដ្ឋ ។ ប្រជាជនរ៉្វាន់ដាជាច្រើននាក់មានចិត្តរីករាយ ហើយមានអារម្មណ៍ធូរស្បើយ ទីមួយដោយសារការរងគ្រោះរបស់ខ្លួនត្រូវបានទទួលស្គាល់ និងទីពីរដោយសារការស្វែងរកយុត្តិធម៌នេះគឺសម្រាប់ផ្តល់ឲ្យខ្លួន ។ លេនណាគ អេសពើ គ្រិន អតីតចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា រៀបរាប់អំពីអត្ថប្រយោជន៍របស់តុលាការព្រហ្មទណ្ឌអន្តរជាតិថា ÷

*តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាការព្រមានចំពោះឧក្រិដ្ឋជនដែលបានកាប់សម្លាប់និងរំលោភបំពានលើផ្លូវភេទ ថាអំពើ*

របស់អ្នកទាំងនោះគឺជាអំពើផ្ទុយពីច្បាប់ ហើយដាច់ខាតត្រូវតែទទួលទោសទោះបីជាការប្រព្រឹត្តនោះស្ថិតនៅទីកន្លែងណាក្តី ។ តុលាការព្រហ្មទណ្ឌអន្តរជាតិក៏អាចជួយលើកស្ទួយសន្និសញ្ញាអន្តរជាតិទីក្រុងហ្សឺណែវដែលបានចែងថា ខុក្រិដ្ឋជនទាំងអស់ត្រូវតែទទួលខុសត្រូវ ។ ទាំងបុគ្គលដែលបញ្ជានិងបុគ្គលដែលអនុវត្តតាមបញ្ជា ម្នាក់ៗសុទ្ធតែមានចំណែកទទួលខុសត្រូវចំពោះមុខច្បាប់ ។

អត្ថប្រយោជន៍ផ្សេងទៀតរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀត ។ ការ៉េ អាសៀល អភិបាលក្រុងគីប៊ូយេ បញ្ចេញយោបល់ថា ដំណើរការកាត់ទោសខុក្រិដ្ឋជនយ៉ាងហោចណាស់ធ្វើឲ្យជនដែលមានបំណងអាក្រក់ឬមានផែនការសម្លាប់ប្រជាជនគិតសាជាថ្មីថាគួរធ្វើឬមិនគួរធ្វើ ។ អាសៀល ពន្យល់ថា “ប្រទេសរ្វ៉ាន់ដាជាប្រទេសដែលមានការកាប់សម្លាប់ជាប្រចាំ ហើយខុក្រិដ្ឋជនតែងតែរួចពីសំណាញ់ច្បាប់ ។ ការបង្កើតឲ្យមានការកាត់ទោសនៅពេលនេះពិតជាអាចលុបបំបាត់វប្បធម៌រួចទោសនៅក្នុងប្រទេសនេះបាន” ។ អ្នកនាំពាក្យរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ជាក់បន្ថែមថា “ការកាត់ទោសខុក្រិដ្ឋជនប្រល័យពូជសាសន៍គឺជាការបញ្ជាក់ប្រាប់អ្នកដឹកនាំជុំវិញពិភពលោកក្នុងសតវត្សរ៍ទី២១នេះថា “បើមានការប្រព្រឹត្តខុសគឺត្រូវតែមានការកាត់ទោស” ។

ដោយសារអំពើវិនាសកម្មមានទំហំធំធេង ជនជាតិទុតស៊ីមួយចំនួនបានចងកំហឹងនិងរើសអើងចំពោះជនជាតិហ៊ូទូ ហើយចាត់ទុកជនជាតិហ៊ូទូជាសត្រូវស្លាប់រស់របស់ខ្លួន ។ ម៉ាហ្គេរីតឡេន ណាយរ៉េនទិនកា គឺជាស្ត្រីមេម៉ាយ ។ សមាជិកគ្រួសាររបស់គាត់ទាំងអស់ត្រូវសម្លាប់ ។ បន្ទាប់ពីការជំនុំជម្រះក្តីខុក្រិដ្ឋជនដែលបានសម្លាប់សមាជិកក្រុមគ្រួសាររបស់គាត់ប្រព្រឹត្តទៅចប់សព្វគ្រប់ ណាយរ៉េនទិនកា និយាយថា “ថ្ងៃនេះយើងមានអារម្មណ៍ថាយើងជាមនុស្សជាតិពិតប្រាកដ” ។ ស្ត្រីម្នាក់ទៀតដែលរងគ្រោះដោយអំពើរំលោភផ្លូវភេទ បានបញ្ចេញយោបល់នៅក្នុងសវនាការថា “ការពិតមិនមែនជនជាតិហ៊ូទូទាំងអស់ជាឃាតករនិងសុទ្ធតែអាក្រក់នោះទេ” ។ ឧទាហរណ៍ខាងលើនេះបញ្ជាក់ថា ការដាក់ទោសរបស់តុលាការចំពោះខុក្រិដ្ឋជនអាចជួយលើកស្ទួយតម្លៃរបស់ជនរងគ្រោះ ហើយក៏អាចបញ្ជាក់អំពីភាពបរិសុទ្ធរបស់ប្រជាជនស្លូតត្រង់ដែរ ។

ដំណើរការកាត់ទោសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចជំរុញឲ្យមានការផ្សះផ្សាបង្រួបបង្រួមជាតិតាមរយៈការថែរក្សាឯកសារនិងភស្តុតាងសម្រាប់ប្រើប្រាស់ទាំងនៅក្នុងតុលាការនិងប្រវត្តិសាស្ត្រ ។ លេនណាត អេសពើគ្រិន បញ្ជាក់ថា ក្នុងដំណើរការជំនុំជម្រះតែងតែមានការកត់ត្រាអំពីហេតុការណ៍ដែលបានកើតឡើង ការរៀបរាប់របស់សាក្សីនៅក្នុងករណីនីមួយៗមានចាប់ពី៦ពាន់រហូតដល់៨ពាន់ទំព័រ ។ ក្រៅពីឯកសារនិងភស្តុតាងដែលរៀបរាប់ដោយសាក្សី តុលាការនៅមានឯកសារប្រភេទរូបថតនិងកាសែតវីដេអូជាច្រើនទៀត ។ ឯកសារនិងភស្តុតាងទាំងអស់មានតម្លៃធំធេងសម្រាប់ប្រវត្តិសាស្ត្រនិងមនុស្សជាតិទូទៅ ។

ការដាក់ទោសខុក្រិដ្ឋជនអាចជួយឲ្យអារម្មណ៍ជនរងគ្រោះបានធូរស្បើយមួយកម្រិត ។ ការដាក់ទោសអំពើរំលោភសិទ្ធិមនុស្សអាចកសាងច្បាប់ទម្លាប់និងនីតិរដ្ឋ ហើយការកាត់ទោសគឺជារនាំងការពារការរំលោភបំពានរបស់អ្នកកាន់អំណាចមកលើប្រជាជន ។ ក៏ប៉ុន្តែ ប្រជាជនរ្វ៉ាន់ដាមួយចំនួនមិនយល់ស្របរាល់អត្ថប្រយោជន៍របស់តុលាការដូចដែលពោលខាងលើឡើយ ។ ប្រជាជនទាំងនោះបដិសេធមិនទទួលស្គាល់តួនាទីនិងអត្ថប្រយោជន៍របស់តុលាការក្នុងដំណើរការបង្រួបបង្រួមដោយសារ ÷

### ក) បញ្ហាផ្នែកសម្ភារ

តាមការសិក្សារបស់ក្រុមឃ្លាំមើលសិទ្ធិមនុស្សបន្ទាប់ពីអំពើប្រល័យពូជសាសន៍ ប្រជាជនរ្វ៉ាន់ដាទាមទាររកយុត្តិធម៌ ប៉ុន្តែត្រូវខកចិត្តដោយសារប្រព័ន្ធតុលាការក្នុងស្រុកមិនអាចជឿទុកចិត្តបាន ហើយតុលាការអន្តរជាតិមានលក្ខណៈយឺតយ៉ាវដោយសារកង្វះខាតថវិកា ។ នៅក្នុងដំណាក់កាលដំបូង បុគ្គលិកបម្រើការងារក្នុងតុលាការបានចំណាយពេលយ៉ាងច្រើនដើម្បីរៀបចំការិយាល័យនិងការងាររដ្ឋបាល ។ ការខ្វះខាតសម្ភារៈដូចជាប៊ិកនិងក្រដាសដោយសារខ្វះថវិកា និងអំពើពុករលួយបានធ្វើឲ្យបុគ្គលិកមានការនឿយណាយ ។ ម្យ៉ាងទៀត តុលាការ

ជួបប្រទះបញ្ហាក្នុងការជួលបុគ្គលិក ដោយសារតុលាការត្រូវចំណាយពេលប្រមាណមួយឆ្នាំដើម្បីរង់ចាំការិយាល័យអង្គការសហប្រជាជាតិចុះហត្ថលេខាជួលបុគ្គលិកម្នាក់ៗ ។ ថូម៉ាស់ ហ្វ្រិតម៉ែន ប្រាប់ឲ្យដឹងថា បន្ទាប់ពីមានអំពើប្រល័យពូជសាសន៍ ប្រជាជនរ៉្វាន់ដាស្រេកឃ្លានយុត្តិធម៌ ហើយទាមទារយុត្តិធម៌ដើម្បីសងសឹក ប៉ុន្តែប្រជាជនទាំងនោះត្រូវខកចិត្តយ៉ាងខ្លាំងដោយសារបញ្ហាយឺតយ៉ាវរបស់តុលាការ ។

### ១) បញ្ហាផ្នែកប្រតិបត្តិការ

តុលាការព្រហ្មទណ្ឌអន្តរជាតិស្ថិតនៅក្រៅប្រទេសឆ្ងាយពីប្រជាជន បង្កឲ្យប្រជាជនជួបប្រទះការលំបាកក្នុងការទាក់ទង ។ ម្យ៉ាងទៀត ប្រតិបត្តិការរបស់តុលាការក៏មានលក្ខណៈស្មុគស្មាញចំពោះប្រជាជនរ៉្វាន់ដាដែរ ។ ទម្លាប់របស់ប្រជាជនរ៉្វាន់ដាក្នុងការប្តឹងផ្តល់គឺសរសេរពាក្យបណ្តឹងរួចផ្ញើជូនតុលាការឬមេដឹកនាំភូមិឃុំដើម្បីដោះស្រាយ ។ ប៉ុន្តែតុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវឲ្យប្រជាជនទាក់ទងដោយផ្ទាល់ជាមួយក្រុមអ្នកច្បាប់បរទេសដែលគាត់មិនធ្លាប់ស្គាល់ពីមុនសោះ ។ ការចេញចូលធ្វើទំនាក់ទំនងជាមួយបុគ្គលិកទាំងនោះក៏មានការលំបាកនិងស្មុគស្មាញដែរ ។ ការិយាល័យរបស់មេធាវីស្ថិតនៅក្នុងទីក្រុងហើយមានការយាមកាមយ៉ាងតឹងរ៉ឹងបំផុត ។ ប្រជាជនរ៉្វាន់ដាដែលមានបំណងទាក់ទងជាមួយអ្នកស៊ើបអង្កេតក្តីរមែងត្រូវការអ្នកបកប្រែភាសា ។ លើសពីនេះ ប្រតិបត្តិការរបស់តុលាការមានសភាពមិនប្រក្រតីតាំងពីចាប់ដំណើរការដំបូងម្ល៉េះ ។ ឧទាហរណ៍ រីឆាដ ហ្គោលស្តូន ដែលជាប្រធានតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដាហាក់ចាប់អារម្មណ៍ខ្លាំងទៅលើដំណើរការកាត់ទោសឧក្រិដ្ឋជននៅប្រទេសយូហ្គោស្លាវីជាងនៅប្រទេសរ៉្វាន់ដា ។ លូីស អាបួរ ដែលបន្តការងារពី ហ្គោលស្តូន ខិតខំប្រមែប្រមូលរឿងក្តីបញ្ចូលគ្នាដើម្បីបើកសវនាការក្នុងពេលតែមួយ ប៉ុន្តែការព្យាយាមរបស់គាត់ត្រូវបោក្រុមបដិសេធ ។ ព្រមពេលជាមួយគ្នានេះដែរ ការជំនុំជម្រះក្តីអូសបន្លាយពេលយូរក្នុងការសិក្សាអំពីតួនាទីនិងការទទួលខុសត្រូវរបស់ចុងចោទ ។ អាលីសាន់ ដេហ្វុក ពន្យល់ថាបញ្ហាខាងលើធ្វើឲ្យប្រជាជនរ៉្វាន់ដាធុញទ្រាន់លែងចង់ប្តឹងផ្តល់ ហើយគិតថាការប្តឹងផ្តល់ធ្វើឲ្យគាត់កាន់តែលំបាកនិងឈឺចាប់ ។

### គ) គ្មានការពាក់ព័ន្ធ

ប្រជាជនរ៉្វាន់ដាភាគច្រើនគិតថា តុលាការព្រហ្មទណ្ឌអន្តរជាតិមិនមែនបង្កើតឡើងដើម្បីរកយុត្តិធម៌ឲ្យប្រជាជនរ៉្វាន់ដាឡើយ ដោយសារតុលាការនេះមានទីតាំងនៅក្រៅប្រទេស ហើយប្រជាជនរ៉្វាន់ដាពុំបានដឹងច្បាស់អំពីប្រតិបត្តិការនិងអំពីអ្វីដែលបានកើតឡើងពិតប្រាកដ ។ ឧទាហរណ៍ មាត្រាមួយរបស់តុលាការកំណត់ថា ឧក្រិដ្ឋជនអាចត្រូវឃុំឃាំងនៅក្នុងពន្ធនាគារក្នុងស្រុកនិងបរទេសអាស្រ័យតាមការជំនុំជម្រះរបស់តុលាការ ។ មាត្រានេះធ្វើឲ្យប្រជាជនរ៉្វាន់ដាមិនសប្បាយចិត្តនិងខកចិត្ត ជាពិសេសចំពោះការឃុំឃាំងខ្លួន យេន កាំបាន់ដា និង ថេអូនេស្តេ បាហ្គូសូរា ។ មន្ទីរឃុំឃាំងខ្លួនជនឧក្រិដ្ឋទាំងពីរមានសភាពល្អប្រសើរជាងផ្ទះរបស់ជនរងគ្រោះទៅទៀត ។ ប្រជាជនមួយចំនួនទៀតមិនសប្បាយចិត្តចំពោះតុលាការដែលកាត់ទោសឲ្យមេដឹកនាំទាំងពីរជាប់ពន្ធនាគារអស់មួយជីវិត ចំណែកឯជនដៃដល់ដែលអនុវត្តតាមបញ្ជារបស់អ្នកទាំងពីរនេះប្រឈមនឹងការកាត់ទោសប្រហារជីវិតដោយតុលាការក្នុងស្រុក ។

### ឃ) យុត្តិធម៌យឺតយ៉ាវ

ចាប់តាំងពីឆ្នាំ១៩៩៦មក តុលាការបើកសវនាការជំនុំជម្រះក្តីបានត្រឹមតែ៦ភាគរយនៃចំនួនជនសង្ស័យដែលបានចាប់ខ្លួនប៉ុណ្ណោះ ។ ក្នុងឆ្នាំ១៩៩៤ ជនសង្ស័យដែលជាប់ឃុំឃាំងមានចំនួន១ម៉ឺននាក់ ។ ចំនួនជនសង្ស័យបានកើនឡើងដល់១សែន២ម៉ឺន៥ពាន់នាក់នៅឆ្នាំ១៩៩៩ ។ ក្នុងចំនួនខាងលើនេះមានប្រជាជនពេញកម្លាំងភេទប្រុសចំនួន១០ភាគរយនៃចំនួនប្រជាជនពេញកម្លាំងទូទាំងប្រទេស ។ ដោយសារចំនួនជនសង្ស័យដែលត្រូវចាប់ខ្លួនបានកើនឡើង មន្ទីរឃុំឃាំងដែលកសាងឡើងដើម្បីឃុំឃាំងអ្នកទោស១ម៉ឺន៥ពាន់នាក់ត្រូវផ្ទុកលើសចំណុះនិងមានសភាពចង្អៀតណែនណាន់តាន់តាប់ ។ ចំណុចដែលគួរចាប់អារម្មណ៍មួយផ្សេងទៀតនោះគឺថា អ្នកទោសមួយចំនួនត្រូវចាប់ខ្លួនដាក់មន្ទីរឃុំឃាំងរាប់ឆ្នាំដោយខុសច្បាប់គ្មានការស្រាវជ្រាវច្បាស់លាស់ ។ ភាពចង្អៀតគ្មានអនាម័យ នៅក្នុងមន្ទីរឃុំឃាំងបណ្តាលឲ្យអ្នកទោសធ្លាក់ខ្លួនមានជំងឺហើយស្លាប់ជាបន្តបន្ទាប់នៅមុនពេលជំនុំជម្រះក្តី ។ ឧទាហរណ៍មន្ទីរឃុំឃាំងនៅគីបូយេដែលសាងសង់

សម្រាប់ឃុំឃាំងអ្នកទោសចំនួន៨០០នាក់ ជាក់ស្តែងត្រូវឃុំឃាំងអ្នកទោសរហូតដល់៣១៩៧នាក់ ។ មាត្រដ្ឋានអ្នកទោសក្នុងមន្ទីរឃុំឃាំងនេះគឺ៥នាក់ក្នុងមួយម៉ែត្រការ៉េ ដូច្នេះអ្នកទោសត្រូវដេកលើគ្រែដែលបន្តុបពីលើគ្នាជាច្រើនជាន់ ។ អ្នកទោសមិនអាចអង្គុយទាំងអស់គ្នាក្នុងពេលតែមួយឡើយ អ្នកទោសខ្លះត្រូវដេកនៅពេលដែលអ្នកទោសខ្លះអង្គុយ ។ អ្នកទោសទាំងអស់រស់នៅក្នុងសភាពចង្អៀតនិងលំបាកបែបនេះអស់រយៈពេលជិត៨ឆ្នាំមកហើយ ដើម្បីរង់ចាំពេលវេលាតុលាការជំនុំជម្រះក្តីរបស់ខ្លួន ។

ស្ថានភាពចង្អៀតនិងគ្មានអនាម័យ នៅក្នុងមន្ទីរឃុំឃាំងបណ្តាលឲ្យអ្នកទោសជប់ភាគរយស្លាប់បាត់បង់ជីវិតចាប់តាំងពីឆ្នាំ១៩៩៤ ។ ក្នុងអំឡុងពេលប្រមាណ១០ឆ្នាំ តុលាការជំនុំជម្រះក្តីបានត្រឹមតែជិត៦ភាគរយប៉ុណ្ណោះនៃចំនួនអ្នកជាប់ឃុំឃាំង ដូច្នេះតុលាការត្រូវចំណាយពេលរាប់រយឆ្នាំ ទើបអាចជំនុំជម្រះក្តីអ្នកជាប់ឃុំឃាំងទាំងអស់ឲ្យចប់សព្វគ្រប់ ។ ភាពស្មៀមស្ងាត់មិនដដែករកដំណោះស្រាយមិនអាចជួយធ្វើឲ្យដំណើរការផ្សះផ្សាបង្រួបបង្រួមលឿនទៅមុខបានទេ ហើយការយឺតយ៉ាវក្នុងការផ្តល់យុត្តិធម៌ជូនជនរងគ្រោះគឺកាន់តែមិនអាចជួយ ដំណើរការផ្សះផ្សាបង្រួបបង្រួមថែមទៀត ។

## ង) យុត្តិធម៌របស់អ្នកឈ្នះ

តុលាការអាចផ្តល់យុត្តិធម៌ ប៉ុន្តែមិនអាចរកឃើញការពិតឡើយ ។ យុត្តិធម៌តាមផ្លូវតុលាការគឺជាយុត្តិធម៌សម្រាប់អ្នកឈ្នះតែប៉ុណ្ណោះ ។ ជាក់ស្តែង នៅពេលសួរបញ្ជាក់អំពីចំណាប់អារម្មណ៍របស់គាត់ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ជនជាតិហ៊ូទូម្នាក់បាននិយាយថា "យុត្តិធម៌ដែលផ្តល់ដោយតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាយុត្តិធម៌របស់ឈ្នះ ។ ខ្ញុំចង់និយាយថាវាមិនមែនជាយុត្តិធម៌ទេ ប៉ុន្តែគឺជាការសងសឹករបស់អ្នកឈ្នះមកលើអ្នកចាញ់" ។

## ច) យុត្តិធម៌សម្រាប់អ្នកណា?

ឡាស បឺក ភ្ញាក់ផ្អើលជាខ្លាំងនៅខណៈពេលដែលគាត់ចុះទៅពិនិត្យស្ថានភាពអ្នកទោសក្នុងមន្ទីរឃុំឃាំងនៅគីបូយេ ហើយក្តាប់បានអំពីស្ថានភាពលំបាករបស់អ្នកទោស ជាពិសេសនៅពេលត្រូវបោទសួរដោយអ្នកទោសម្នាក់ថា "យុត្តិធម៌សម្រាប់អ្នកណា?" ។ អាណាតាសេ និង សេរូមបា ត្រូវតុលាការកាត់ទោសឲ្យជាប់គុកអស់មួយជីវិតពីបទប្រើឡានឈូសដីបំផ្លិចបំផ្លាញវិហារកាតូលិកមួយនៅនីយ៉ាងហ្គេ និងពីបទសម្លាប់ប្រជាជនទុតស៊ីអស់២ពាន់នាក់ ។ អាណាតាសេ គិតថា ការកាត់ក្តីរបស់តុលាការគឺអយុត្តិធម៌ ដោយសារគាត់ត្រូវជាប់ឃុំឃាំង ចំណែកឯសេរូមបា ដែលជាបព្វជិតសាសនានិងជាអ្នកផ្តើមគំនិតបានរត់គេចខ្លួនទៅប្រទេសអ៊ីតាលី ជ្រកក្រោមការការពាររបស់បព្វជិតនៅបូរីវ៉ាទីកង់ ។ អ្នកទោសម្នាក់ផ្សេងទៀតបានរអ៊ូរទាំថា "ដំណើរការស្វែងរកយុត្តិធម៌របស់តុលាការមានការយឺតយ៉ាវណាស់ ។ យើងជាប់ឃុំឃាំងអស់រយៈពេល៧ឆ្នាំដោយគ្មានការជំនុំជម្រះក្តី ។ ពេលយើងឮដំណឹងអំពីតុលាការកាឆាឆា យើងសប្បាយចិត្ត ហើយចង់ឲ្យតុលាការប្រជាជននេះកើតឡើងឆាប់ៗដើម្បីជួយរកយុត្តិធម៌ឲ្យយើង" ។

ឡាម ប៊ូន យល់ឃើញថា មូលហេតុសំខាន់ដែលប្រជាជនរ៉្វាន់ដាមិនពេញចិត្តហើយរិះគន់តុលាការព្រហ្មទណ្ឌអន្តរជាតិ គឺដោយសារតុលាការនេះគិតតែដោះស្រាយបញ្ហាយុត្តិធម៌ គិតតែបញ្ហាឧក្រិដ្ឋជន ហើយមិនយកចិត្តទុកដាក់ចំពោះជនរងគ្រោះដែលក្រីក្រខ្វះខាត ។ ឡាម ប៊ូន បញ្ជាក់បន្ថែមថា យុត្តិធម៌គឺជាធាតុសំខាន់ធ្វើឲ្យជនរងគ្រោះបានធូរស្បើយអារម្មណ៍ ប៉ុន្តែជនរងគ្រោះក៏ត្រូវការជំនួយបន្ថែមពីលើយុត្តិធម៌នេះដែរ ។ ជនរងគ្រោះត្រូវតែទទួលបាននូវអ្វីដែលគាត់ត្រូវការបន្ថែមពីលើយុត្តិធម៌នេះទៀត ដើម្បីឲ្យគាត់អាចបំភ្លេចអតីតកាលហើយកសាងអនាគតថ្មីឡើងវិញបាន ។

## ៥) ប្រព័ន្ធតុលាការកាឆាឆា

ដូចដែលបានបង្ហាញអំពីចំណុចខ្សោយរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចជាការយឺតយ៉ាវនិងស្ថានភាពលំបាករបស់អ្នកទោសនៅក្នុងមន្ទីរឃុំឃាំងដែលបណ្តាលឲ្យការគាំទ្ររបស់ប្រជាជនចំពោះតួនាទីតុលាការក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសរ៉្វាន់ដាថយចុះ ។ នៅពាក់កណ្តាលឆ្នាំ២០០២ រដ្ឋាភិបាលរ៉្វាន់ដាបានដាក់ចេញផែនការថ្មីដើម្បីជំរុញដំណើរការផ្សះផ្សាបង្រួបបង្រួម ។ គម្រោងថ្មីនោះហៅថា ប្រព័ន្ធតុលាការប្រជាជន

ឬប្រព័ន្ធតុលាការកាឆាឆា ដែលជាវិធីដោះស្រាយជម្លោះនៅប្រទេសរ៉្វាន់ដានាសម័យបុរាណ ។

### ក) អ្វីទៅជាតុលាការកាឆាឆា?

តុលាការកាឆាឆាគឺជាប្រភេទតុលាការសម្រាប់ដោះស្រាយទំនាស់កើតឡើងនៅក្នុងប្រទេសរ៉្វាន់ដា នៅសម័យបុរាណ ។ កាឆាឆាមានន័យថា ការជួបជុំគ្នាអង្គុយលើវាលស្មៅដើម្បីពិភាក្សាដោះស្រាយទំនាស់ដែលកើតឡើង ។ ក្នុងសម័យបុរាណមេកន្ទ្រាញឬមេភូមិបានកោះហៅភាគីជម្លោះមកជួបជុំអង្គុយលើវាលស្មៅក្រោមដើមឈើដើម្បីដោះស្រាយទំនាស់ ហើយបង្រួបបង្រួមភាគីជម្លោះឲ្យត្រូវរ៉ូវគ្នាឡើងវិញ ។ ឧទាហរណ៍ នៅពេលសត្វគោឬក្របីរបស់អ្នកភូមិណាម្នាក់បានចូលស៊ីស្រូវនៅក្នុងស្រែរបស់អ្នកភូមិម្នាក់ទៀត មេកន្ទ្រាញឬមេភូមិប្រើប្រាស់តុលាការប្រជាជនដើម្បីដោះស្រាយជម្លោះនេះ ។ វិធីសាស្ត្រនេះតម្រូវឲ្យម្ចាស់ក្របីមកអង្គុយជុំជាមួយម្ចាស់ស្រូវហើយនិយាយរៀបរាប់អំពីហេតុការណ៍ដែលបានកើតឡើងដើម្បី ឲ្យមេកន្ទ្រាញឬមេភូមិបានដឹង ។ បន្ទាប់មកមេកន្ទ្រាញ ឬមេភូមិដោះស្រាយបញ្ហានិងផ្សះផ្សាគូទំនាស់ទាំងពីរឲ្យយល់ព្រមអធ្យាស្រ័យគ្នានិងឈានដល់ការត្រូវរ៉ូវគ្នាឡើងវិញ ។ តុលាការ កាឆាឆា ដែលរដ្ឋាភិបាលរ៉្វាន់ដាដាក់ចេញដើម្បីប្រើប្រាស់ដោះស្រាយទំនាស់នៅពេលនេះ ទាមទារមនុស្សចាស់ទុំដែលមានលក្ខណៈសម្បត្តិល្អនៅក្នុងភូមិចូលរួមដោះស្រាយជម្លោះឬបណ្តឹងរបស់ប្រជាជន ។ ក៏ប៉ុន្តែ ទំនាស់នៅពេលនេះមិនមែនជាទំនាស់រឿងស្រូវឬគោក្របីឡើយ ពោលគឺទំនាស់អំពើកាប់សម្លាប់ប្រល័យពូជសាសន៍ដែលកើតឡើងនៅប្រទេសរ៉្វាន់ដាក្នុងឆ្នាំ ១៩៩៤ ។

នៅដើមឆ្នាំ១៩៩៩ សេចក្តីព្រាងច្បាប់តុលាការកាឆាឆាត្រូវបានផ្សព្វផ្សាយ ហើយការងារពាក់ព័ន្ធក៏បានចាប់ផ្តើមដំណើរការជាបន្តបន្ទាប់ដែរ ។ ឧទាហរណ៍ការប្រជុំសិក្សាអំពីច្បាប់ដែលចូលរួមដោយអង្គការក្រៅរដ្ឋាភិបាលនិងសហគមន៍អន្តរជាតិផ្តល់ជំនួយ ។ ព្រឹត្តិការណ៍ផ្សេងទៀតរួមមាន ◆ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ ប្រធានាធិបតីរ៉្វាន់ដាបានចេញអនុក្រឹត្យដោះលែងអ្នកទោសចំនួន៤៩.៣៧៦នាក់ ក្នុងនោះរួមមានអ្នកទោសដែលត្រូវចាប់ខ្លួនដោយគ្មានភស្តុតាង មនុស្សចាស់ជរា និងអ្នកទោសដែលជាប់ឃុំឃាំងជាច្រើនឆ្នាំរហូតអាចលើសពីទោសកំហុសរបស់ខ្លួនប្រសិនបើត្រូវតុលាការបើកសវនាការជំនុំជម្រះក្តី ។ ◆ ការជ្រើសរើសចៅក្រមចំនួន២៦ម៉ឺននាក់ដោយបោះឆ្នោតដែលបេក្ខជនគឺជាអ្នកដែលគ្មានជាប់ពាក់ព័ន្ធនឹងអំពើកាប់សម្លាប់ ។ ◆ ការបណ្តុះបណ្តាលជំនាញច្បាប់បន្ថែមពីសំណាក់គ្រូចំនួន៧០០នាក់ដែលបានទទួលការបណ្តុះបណ្តាលរួចអំពីច្បាប់ក៏ដូចជាការងារជាចៅក្រមក្នុងតុលាការប្រជាជនជូនដល់ចៅក្រមដែលត្រូវបានជ្រើសរើស ។ តាមផែនការរបស់រដ្ឋាភិបាលរ៉្វាន់ដា តុលាការកាឆាឆានឹងចាប់ដំណើរការនៅខែមិថុនា ឆ្នាំ២០០៣ និងបញ្ចប់នៅចុងឆ្នាំ២០០៨ ។

### ខ) ប្រព័ន្ធរបស់តុលាការកាឆាឆា

តុលាការកាឆាឆានឹងត្រូវបង្កើតឡើងនៅគ្រប់ទីកន្លែងទូទាំងប្រទេស ហើយប្រជាជនដែលរស់នៅទីកន្លែងជាអ្នកជ្រើសតាំងចៅក្រម ។ អ្នកទោសទាំងអស់លើកលែងតែប្រភេទអ្នកទោសដែលជាប់ចោទពីបទឧក្រិដ្ឋប្រភេទទីមួយ (មេដឹកនាំខ្ពស់បំផុត) នឹងត្រូវបញ្ជូនខ្លួនពីពន្ធនាគារទៅចូលរួមក្នុងសវនាការរបស់តុលាការកាឆាឆាដែលមានទីតាំងនៅកន្លែងដែលឧក្រិដ្ឋជនបានប្រព្រឹត្តឧក្រិដ្ឋកម្ម ។ ប្រជាជនចំនួន១៩រូបដែលគ្មានជាប់ពាក់ព័ន្ធនឹងអំពើឧក្រិដ្ឋនិងមិនមែនជាសាច់ញាតិរបស់អ្នកទោស នឹងត្រូវជ្រើសរើសជាគណៈកម្មការសម្រាប់សវនាការ ។ ដំណើរការរបស់តុលាការគឺប្រជាជនទាំងអស់ក្នុងសហគមន៍អាចចូលរួមក្នុងសវនាការដើម្បីពិភាក្សាផ្តល់ព័ត៌មាននិងប្តឹងប្តល់ចំពោះជនជាប់ចោទ ហើយចៅក្រមជាអ្នកសម្រេចសេចក្តី ។

តុលាការកាឆាឆាចែកចេញជាបួនថ្នាក់ ។ ទីមួយតុលាការកាឆាឆាថ្នាក់ភូមិ ទីពីរថ្នាក់ឃុំ ទីបីថ្នាក់ស្រុក និងទីបួនថ្នាក់ខេត្ត ។ តុលាការកាឆាឆាគ្រប់ថ្នាក់មានភារកិច្ចសម្រេចដោគវាសនារបស់អ្នកទោស ។ តុលាការកាឆាឆាថ្នាក់ភូមិមានភារកិច្ចជំនុំជម្រះក្តីរបស់អ្នកទោសប្រភេទទីបួន ដែលជាប់ចោទពីបទលួចរបស់របរនិងបំផ្លិចបំផ្លាញសម្ភាររបស់អ្នកដទៃ ។ ប្រសិនបើរកឃើញថាអ្នកទោសពិតជាបានប្រព្រឹត្តអំពើដូចបានពោលខាងលើអ្នកទោសត្រូវតែសងថ្លៃខូចខាតដល់ជនរងគ្រោះ ។ តាមច្បាប់របស់តុលាការកាឆាឆាករណីនេះអ្នកទោសគ្មានសិទ្ធិប្តឹងឧទ្ធរណ៍ឡើយ ។ តុលាការ

ថ្នាក់បន្ទាប់គឺតុលាការកាឆាឆាថ្នាក់ឃុំ ។ តុលាការនេះមានភារកិច្ចជំនុំជម្រះក្តីបទឧក្រិដ្ឋ ប្រភេទទីបី ដែលអ្នកទោសជាប់ចោទពីបទបន្តុះបង្អាប់មិនបានប៉ុនប៉ងបំផ្លាញអាយុជីវិត ឬធ្វើឃាតជនរងគ្រោះ ។ តុលាការថ្នាក់ស្រុកមានភារកិច្ចជំនុំជម្រះក្តីបទឧក្រិដ្ឋប្រភេទទីពីរដែលអ្នកទោសជាប់ចោទពីបទសម្លាប់មនុស្ស ។ នៅទីនេះអ្នកទោសអាចត្រូវកាត់ទោសឲ្យជាប់ឃុំឃាំងមួយរយៈ ឬជាប់គុកអស់មួយជីវិត ។ តុលាការប្រភេទចុងក្រោយគឺតុលាការកាឆាឆាថ្នាក់ខេត្ត ។ តុលាការនេះមានភារកិច្ចតែមួយគឺទទួលបណ្តឹងឧទ្ធរណ៍របស់អ្នកទោសនៅតុលាការថ្នាក់ស្រុក ។

នៅក្នុងប្រព័ន្ធតុលាការកាឆាឆា ជនជាប់ចោទគ្មានមេធាវីការពារទេ ។ ច្បាប់របស់តុលាការកាឆាឆាកំណត់ឲ្យប្រជាជនដើរតួជាដើមចោទនិងជាចៅក្រម ។ អ្នកទោសប្រភេទទីមួយដែលជាប់ចោទពីបទមេគំនិតដឹកនាំឲ្យមានអំពើប្រល័យពូជសាសន៍និងអំពើរំលោភលើផ្លូវភេទហើយដែលទំហំទោសអាចនាំដល់ការកាត់ទោសប្រហារជីវិតត្រូវជំនុំជម្រះនៅក្នុងតុលាការដែលមានមេធាវីនិងចៅក្រម ។

ចំណុចសំខាន់មួយនៅក្នុងច្បាប់របស់តុលាការកាឆាឆាគឺការសារភាពកំហុសរបស់ឧក្រិដ្ឋជន ។ ច្បាប់នេះចែងថា អ្នកទោសដែលសារភាពកំហុសហើយសុំការលើកលែងទោសនឹងទទួលបានការសម្រាលទោស ។ ការសម្រាលទោសមានទំហំធំប្រសិនបើអ្នកទោសយល់ព្រមសារភាពកំហុសរបស់ខ្លួនក្នុងអំឡុងពេលជាប់ឃុំឃាំងឬនៅមុនពេលតុលាការកាឆាឆាបើកសវនាការជំនុំជម្រះ ។ ការសម្រាលទោសមានទំហំតូចប្រសិនបើអ្នកទោសព្រមសារភាពកំហុសក្នុងអំឡុងពេលជំនុំជម្រះក្តី ហើយអ្នកទោសនឹងមិនទទួលបានការសម្រាលទោសទាល់តែសោះប្រសិនបើមិនព្រមឆ្លើយសារភាពហើយត្រូវតុលាការរកឃើញថាមានកំហុស ។ ការដាក់ទោសរបស់តុលាការកាឆាឆាគឺកំណត់ឲ្យអ្នកទោសទៅចូលរួមបម្រើសកម្មភាពសង្គម ដូចជាសង់ផ្ទះឲ្យប្រជាជន ស្ពានផ្លូវនិងសាលារៀនជាដើម ។

ចំណុចសំខាន់មួយទៀតរបស់តុលាការកាឆាឆាគឺសំណងសម្រាប់ជនរងគ្រោះ ។ នៅក្នុងផ្នែកមួយនៃដំណើរការរបស់តុលាការកាឆាឆាគឺតុលាការផ្តល់ឱកាសឲ្យជនរងគ្រោះធ្វើតារាងរៀបរាប់បញ្ជាក់អំពីការខូចខាតបាត់បង់ទ្រព្យសម្បត្តិនិងសាច់ញាតិរបស់ខ្លួនជូនតុលាការ ។ នៅពេលបញ្ចប់សវនាការជំនុំជម្រះ ជនរងគ្រោះទទួលបានលិខិតទទួលស្គាល់ការខូចខាតជាផ្លូវការពីតុលាការ ហើយអាចប្រើប្រាស់លិខិតនេះដើម្បីបើកប្រាក់សំណងអំពីមូលនិធិសាធារណៈ ។

### ក) ចំណុចខ្លាំងនិងចំណុចខ្សោយ

គោលបំណងរបស់រដ្ឋាភិបាលរ៉្វាន់ដាដែលសម្រេចយកប្រព័ន្ធយុត្តិធម៌សម័យបុរាណ ហៅថាតុលាការកាឆាឆា មកប្រើប្រាស់សម្រាប់ដោះស្រាយជម្លោះនាបច្ចុប្បន្ននេះមានដូចខាងក្រោម ÷

១) ដើម្បីស្វែងរកការពិតអំពីអ្វីដែលបានកើតឡើងក្នុងរបបប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដា

២) ដើម្បីជំរុញដំណើរការជំនុំជម្រះក្តីឲ្យលឿនទៅមុខ

៣) ដើម្បីលុបបំបាត់វប្បធម៌លើកលែងទោស

៤) ផ្សះផ្សាបង្រួបបង្រួមប្រជាជនរ៉្វាន់ដាឲ្យជានាទីងគ្នាវិញ

៥) កើនរំពឹកប្រជាជនអំពីវប្បធម៌និងយុត្តិធម៌សម័យបុរាណរបស់រ៉្វាន់ដា

៦) ដើម្បីជាការបញ្ជាក់ថាប្រជាជនរ៉្វាន់ដាមានសមត្ថភាពដោះស្រាយជម្លោះដោយខ្លួនឯង ។

តុលាការកាឆាឆាមានលទ្ធភាពសម្រេចតាមបំណងខាងលើនិងជួយឲ្យមានការផ្សះផ្សាបង្រួបបង្រួមនៅប្រទេសរ៉្វាន់ដា ជាងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ តុលាការកាឆាឆាមានចំនួនមួយម៉ឺន ហើយស្ថិតនៅគ្រប់ទីកន្លែងទូទាំងប្រទេស ដូច្នេះតុលាការនេះអាចជំនុំជម្រះក្តីបានលឿន ។ តុលាការកាឆាឆាបានកើតតាំងពីសម័យបុរាណ ដូច្នេះប្រជាជនយល់ដឹងនិងគាំទ្រតុលាការនេះ ។ ការចូលរួមរបស់ប្រជាជនធ្វើឲ្យមានការពិភាក្សាធ្វើឲ្យប្រជាជនមានអារម្មណ៍ធូរស្បើយយល់ព្រមអធ្យាស្រ័យគ្នាទៅវិញទៅមក ។ ការនាំជនជាប់ចោទវិលត្រឡប់ទៅជំនុំជម្រះក្តីនៅទីកន្លែងដែលឧក្រិដ្ឋជនបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម គឺជាការលើកតម្កើងសិទ្ធិនិងលើកទឹកចិត្តដល់ជនរងគ្រោះ ។ ដំណើរការរបស់តុលាការកាឆាឆា ទាំងការសារភាពនិងការដាក់ទោស អាចជួយឲ្យមានការអភិវឌ្ឍភូមិស្រុក និងបង្ហាញអ្នកភូមិអំពីអ្វីដែលបានកើតឡើង ។

អ្នកទោសដែលបានប្រព្រឹត្តខុសហើយយល់ព្រមសារភាពកំហុស នឹងត្រូវដោះលែងឲ្យមានសេរីភាពវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារវិញ ។

ពៀរ៉េត មុកាមូរិនហ្គូ មានទឹកចិត្តរីករាយចំពោះតុលាការប្រជាជន ។ មុកាមូរិនហ្គូ ត្រូវអ្នកជិតខាងចោទប្រកាន់ថាបានចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដូច្នេះគាត់ត្រូវចាប់ខ្លួន និងឃុំឃាំងអស់រយៈពេល៦ឆ្នាំ ។ នៅពេលនោះ មុកាមូរិនហ្គូ មានអាយុ១៦ឆ្នាំ ។ គាត់រៀបរាប់ថា “ខ្ញុំមិនបានប្រព្រឹត្តអំពើឧក្រិដ្ឋ ខ្ញុំពិតជាមិនដឹងថាត្រូវសារភាពរឿងអ្វីទេ ។ ខ្ញុំជាមនុស្សស្អាតស្អំ បាតដៃខ្ញុំអត់មានប្រឡាក់ឈាមអ្នកណាទេ ។ រដ្ឋាភិបាលក៏ដឹងហើយទទួលស្គាល់រឿងនេះដែរ ។ មិនមែនអ្នកជាប់ឃុំឃាំងទាំងអស់សុទ្ធតែបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ” ។ មុកាមូរិនហ្គូ បង្ហាញមុខក្នុងសវនាការរបស់តុលាការកាឆាឆាក្នុងជំហានសាកល្បង ។ អ្នកភូមិជឿអ្វីដែល មុកាមូរិនហ្គូ និយាយ ហើយបានយល់ព្រមដោះលែងគាត់ឲ្យមានសេរីភាព ។ ករណីខាងលើនេះក៏បានកើតឡើងនៅក្នុងសវនាការរបស់តុលាការកាឆាឆានៅ ហ្គីសេរូ ដែរ ។ នៅទីនោះ អ្នកភូមិជាជនជាតិទុតស៊ី បានជួយការពារនិងយល់ព្រមឲ្យតុលាការដោះលែងជនជាប់ចោទជាជនជាតិហ៊ូទូ ។

ទោះជាយ៉ាងនេះក្តីក៏នៅតែមានប្រជាជនរ្វ៉ាន់ដាមួយចំនួនមិនសប្បាយចិត្តចំពោះប្រព័ន្ធតុលាការកាឆាឆាដែរ ។ ចេនវៀ បូនីហ្សីម៉ាណា ជាអ្នកបើករថយន្តតាក់ស៊ីដែលបានបាត់បង់ឪពុកម្តាយ បងប្អូន៣នាក់ និងប្អូនស្រីម្នាក់ បាននិយាយថា តុលាការកាឆាឆាបង្កើតឡើងគឺសម្រាប់ជួយឧក្រិដ្ឋជនប្រល័យពូជសាសន៍ឲ្យគេចផុតពីមន្ទីរឃុំឃាំង ។ មនុស្សសម័យបុរាណប្រើប្រាស់តុលាការកាឆាឆាដើម្បីជំនុំជម្រះក្តីតូចតាចដូចជាករណីលួចគោក្របីជាដើម ។ ការយកតុលាការប្រជាជនមកអនុវត្តចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍គឺពិតជាមិនត្រឹមត្រូវឡើយ ។ បូណាវិនជឺ នីទីប៊ីហ្សី យល់ស្រប ជាមួយ បូនីហ្សីម៉ាណា ដែរ ។ ចំពោះ នីទីប៊ីហ្សី តុលាការកាឆាឆាគឺជាឆាកល្ខោនដែលរៀបចំដោយជនជាតិហ៊ូទូដើម្បី “ដោះលែងជនជាតិហ៊ូទូដែលមានកំហុសឲ្យចេញពីមន្ទីរឃុំឃាំង” ។

ប្រជាជនមួយចំនួនទៀតមិនគាំទ្រតុលាការតុលាការកាឆាឆា ដោយយល់ឃើញថា តុលាការនេះអាចបង្កឲ្យមានភាពស្មុគស្មាញនៅក្នុងភូមិ ។ ឧទាហរណ៍ ស្ត្រីមេម៉ាយនិងមនុស្សចាស់ជរាដែលគេចផុតពីការសម្លាប់នឹងភិតភ័យម្តងទៀតដោយសារតុលាការដោះលែងឧក្រិដ្ឋជនឲ្យវិលត្រឡប់ទៅរស់នៅក្នុងភូមិស្រុកជាមួយគាត់វិញ ។ អាល់ហ្វូសិន យូវីនម៉ាណា ជាស្ត្រីមេម៉ាយដែលបាត់បង់ប្តីនិងកូននៅក្នុងរបបប្រល័យពូជសាសន៍ រៀបរាប់ថា ÷

មានរឿងជាច្រើនដែលខ្ញុំមិនអាចបំភ្លេចបាន ។ ខ្ញុំបានដឹងអំពីការរំលោភលើរូបរាងកាយស្ត្រីទាំងចាស់ទាំងក្មេង ។ បើអ្នកបានដឹងរឿងនេះ ហើយឧបមាថារឿងនេះកើតលើរូបអ្នកវិញ ឥឡូវអ្នកដែលធ្វើបាបអ្នកបានត្រឡប់មករស់នៅក្នុងស្រុកភូមិជាមួយអ្នកវិញ ចុះបើថ្ងៃណាមួយមនុស្សម្នាក់នោះផឹកស្រាស្រវឹងរួចដើរនិយាយប្រាប់គេឯងពេញភូមិថា គាត់បានរំលោភអ្នកឯង តើអ្នកឯងគិតយ៉ាងម៉េច? គេថាតុលាការកាឆាឆាអាចជួយប្រជាជន តើវាជួយអ្វីកើតទៅ?

អ្នកជំនាញការបរទេសនិងក្រុមឃ្លាំមើលអំពីសិទ្ធិមនុស្សបានរិះគន់ភាពលម្អៀងរបស់តុលាការកាឆាឆា ។ ជនរងគ្រោះខ្លះមិនចាប់អារម្មណ៍និងមិនជឿថាតុលាការកាឆាឆាអាចធ្វើឲ្យខ្លួនអាចលាតត្រដាងនូវការពិត ហើយអាចផ្សះផ្សាបង្រួបបង្រួមរវាងជនរងគ្រោះនិងជនដៃដល់បានឡើយ ។ ប្រជាជនបារម្ភថាការពិតនៅតែមិនអាចដឹងដោយសារចៅក្រមមិនអព្យាក្រឹតនិងគ្មានចំណេះដឹងច្បាស់លាស់ផ្នែកច្បាប់ ។ ជនរងគ្រោះឈ្មោះ ថេរ៉េសា យូវិនហ្គាប៊ីយេ បាត់បង់កូនប្រុស៣នាក់និងកូនស្រីម្នាក់ រៀបរាប់ឲ្យដឹងថា “ខ្ញុំមិនជឿថាចៅក្រមអព្យាក្រឹតសោះ ។ បើឧក្រិដ្ឋជនជាសាច់ញាតិរបស់ចៅក្រមនោះចៅក្រមពិតជាមិនអាចរកស-ខ្មៅឃើញឡើយ” ។ មូកាសេរូ ក៏គ្មានជំនឿលើតុលាការកាឆាឆានិងចៅក្រមដែរ ។ មូកាសេរូ លើកករណីក្នុងគ្រួសារក្មួយរបស់គាត់ ដែលសមាជិកគ្រួសារស្លាប់ទាំងអស់ នៅសល់តែក្មួយប្រុសរបស់គាត់ម្នាក់អាយុ១៣ឆ្នាំ ។ មូកាសេរូ បារម្ភទីមួយខ្លាចក្មួយប្រុសរបស់គាត់មិនហ៊ានរៀបរាប់រឿងរ៉ាវដែលកើតឡើងប្រាប់តុលាការ ។ ទីពីរគាត់ខ្លាចតុលាការនិងចៅក្រមមិនជឿក្មួយរបស់គាត់ ។ “ចុះបើដូចករណីនេះ បើយើងនៅ

សល់តែក្មេងម្នាក់ជាសាក្សី ហើយអ្នកដទៃទៀតគឺជាសាច់ញាតិរបស់ឃាតករអេះអាងថា ឃាតករគ្មានកំហុស តើរឿងហ្នឹងវាទៅជាយ៉ាងណា?" ។

តាមការពិត ច្បាប់របស់តុលាការកាឆាឆាបានចែងយ៉ាងច្បាស់ដើម្បីទប់ទល់ការមិនទុកចិត្តនិងក្ដីបារម្ភរបស់ប្រជាជនអំពីភាពមិនលម្អៀងរបស់ចៅក្រម ។ អាន់តូនី វូប៊ីរីកា តំណាងក្រសួងយុត្តិធម៌ ពន្យល់អំពីវិធានការចំពោះភាពលម្អៀងថា ៖

ជនរងគ្រោះគិតថាគាត់នឹងត្រូវតុលាការសួរនាំសព្វគ្រប់អំពីអ្វីដែលបានកើតឡើង ។ ការពិតយើងដឹងថាគាត់មិនដឹងរឿងទាំងអស់ច្បាស់លាស់ទេ ព្រោះពួកគាត់រត់គេចខ្លួនពីការសម្លាប់ ។ អ្វីដែលយើងត្រូវការពីគាត់គឺព័ត៌មានដែលគាត់ដឹងប៉ុណ្ណោះ មិនមែនរឿងតាំងពីដើមដល់ចប់ឡើយ ។ ពេលបានដឹងព័ត៌មានយើងនិងសួរឧក្រិដ្ឋជនឲ្យឆ្លើយសារភាព ។

វិធានការផ្សេងទៀតរបស់រដ្ឋាភិបាលរួមមាន ទីមួយ ការបង្ហាត់បង្រៀនក្រមសីលធម៌ដល់ចៅក្រមទាំង២ម៉ឺន៦ពាន់នាក់បន្ទាប់ពីត្រូវបានជ្រើសរើស ។ ទីពីរមាត្រា៨២នៃច្បាប់របស់តុលាការកាឆាឆាបើកផ្លូវបណ្ដឹងឧទ្ធរណ៍ថ្នាក់ខេត្តបន្តទៀតក្នុងករណីមានការសង្ស័យឬមិនពេញចិត្តចំពោះការជំនុំជម្រះ ។ ជាមួយគ្នានេះ មាត្រា១៦និង៩០នៃច្បាប់ក៏បានចែងអំពីការទប់ស្កាត់ភាពមិនអព្យាក្រឹតរបស់ចៅក្រមដែរ ។ ឧទាហរណ៍ មាត្រា១៦កំណត់ថា ក្នុងករណីដែលចៅក្រមនិងឧក្រិដ្ឋជនគឺជាសាច់ញាតិនឹងគ្នា ការជំនុំជម្រះក្ដីត្រូវផ្ទេរទៅធ្វើនៅកន្លែងមួយទៀតដែលអព្យាក្រឹតជាងនេះ ។ មាត្រា៩០ បានចែងច្បាស់ថា ក្នុងករណីមានភាពមិនប្រក្រតីឬបាតុភាពកើតឡើង ក្រុមជំនួយការច្បាប់ជាអ្នកពិនិត្យនិងសម្រេចសំណុំរឿងនោះ ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជីន ឌី ដៀមូស៊ីយូ បន្ថែមថា "គ្រប់ករណីមិនពេញចិត្តប្រជាជនអាចប្ដឹងឧទ្ធរណ៍បាន" ។

អត្ថបទជាច្រើនដែលសិក្សាអំពីការផ្សះផ្សាបង្រួបបង្រួមបានសរសេរថា ការផ្សះផ្សាបង្រួបបង្រួម មិនមែនជាលទ្ធផលដែលងាយមើលឃើញឡើយ ។ ការផ្សះផ្សាបង្រួបបង្រួមគឺជាការស្វែងរកដែលទាមទារការប្ដេជ្ញាចិត្តនិងការសហការ ។ ដៀមូស៊ីយូ ហាក់ដូចជាសប្បាយចិត្តនឹងដំណើរការរបស់តុលាការកាឆាឆាទីមួយដោយសារតុលាការនេះអាចជួយដោះស្រាយបញ្ហាជនជាប់សង្ស័យដែល កំពុងតែជាប់ឃុំឃាំង និងទីពីរអាចនាំឲ្យប្រទេសរ៉្វាន់ដាមានសន្តិភាពក្នុងរយៈពេលពី៣ទៅ៥ឆ្នាំខាងមុខ ។

បទពិសោធន៍និងមេរៀនដែលកើតឡើងនៅប្រទេសរ៉្វាន់ដាបញ្ជាក់ច្បាស់ថា យុត្តិធម៌តាមផ្លូវតុលាការតែមួយមិនគ្រប់គ្រាន់សម្រាប់នាំមកនូវការផ្សះផ្សាបង្រួបបង្រួមឡើយ ។ តាមការបង្ហាញ និងឧទាហរណ៍ខាងលើការស្វែងរកយុត្តិធម៌មានភាពស្មុគស្មាញហើយតែងតែមានផលប៉ះពាល់លើធាតុដទៃផ្សេងទៀត ។ សន្តិភាពនិងការបង្រួបបង្រួមជាតិពិតប្រាកដសម្រាប់ប្រទេសរ៉្វាន់ដាត្រូវការជាចាំបាច់នូវការព្យាបាលរបួសផ្លូវចិត្តនិងការជឿទុកចិត្តគ្នាឡើងវិញ ។ ជនជាតិទុតស៊ីដែលនៅរស់ត្រូវតែមានជំនឿចិត្តលើជនជាតិហ៊ូទូដែលវិលត្រឡប់មករស់នៅក្នុងភូមិស្រុកជាមួយគាត់ម្ដងទៀត ។ ចំណែកជនជាតិហ៊ូទូត្រូវផ្ដាច់ខ្លួនឲ្យផុតពីគំនិតដែលយល់ថាខ្លួនឯងជាផ្នែកមួយនៃអំពើប្រល័យពូជសាសន៍ ហើយជឿថាជនជាតិទុតស៊ីពិតជាមិនសងសឹកមកលើខ្លួននិងក្រុមគ្រួសារឡើយ ។ តុលាការកាឆាឆា ហាក់ដូចជាមានតួនាទីសំខាន់ក្នុងការកសាងទំនុកចិត្តរបស់ប្រជាជនឡើងវិញ ។ បច្ចុប្បន្ននេះ តុលាការកាឆាឆាកំពុងតែដំណើរការ ដូច្នេះក្ដីសង្ឃឹមរបស់ប្រជាជនក្នុងការធ្វើដំណើរទៅរកភាពសុខដុមរមនានៅពេលអនាគតខាងមុខគឺអាស្រ័យទាំងស្រុងលើការជឿនិងការចូលរួមរបស់ប្រជាជននៅក្នុងដំណើរការនេះ ។

មេរៀននិងបទពិសោធន៍ពីប្រទេសរ៉្វាន់ដាគឺយុត្តិធម៌តាមផ្លូវតុលាការតែមួយមិនគ្រប់គ្រាន់ក្នុងដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិឡើយ ។ ផ្នែកបន្ទាប់នៃអត្ថបទសិក្សានេះនឹងវិភាគអំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានកាប់សម្លាប់ប្រជាជនកម្ពុជាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ នៅប្រទេសកម្ពុជា ។ តើតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតែមួយគ្រប់គ្រាន់ឬមិនគ្រប់គ្រាន់សម្រាប់ដំណើរការផ្សះផ្សាបង្រួបបង្រួមជាតិនៅប្រទេសកម្ពុជា? ***(នៅមានត)***

**អៀ ម៉េងទ្រី**

# ការកំណត់និយមន័យថ្មីនៃ "អំពើប្រល័យពូជសាសន៍"

## សេចក្តីផ្តើម

សតវត្សរ៍ទី២០គឺជាសម័យកាលដែលបង្ហូរឈាមខ្លាំងក្លាបំផុតនៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ។ សម័យកាលនេះ ត្រូវញាំញីដោយមហាសង្គ្រាមលោកពីរ និងសង្គ្រាមត្រជាក់រវាងប្រទេសមហាអំណាចពីរដែលដណ្តើមអំណាចកាប់កាប់ប្រទេសក្រីក្រនិងប្រទេសក្រោមអាណានិគម ។ ក្នុងសម័យសង្គ្រាមលោកលើកទី១ រដ្ឋាភិបាលទួរគីបានបំភិតបំភ័យពិភពលោកដោយបង្កការសម្លាប់យ៉ាងរង្គាលមួយ នៅក្នុងសម័យទំនើបនេះគឺសម្លាប់ជនជាតិអារមេនីនៅក្នុងប្រទេសទួរគី ។ ដោយមិនធ្លាប់ជួបប្រទះនូវឧក្រិដ្ឋកម្មបែបនេះ ពិភពលោកបានឈរសម្លឹងមើលដោយមិនអាចជួយអ្វីបានសោះ ព្រោះប្រហែលជាស្មានមិនដល់អំពីវិសាលភាពនៃអំពើនេះ ។ រហូតដល់សង្គ្រាមលោកលើកទី១រលត់ទៅទើបការពិតត្រូវបានលាតត្រដាងឡើង ក៏ប៉ុន្តែឧក្រិដ្ឋកម្មនេះមិនទាន់ត្រូវបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិដែលកំពុងតែបង្កើតឡើងនៅឡើយទេ ។ នៅក្នុងសម័យសង្គ្រាមលោកទី២ ជនជាតិជ្វីហ្វ៦លាននាក់ត្រូវទាហានណាហ្ស៊ីអាល្លឺម៉ង់សម្លាប់ក្រោមផែនការធ្វើឲ្យអាល្លឺម៉ង់ក្លាយជាប្រទេសមហាអំណាចមួយដែលគ្មានជនជាតិជ្វីហ្វនិងសមាសភាពដែលខុសនឹងបំណងរបស់ខ្លួន ។ នៅសូវៀត ស្តាលីន បានបង្អត់អាហារនិងសម្លាប់ប្រជាជនសូវៀតអស់រាប់លាននាក់ ដោយចាត់ទុកប្រជាជនទាំងនោះជាមនុស្សគ្រោះថ្នាក់សម្រាប់របបរបស់ខ្លួន ។ ជប៉ុនបានសម្លាប់ជនជាតិចិន ចាប់រំលោភស្ត្រី និងចាប់ស្ត្រីជនជាតិចិននិងកូរ៉េមកធ្វើជាទាសី ។ សង្គ្រាមពិតជាគ្មានមេត្តា ។ ទីក្រុងដ្រេស្តេន និងហាមបឺ ត្រូវបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែករបស់ភាគីទាំងពីរ ។ សង្គ្រាមលោកលើកទី២បានបញ្ចប់ដោយការទម្លាក់គ្រាប់បែកបរមាណូចំនួនពីរគ្រាប់របស់អាមេរិកមកលើទីក្រុងហ៊ីរ៉ូស៊ីម៉ា និង ណាហ្គាសាគី នៃប្រទេសជប៉ុន ។

ការបំផ្លាញជនជាតិជ្វីហ្វសញ្ជាតិអ៊ឺរ៉ុប និងការគិតអំពីបញ្ហាអធិបតេយ្យភាពរដ្ឋដែលបណ្តាលឲ្យមេដឹកនាំជាច្រើននាក់ហ៊ានសម្លាប់ប្រជាជនខ្លួនឯង បានដាស់ពិភពលោកទាំងមូលឲ្យបញ្ឈប់ការសម្លាប់រង្គាលដោយការបង្កើតអនុសញ្ញាប្រល័យពូជសាសន៍ដែលចូលជាធរមានឆ្នាំ១៩៤៨របស់អង្គការសហប្រជាជាតិ ។ ពិភពលោកបានសន្យាថានឹងមិនឲ្យមានឧក្រិដ្ឋកម្មបែបនេះកើតមានឡើងសាជាថ្មីម្តងទៀតឡើយក្នុងសង្គមមនុស្ស ។ អំពើប្រល័យពូជសាសន៍នៅតែកើតឡើងជាច្រើនលើកច្រើនសា សូម្បីតែនៅដើមទសវត្សរ៍ឆ្នាំ១៩៩០នៅក្នុងតំបន់អ៊ឺរ៉ុបដែលមានអារ្យធម៌ខ្ពស់ ជនជាតិស៊ែបប្រឆាំងជនជាតិមូស្លីមដោយដាក់ជនជាតិមូស្លីមទាំងនោះនៅក្នុងជំរំប្រមូលផ្តុំដែលមានលក្ខណៈស្រដៀងនឹងជំរំប្រមូលផ្តុំរបស់ណាហ្ស៊ី ។ អំពើប្រល័យពូជសាសន៍នៅដាហ្វ៊ួរនៅតែបន្តមាន ។ នៅមានការភាន់ច្រឡំក្នុងការប្រើពាក្យ "ប្រល័យពូជសាសន៍" ។ វាមិនមែនជាការងាយស្រួលក្នុងការទប់ស្កាត់ បញ្ឈប់ ឬបំបាត់អំពើប្រល័យពូជសាសន៍ដូចដែលយើងបានគិតនោះទេ ។ បញ្ហាសំខាន់គឺការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ ។ និយមន័យនៃអំពើប្រល័យពូជសាសន៍ដែលកំណត់ដោយអង្គការសហប្រជាជាតិគឺជានិយមន័យដែលយកជាផ្លូវការ ។ ចាប់តាំងពី រ៉ាហ្វែល លឹមគីន បង្កើតពាក្យនេះជាលើកដំបូងក្នុងឆ្នាំ១៩៤៤ អំពើប្រល័យពូជសាសន៍ ត្រូវបានយល់ឃើញផ្សេងៗគ្នា ។ តើយើងមិនអាចកំណត់និយមន័យអំពើប្រល័យពូជសាសន៍បានដោយសារពាក្យនេះគួរឲ្យភ្ញាក់ផ្អើលខ្លាំងពេកឬ ដោយសារមូលហេតុផ្សេងទៀត? អត្ថបទនេះព្យាយាមកំណត់និយមន័យថ្មីនៃ "អំពើប្រល័យពូជសាសន៍" ។ នេះមានន័យថា គួរតែចាប់ផ្តើមដោយការពិនិត្យនិយមន័យមុនៗ ។

## ហេតុអ្វីគួរតែកំណត់និយមន័យអំពើប្រល័យពូជសាសន៍សាជាថ្មី?

ក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីអំពីការទប់ស្កាត់និងការផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានអនុម័តនៅឆ្នាំ១៩៤៨ អំពើប្រល័យពូជសាសន៍ត្រូវបានកំណត់ក្នុងមាត្រា២ថា ÷

"...អំពើណាមួយនៃអំពើខាងក្រោមនេះ ដែលបានប្រព្រឹត្ត

ដោយមានចេតនាបំផ្លាញទាំងស្រុងឬដោយផ្នែកដល់សញ្ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនាណាមួយ ÷

ក) សម្លាប់សមាជិកនៃក្រុម

ខ) បង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរលើរូបរាងកាយ និងផ្លូវចិត្តរបស់សមាជិកនៃក្រុម

គ) បង្ខំឲ្យរស់នៅក្នុងស្ថានភាពមួយដែលដឹងថាមានគ្រោះថ្នាក់ដែលអាចនាំឲ្យមានការបំផ្លិចបំផ្លាញក្រុមមួយទាំងស្រុង ឬដោយផ្នែក

ឃ) ដាក់បង្ខំនូវវិធានការនានាសំដៅរារាំងការផ្តល់កំណើតនៅក្នុងក្រុម

ង) ផ្ទេរកុមារនៃក្រុមមួយទៅក្រុមមួយទៀតដោយបង្ខំ ។

មានកន្លះខាតមួយចំនួនតូចក្នុងការកំណត់និយមន័យនេះ ។ ជាដំបូង ឆក និង ចូណាសាន់ បានស្នើឲ្យប្រើពាក្យប្រល័យពូជសាសន៍ក្នុងន័យទូលំទូលាយទៅតាមស្ថានភាពដែលមិនសូវពាក់ព័ន្ធ ។ ការភាន់ច្រឡំនេះកើតឡើងដោយសារតែធាតុផ្សំនៅក្នុងនិយមន័យនេះ ។ ធាតុផ្សំពីចំណុច (ក) ដល់ចំណុច (ង) រួមបញ្ចូលទាំងការប្រព្រឹត្តដែលបណ្តាលឲ្យស្លាប់និងដែលមិនបណ្តាលឲ្យស្លាប់ ផ្តល់លទ្ធភាពដល់បុគ្គលជាច្រើនលើកមតិប្រឆាំងនឹងសកម្មភាពមួយចំនួនដូចជា ការពន្យារកំណើត ការលាយឡំវប្បធម៌គ្នា និងការលុបបំបាត់ភាសាឬសាសនាណាមួយ ។ល ។ ដើម្បីបង្កើតអនុសញ្ញាប្រល័យពូជសាសន៍ឡើង ។ មានមនុស្សជាច្រើនបានបង្ហាញឲ្យឃើញថា នយោបាយគ្រួសារមួយមានកូនមួយរបស់ចិនគឺមានលក្ខណៈប្រល័យពូជសាសន៍ ពីព្រោះចិនកំណត់ និងកាត់បន្ថយកំណើនភាគណាមួយនៃក្រុមជាតិពន្ធុរបស់ចិន ។ ក៏ប៉ុន្តែគោលបំណងពិតរបស់ប្រទេសចិនគឺកាត់បន្ថយកំណើនប្រជាជនដ៏ច្រើនរបស់ខ្លួនដែលជាបញ្ហាធំមួយសម្រាប់កំណើនរយៈពេលយូរ ។ ទីពីរ ការសម្លាប់ជាតិពន្ធុដែលមានក្នុងធាតុផ្សំពីចំណុច (ក) ដល់ចំណុច (ង) ក៏ជាផ្នែកមួយនៃការកំណត់និយមន័យដែលអ្នកប្រាជ្ញជាច្រើននាក់បានបដិសេធ ។

ទីបី ជាទូទៅនិយមន័យខាងលើនេះរាប់បញ្ចូលតែបួនក្រុមដែលត្រូវការពារ ហើយក្រុមនយោបាយដែលជាក្រុមរងគ្រោះដ៏សំខាន់ចាប់តាំងពីសង្គ្រាមលោកលើកទីពីរគួរតែរាប់បញ្ចូល ។ ជនដៃដល់នៃអំពើប្រល័យពូជសាសន៍បានព្យាយាមធ្វើឲ្យក្រុមដែលត្រូវការពារទាំងបួននោះក្លាយជាជនរងគ្រោះដោយសំអាងលើហេតុផលនយោបាយដូចដែលក្រុមគណៈប្រតិភូនៃប្រទេសបារាំងបានទស្សន៍ទាយជាមុន ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងករណីនេះ អនុសញ្ញាប្រល័យពូជសាសន៍ពិតជាមិនអត់ប្រយោជន៍ទេ ។ បួនក្រុមដែលត្រូវបានការពារមានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងក្រុមនយោបាយដូចដែល ឃុបពើ បានកត់សម្គាល់នៅក្នុងករណីជាច្រើន ។ ប្រសិនបើក្រុមជនរងគ្រោះជាសមាជិកនៃសញ្ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬក្រុមសាសនាណាមួយ អនុសញ្ញាប្រល័យពូជសាសន៍នៅតែអាចបង្កើតឡើងបានដែរ បើទោះជាជនដៃដល់អះអាងថាជនរងគ្រោះរបស់ខ្លួនមានការជាប់ពាក់ព័ន្ធនឹងនយោបាយក៏ដោយ (នេះគឺជាបញ្ហានៃការបង្ហាញអត្តសញ្ញាណជនរងគ្រោះរបស់ ឆក និង ចូណាសាន់ តាមរយៈការមើលឃើញរបស់ជនដៃដល់) ។ បញ្ហានេះមានការលំបាកជាងក្នុងការបង្ហាញនូវទោសកំហុសប្រសិនបើក្រុមនយោបាយត្រូវបានកំណត់យ៉ាងប្រាកដនោះ ។ ក៏ប៉ុន្តែអាចថាក្រុមនយោបាយអាចរងគ្រោះដោយមូលហេតុបន្សុទ្ធកម្មផ្នែកនយោបាយ ។ ក្រុមសេដ្ឋកិច្ចសង្គមនិងក្រុមផ្សេងៗទៀតគួរតែត្រូវរាប់បញ្ចូល ។

អ្នកសង្កេតការណ៍ជាច្រើនបាននិយាយថា ការសម្រុះសម្រួលមួយត្រូវបានធ្វើឡើង ពិភាក្សាដកក្រុមនយោបាយចេញពីនិយមន័យនេះដើម្បីធានាសច្ចានុម័តអតិបរិមាដោយរដ្ឋជាសមាជិកដែលភ័យខ្លាចប្រទេសខាងក្រៅការលូកដៃចូលគាបសង្កត់គំនិតខ្វែងយោបល់ផ្ទៃក្នុងរបស់ខ្លួនតាមរយៈអនុសញ្ញានេះ ។ បើគ្មានការគាំទ្រពីរដ្ឋជាសមាជិកទេ អនុសញ្ញាប្រល័យពូជសាសន៍ក៏មិនកើតឡើងដោយជោគជ័យដែរ ។ ទោះបីជាយ៉ាងណាក៏ដោយដូចដែល ឃុបពើ បានកត់សម្គាល់ការជ្រៀតជ្រែកចូលក្នុងរដ្ឋអធិបតេយ្យដើម្បីការពារក្រុមរងគ្រោះគឺជាបំណងសំខាន់របស់អនុសញ្ញាប្រល័យពូជសាសន៍ ។ នេះបញ្ជាក់ថាកង្វះក្រុមនយោបាយមានការទាក់ទិននឹងបរាជ័យនៃអនុសញ្ញានេះ ។

ជាចុងក្រោយ ការរាប់បញ្ចូលនិងការមិនរាប់បញ្ចូលក្នុងពេលដំណាលគ្នាហាក់ដូចជាបង្កឲ្យមានបញ្ហាផ្សេងៗទៀត ។ ការដាក់បញ្ចូលនូវធាតុផ្សំលើរូបកាយពុំសូវទទួលបានការយកចិត្តទុក

ដាក់ពីគោលបំណងសំខាន់នៃអនុសញ្ញាឡើយ មានដូចជាការសម្លាប់ក្រុមនោះទាំងស្រុងឬដោយផ្នែក ។ ការសម្លាប់រង្គាលក្នុងប្រទេសដែលមិនរាប់បញ្ចូលក្រុមនយោបាយនិងដែលត្រូវបានអនុវត្តក្រោមមូលហេតុពីរក្នុងចំណោមមូលហេតុបួនដែលនិយាយនៅក្នុងអនុសញ្ញានេះ កម្រត្រូវបានកត់សម្គាល់ដោយពិភពខាងក្រៅណាស់ ពីព្រោះជនដែលអាចនឹងបង្ហាញឲ្យឃើញថានោះគឺជាការគាបសង្កត់ផ្នែកនយោបាយ ។ សហគមន៍អន្តរជាតិនឹងចេញមកដោះស្រាយនៅពេលណាដែលបញ្ហានេះកាន់តែធំដែលអាចឈានដល់ការជម្លៀសជនភៀសខ្លួនចូលទៅប្រទេសជិតខាងដែលជាស្ថានភាពមួយតែងតែជួបប្រទះ ។ ដូចនេះ អនុសញ្ញានេះមិនអាចកំណត់និយមន័យអំពើប្រល័យពូជសាសន៍ឲ្យតូចទៅតាមការប្រើប្រាស់ពាក្យពេចន៍របស់ខ្លួនបានឡើយ ។ ជាមួយនឹងទស្សនៈទូទៅចំពោះអំពើប្រល័យពូជសាសន៍ដែលស្រដៀងទៅនឹង ហូឡូខូស (ការសម្លាប់រង្គាលជនជាតិជ្វីហ្វនៅអឺរ៉ុប ដោយណាហ្ស៊ីអាល្លឺម៉ង់) ឬក៏ការបំផ្លាញទាំងស្រុងនូវសញ្ជាតិជាតិពន្ធ ឬពូជសាសន៍មួយ គឺមានទំនោរមួយមិនបកស្រាយនិយមន័យប្រល័យពូជសាសន៍តាមផ្លូវច្បាប់ថាជាការបំផ្លាញលើរូបរាងកាយនៃក្រុមមួយឡើយ ។ បន្ថែមពីនេះ ការបកស្រាយមិនត្រឹមត្រូវនេះដែលត្រូវបានស្គាល់យ៉ាងច្បាស់នោះគឺថា តើមតិសាធារណៈយល់ពាក្យប្រល័យពូជសាសន៍យ៉ាងដូចម្តេចពីព្រោះការបកស្រាយអត្ថន័យនៃពាក្យនេះបង្ហាញថា ការបង្កើតពាក្យដែលច្របូកច្របល់គ្នាដូចជា "ការសម្លាប់រង្គាលនៃអំពើប្រល័យពូជសាសន៍" ដើម្បីឲ្យស្របទៅនឹងស្ថានភាពដែលមានតែមួយផ្នែកតូចនៃក្រុមនោះត្រូវបានបំផ្លិចបំផ្លាញ ។

ដូចដែលយើងបានឃើញនៅក្នុងការកំណត់និយមន័យថ្មីនៃអត្ថបទនេះ ដំណោះស្រាយយ៉ាងសាមញ្ញគឺ ៖ លុបចោលធាតុផ្សំលើរូបកាយមួយចំនួននិងពង្រីកបន្ថែមក្រុមដែលត្រូវការពារ ។

### គោលការណ៍ដើមរបស់ លីមគីន

នៅឆ្នាំ១៩៣៣ លីមគីន បានដាក់សំណើទៅសន្និសីទអន្តរជាតិ សម្រាប់ការបង្រួបបង្រួមច្បាប់ព្រហ្មទណ្ឌនៅទីក្រុងម៉ាឌ្រីដ សុំឲ្យមានការប្រមូលចងក្រងជាច្បាប់តែមួយនូវអ្វីដែលក្រោយមកលោកហៅថា "អំពើសាហាវព្រៃផ្សៃ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ" ដើម្បីហាមប្រាមការលុបបំបាត់សាសនាជាតិពន្ធ និងពូជសាសន៍ ។ សំណើរបស់ លីមគីន ផ្តោតជាសំខាន់លើការសម្លាប់ជនជាតិអារមេនីក្នុងអំឡុងសង្គ្រាមលោកលើកទី១ និងក្រើនរំឭកដល់សន្និសីទអំពីការឡើងកាន់អំណាចរបស់ ហ៊ីត្លែរ ។ លីមគីន កំណត់អត្ថន័យ"អំពើសាហាវព្រៃផ្សៃ"ថាជា"ការបំផ្លាញដោយចេតនានូវជាតិពន្ធ ពូជសាសន៍ ឬសាសនា នៃក្រុមមួយ" និង"ការបំផ្លាញទ្រព្យសម្បត្តិ"ថា "ការបំផ្លិចបំផ្លាញស្នាដៃសិល្បៈនិងវប្បធម៌ដែលបង្ហាញអំពីទេពកោសល្យរបស់ក្រុមទាំងនោះ" ។


ពីឆ្វេងទៅស្តាំ ៖ ខកញ៉ា ឃ្មួ កែតាំ, លោក ឆាំង យុ (នាយកមជ្ឈមណ្ឌល
នៅវាលពិឃាតបឹងជើងឯក

ដោយសារថាឧក្រិដ្ឋកម្មនេះបានប្រមាថទៅដល់មនសិការរបស់មនុស្ស លីមគីន ស្នើសុំឲ្យទប់ស្កាត់ឧក្រិដ្ឋកម្មនេះក្រោមដែនសមត្ថកិច្ចសកល ទោះជាកើតឡើងនៅទីណាឬពេលណាក្តី ដោយមិនគិតដល់ព្រំដែនរដ្ឋឡើយ ។ ក្នុងអំឡុងពេលសង្គ្រាមជាពេលដែលរដ្ឋជាច្រើនមានការព្រួយបារម្ភខ្លាំងពេកពីកិច្ចការផ្ទៃក្នុងរបស់ខ្លួន សំណើរបស់ លីមគីន ត្រូវបានយកមកពិចារណា ក៏ប៉ុន្តែមិនត្រូវបានយកមកអនុវត្តឲ្យបានដិតដល់ទេ ។

នៅក្នុងសង្គ្រាមលោកលើកទី២ ខណៈដែលការគ្រប់គ្រងដ៏គួរឲ្យភ័យខ្លាចរបស់ណាហ្ស៊ីដូចនឹងអ្វីដែល លឹមគីន បានព្យាករណ៍ទុកតាំងពីទសវត្សរ៍ឆ្នាំ១៩៣០ សំណើរបស់ លឹមគីន ឲ្យជំនួសពាក្យ "អំពើប្រល័យពូជសាសន៍" ដោយពាក្យ "អំពើសាហាវព្រៃផ្សៃ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ" បានក្លាយជាការពិត ពីព្រោះថាឧក្រិដ្ឋកម្មរបស់ណាហ្ស៊ីបង្ហាញឲ្យឃើញយ៉ាងច្បាស់នូវហេតុការណ៍ពីមុនដែលជាការបំផ្លិចបំផ្លាញក្រុមណាមួយ ។ លឹមគីន បានពន្យល់ "អំពើប្រល័យពូជសាសន៍" ថាជា "ផែនការមួយនៃសកម្មភាពជាច្រើនដែលមានគោលដៅបំផ្លិចបំផ្លាញមូលដ្ឋានជីវិតនៃក្រុមមួយក្នុងគោលបំណងលុបបំបាត់ក្រុមនោះ" ។ លឹមគីន មានបំណងការពារគ្រប់ក្រុមទាំងអស់ រួមទាំង "រូបរាងកាយ ជីវិតនយោបាយ សង្គម វប្បធម៌ សេដ្ឋកិច្ច និងសាសនា" ។ ដោយជឿជាក់ថា ដើម្បីបង្កើតបានវប្បធម៌មួយត្រូវការពេលវេលារាប់ពាន់ឆ្នាំ លឹមគីន ចាត់ទុកការបំផ្លិចបំផ្លាញវប្បធម៌ជាប្រភេទទីពីរនៃអំពើប្រល័យពូជសាសន៍ដែលក្រោយមកត្រូវបានស្គាល់ថាជា "ការបំផ្លាញជាតិពន្ធ" ។ ប្រភេទទីមួយនៃអំពើប្រល័យពូជសាសន៍ គឺការលុបបំបាត់ទាំងស្រុងឬស្ទើរតែទាំងស្រុងនូវក្រុមមួយ ហើយអំពើប្រល័យពូជសាសន៍ប្រភេទទីបី គឺការបញ្ចូលគ្នារវាង "ការសម្លាប់រង្គាល" និង "ការលុបបំបាត់វប្បធម៌" ។



ឯកសារកម្ពុជា ) និងលោក ពុតលី

មានចំណុចពីរដែលគួរកត់សម្គាល់នៅក្នុងគោលការណ៍ដើមរបស់ លឹមគីន ។ ចំណុចទីមួយ លឹមគីន មានបំណងការពារគ្រប់ក្រុមទាំងអស់នៅក្នុងប្រទេសមួយ (ដែលនឹងរាប់ចូលក្នុងនិយមន័យថ្មីនេះ) ។ ចំណុចទីពីរ លឹមគីន រាប់បញ្ចូល "ការសម្លាប់ជាតិពន្ធ" ថាជា "អំពើប្រល័យពូជសាសន៍" ។ នៅក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៤៨ មាននិយាយអំពីទិសដៅចម្បងរបស់ លឹមគីន ។ អនុសញ្ញានេះរាប់បញ្ចូល ជាតិពន្ធ និងអំពើនៅក្នុងចំណុច (ក) និងចំណុច (ង) ជាវិធានការដោយផ្នែកមួយក្នុងការការពារវប្បធម៌ ។ ស្របពេលជាមួយគ្នានេះដែរ អនុសញ្ញានេះក៏បានបញ្ចូលក្រុមទាំងបួនដែលត្រូវបានការពារទៅក្នុងបញ្ជីរបស់ខ្លួន ។

បើត្រឡប់ទៅមើលកាលពីដើមសតវត្សរ៍ទី១៩ លឹមគីន ប្រហែលជាយល់ឃើញត្រូវដែលថាវប្បធម៌គឺជាវត្ថុមានតម្លៃដែលត្រូវការពេលវេលាយូរដើម្បីបង្កើតឡើង ។ នៅក្នុងពិភពលោកបច្ចុប្បន្នដែលយើងឃើញមានការបែងចែកនិងការបញ្ចូលគ្នារវាងវប្បធម៌ចាស់និងថ្មី វប្បធម៌ហាក់ដូចជាងាយប្រែប្រួលនិងមិនអាចការពារបាន ។ ការឲ្យទម្ងន់នៃ "ការបំផ្លិចបំផ្លាញវប្បធម៌" ស្មើនឹង "អំពើប្រល័យពូជសាសន៍" ហាក់ដូចជាចម្លែក ។ សម្រាប់ លឹមគីន នេះមិនមែនជាការមិនគោរពឡើយ ។ ដូចដែលប្រតិភូមួយចំនួននិយាយថា "គ្មានគំនិតជាក់លាក់ស្តីពីអំពើប្រល័យពូជសាសន៍នោះទេ..." អំពើប្រល័យពូជសាសន៍ គឺជាអ្វីដែលស្មុគស្មាញ ។

## និយមន័យអំពើប្រល័យពូជសាសន៍បង្ហាញដោយអ្នកប្រាជ្ញនានា

ជាមួយនឹងកង្វះខាតនិយមន័យស្តីពីអំពើប្រល័យពូជសាសន៍នៅក្នុងអនុសញ្ញា និងបរាជ័យរបស់អនុសញ្ញានេះក្នុងការរារាំងអំពើប្រល័យពូជសាសន៍ តើអ្នកប្រាជ្ញកំណត់និយមន័យថ្មីនៃអំពើប្រល័យពូជសាសន៍តាមរបៀបណា?

ហ៊ីហ្ សាវិន បានសង្កត់ធ្ងន់លើវិបាកនិងចំណង់របស់ឧក្រិដ្ឋ

ជន ។ ដូចនេះ គាត់ចាត់ជាប្រភេទ : អំពើប្រល័យពូជសាសន៍ដោយការជំនួសអំពើប្រល័យពូជសាសន៍ដោយការបំផ្លិចបំផ្លាញ អំពើប្រល័យពូជសាសន៍ដោយការបំផ្លិចបំផ្លាញទាំងស្រុង ។ អៀវីង លុី ហូរ៉ូវីត ពេញចិត្តនឹងរបៀបដែលធ្វើឡើងដោយរដ្ឋ ។ អៀវីង ឲ្យនិយមន័យអំពើប្រល័យពូជសាសន៍ថាជា "ការបំផ្លិចបំផ្លាញជាប្រព័ន្ធមកលើប្រជាជនស្លូតត្រង់ដោយការិយាធិបតេយ្យរបស់រដ្ឋ" ។ ផ្អែកលើស្ថានភាពសង្គម អៀវីង ចាត់ទុកសង្គមដែលមាននិន្នាការផ្តេផ្តាសនិយមជ្រុលជាសង្គមប្រល័យពូជសាសន៍សង្គមដែលនៅកណ្តាលគឺជាសង្គមបែបសេរី និងសង្គមដែលប្រកាន់ស្តាំជ្រុលគឺជាសង្គមអនាធិបតេយ្យ ។ ហេតុដូច្នេះ អៀវីង សន្និដ្ឋានថា ការនិយមជ្រុលគឺមិនមែនជាមូលហេតុពិតប្រាកដនៃអំពើប្រល័យពូជសាសន៍នោះទេ ក៏ប៉ុន្តែវប្បធម៌ជាតិទេទើបជាមូលហេតុពិតប្រាកដ ។ ដូច្នោះហើយ វប្បធម៌នៃប្រទេសទួរគី អាល្លឺម៉ង់ កម្ពុជា រ៉្វាន់ដា យូហ្គោស្លាវី និងតំបន់ដាហ្វួរ ពុំសូវទន់ភ្លន់ដូចវប្បធម៌នៃប្រទេសផ្សេងៗទៀត នេះមិននិយាយពីអំពើប្រល័យពូជសាសន៍ប្រហែល៤០ទៀតដែលមិនចាត់ជាផ្លូវការស្នើឡើងដោយ ហ្វាហ្វ, ហ៊ើរ និង ហ្គ្រេហ្គោរី ស្តេនតុន ។ ជាងនេះទៅទៀតគំនិតរបស់លោក ហូរ៉ូវីត ផ្ទុយទៅនឹងគំនិតដែលថាមនុស្សអាចនឹងប្រព្រឹត្តអំពើអាក្រក់ ។

វ៉ាហាន ដាជ្រៀន ផ្តោតខ្លាំងទៅលើកង្វះតម្លាភាពរវាងក្រុមសង្គម និងសារជាតិនៃអំពើប្រល័យពូជសាសន៍បែបសម្ភារៈនិយម ។ លោកលើកឡើងថា អំពើប្រល័យពូជសាសន៍គឺជាការប្រព្រឹត្តក្រុមធំលើក្រុមតូច ។ ក៏ប៉ុន្តែ ការយល់ឃើញរបស់ ដាជ្រៀន មិនត្រឹមត្រូវឡើយ ព្រោះនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ ជនជាតិសឺបដែលមានចំនួនតែប្រហែល៣០ភាគរយនៃចំនួនប្រជាជនសរុបប៉ុណ្ណោះបានសម្លាប់ជនជាតិមូស្លីមដែលមានចំនួនច្រើនជាង ។ គំនិតរបស់ ដាជ្រៀន ដែលផ្អែកលើពិសោធន៍ជាក់ស្តែងត្រូវបានបង្ហាញភ្លាមៗថាមិនត្រឹមត្រូវខណៈដែលអំពើប្រល័យពូជសាសន៍មិនបានកើតឡើងតាមនិន្នាការនៃប្រវត្តិសាស្ត្រ ។ ការបែងចែករបស់ ដាជ្រៀន បណ្តាលមកពីភាពមិនស្របគ្នា និងរាប់បញ្ចូលទាំងអំពើប្រល័យពូជសាសន៍ និងដែលលាក់កំបាំងដោយនិងការសម្លាប់ជាតិពន្ធដោយអចេតនា ។

សង្គមវិទូដ៏ល្បីល្បាញម្នាក់ឈ្មោះ ហេឡែន ហ្វេន បាននិយាយថា :

"អំពើប្រល័យពូជសាសន៍គឺការសម្លាប់មួយផ្នែក ឬទាំងស្រុងនៃក្រុមមួយ ដែលត្រូវបានកំណត់ក្រៅពីការទទួលខុសត្រូវទាំងស្រុងរបស់ជនដៃដល់ ដោយរដ្ឋាភិបាល មេដឹកនាំ បុគ្គលិក ឬក្រុមមនុស្សមួយដែលតំណាងឲ្យជនដៃដល់ ដើម្បីឆ្លើយតបទៅនឹងវិបត្តិ ឬឱកាសដែលគិតថាបង្កឡើងដោយជនរងគ្រោះ ។"

និយមន័យនេះនិយាយអំពីការបំផ្លិចបំផ្លាញរូបរាងកាយ អំពើអមនុស្សធម៌ និងវិបត្តិក្នុងសង្គម ។ សង្គមវិទូ ហ្វេន ចុះក្នុងបញ្ជីនូវលក្ខខណ្ឌទាំងអស់ដែលគេស្គាល់ថាជាអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែអ្នកស្រីមានភាពច្បាស់លាស់ជាង ដោយរាប់បញ្ចូលតែការសម្លាប់តែប៉ុណ្ណោះ ។ ហ្វេន បានកំណត់ថា អំពើប្រល័យពូជសាសន៍ដែលកើតឡើងតែក្នុងអំឡុងមានវិបត្តិឬក្រោយពេលមានវិបត្តិ ពុំមែនត្រឹមតែជាការប្រព្រឹត្តរបស់រដ្ឋតែប៉ុណ្ណោះទេ ។ ទោះជាយ៉ាងនេះក្តី ពុំចាំបាច់និយាយអំពីវិបត្តិជារឿងទូទៅទេ ។ អំពើប្រល័យពូជសាសន៍ សង្គ្រាម ជម្លោះ និងភាពវឹកវរក្នុងសង្គមមិនអាចកើតឡើងដោយគ្មានមូលហេតុដើមនោះទេ ។

ឆាល និង ចូណាសសាន់ រិះគន់ យ៉ុបភើ ខុសចំពោះការរាប់បញ្ចូលការទម្លាក់គ្រាប់បែករបស់អាមេរិកលើទីក្រុងហ៊ីរ៉ូស៊ីម៉ា ណាហ្គាសាគី ទីក្រុងដ្រេស្តេន និងប្រទេសវៀតណាម ថាជាអំពើប្រល័យពូជសាសន៍ ។ អ្នកទាំងពីរភាន់ច្រឡំរវាងបំណងនិងចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ។ អ្នកទាំងពីរកំណត់អំពើប្រល័យពូជសាសន៍ថាជា"ទម្រង់នៃការសម្លាប់រង្គាលដែលដែលរដ្ឋឬអាជ្ញាធរមានបំណងបំផ្លាញក្រុមមួយដែលជនដៃដល់បានកំណត់ទុក" ។ និយមន័យនេះបានកំណត់អំពើប្រល័យពូជសាសន៍ថាជាការបំផ្លិចបំផ្លាញក្រុមមួយតាមរយៈការសម្លាប់ ។ ឆាល និង ចូណាសសាន់ ដោះស្រាយការលំបាកក្នុងការកំណត់ក្រុមនយោបាយ ដោយផ្អែកលើរបៀបដែលជនដៃដល់កំណត់អត្តសញ្ញាណក្រុមនោះ ។ ឆាល និង ចូណាសសាន់ អះអាងថា ត្រូវតែមានក្រុមមួយដែលជាជនរងគ្រោះ ដោយសារថាជនដៃដល់អាចកំណត់អត្តសញ្ញាណជនរងគ្រោះបាន ។ នេះជាដំណោះស្រាយដ៏ប្រសើរមួយប៉ុន្តែ ក៏អាចជាបញ្ហាដែរ ។ ក្រោមនិយមន័យនេះ កិច្ចខិតខំប្រឹងប្រែងរបស់

រដ្ឋាភិបាលក្នុងការលុបបំបាត់ក្រុមជនពាល អ្នកលក់ថ្នាំញៀន ក្រុមភេរវជន និងក្រុមដទៃទៀតដែលប្រឆាំងនឹងសង្គម អាចចាត់ទុកថាជាអំពើប្រល័យពូជសាសន៍ ពីព្រោះថា និយមន័យនេះនិយាយតែអំពីរបៀបដែលក្រុមមួយត្រូវបានកំណត់ ប៉ុន្តែមិនមែនអំពីចរិតពិតនៃក្រុមនោះឡើយ ។ ជនដៃដល់មិនដែលមើលឃើញជនរងគ្រោះថាជាក្រុមមួយឡើយ ប៉ុន្តែមើលឃើញថាជាសត្រូវនិងជាអ្នកប្រឆាំងនឹងសង្គមទៅវិញ ។ នេះមិនខុសពីរបៀបដែលយើងរៀបរាប់អំពីក្រុមប្រឆាំងនឹងសង្គមនោះទេ ។ ជាងនេះទៀត ការពិតដែលជនដៃដល់អាចរកឃើញជនរងគ្រោះរបស់ខ្លួនមិនមានន័យថាជនរងគ្រោះត្រូវតែមានវត្តមានជាក្រុមមួយនោះទេ ។ រោគឆ្កួតក៏ដើរតួនាទីសំខាន់ក្នុងបញ្ហានេះដែរ ។

យេហ៊ូដា ប៊ូអឺ ដោះស្រាយបញ្ហាដែលមិនអាចបែងចែកដាច់ពីគ្នារវាងហូឡូខូសនិងការសម្លាប់រង្គាលទ្រង់ទ្រាយតូច ដោយបែងចែកលក្ខខណ្ឌទាំងនេះក្រោមឈ្មោះផ្សេងៗគ្នាដូចជា ហូឡូខូស និងអំពើប្រល័យពូជសាសន៍ ។ នៅពេលនិយាយដល់ហូឡូខូស ប៊ូអឺសំដៅដល់“សកម្មភាពដែលបានគ្រោងទុកជាមុនសំដៅលុបបំបាត់សមាជិកទាំងឡាយនៃជនជាតិ ជាតិពន្ធ ឬពូជសាសន៍ណាមួយដោយហេតុផលសាសនាឬមនោគមវិជ្ជា” ។ ការកំណត់និយមន័យអំពើប្រល័យពូជសាសន៍របស់ ប៊ូអឺ ពុំសូវធ្ងន់ធ្ងរហើយអាចទទួលយកបានច្រើនជាង ។ និយមន័យនេះរួមបញ្ចូលការសម្លាប់ជាតិពន្ធ និងការបំផ្លាញដោយផ្នែកនូវពូជសាសន៍ ជនជាតិ ឬជាតិពន្ធណាមួយ ក្នុងគោលបំណងរារាំងការចូលសញ្ជាតិ ។ ក៏ប៉ុន្តែ ហ្វាហ្វ និង ហ្គឺរ ទិតៀនថា ការបែងចែករបស់ ប៊ូអឺ អាចនាំឲ្យមានជំនឿថា មានតែមនោគមវិជ្ជាបែបណាហ្ស៊ីដែលត្រូវយកមកប្រើក្នុងវប្បធម៌លោកខាងលិចទេទើបអាចលុបបំបាត់ពូជសាសន៍មួយហើយថា ប្រសិនបើគំនិតចាត់ទុកហូឡូខូសពិសេសដាច់ពីអំពើប្រល័យពូជសាសន៍ត្រូវបានទទួលស្គាល់គ្រប់ពេលនោះ ប្រជាជាតិដទៃទៀតមិនបាច់បារម្ភអំពីហូឡូខូសទេ បញ្ហានេះនឹងជាកង្វល់តែមួយគត់សម្រាប់ជនជាតិជ្វីហ្វនិងអាល្លឺម៉ង់ ។

មតិរិះគន់មួយទៀតដែលនិយាយអំពីការបែងចែកពាក្យអំពើប្រល័យពូជសាសន៍ ។ អំពើប្រល័យពូជសាសន៍មិនត្រឹមតែបង្កប់ភាពកាចសាហាវនិងអំពើយង់ឃ្នងរបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែវាមានតម្លៃជានិមិត្តរូប ។ អំពើប្រល័យពូជសាសន៍មានបង្កប់ក្នុងមហាវិនាសកម្ម ពីព្រោះពាក្យនេះកើតចេញពីហូឡូខូស ។ អំពើប្រល័យពូជសាសន៍ភ្ជាប់មកជាមួយនឹងរូបភាពគួរឲ្យរន្ធត់របស់ណាហ្ស៊ីនិងនិមិត្តរូបនៃការភ្ញាក់រឭករបស់ពិភពលោកចំពោះហូឡូខូស ។ អំពើប្រល័យពូជសាសន៍អាចនឹងបាត់បង់ទាំងស្រុងនូវអត្ថន័យសំខាន់ដោយសារតែការបែងចែកពាក្យនេះ ។ ការបែងចែកនេះបង្កឲ្យមានការយល់ច្រឡំអត្ថន័យនិងមានការលំបាកក្នុងការទទួលបានការគាំទ្រជាសាធារណៈសម្រាប់អន្តរាគមន៍អំពើប្រល័យពូជសាសន៍នាពេលអនាគត ។ ការអះអាងតែមួយនេះអាចទាក់ទិននឹងការបែងចែកពាក្យប្រល័យពូជសាសន៍របស់ ហ្វាហ្វ និង ហ្គឺរ នៅក្នុងអំពើប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលក្រុមនយោបាយ ។ ក្នុងករណីនេះ ពាក្យអំពើប្រល័យពូជសាសន៍មិនសូវត្រូវបានគេកត់សម្គាល់ឡើយ ។

ផ្អែកលើការសិក្សាអំពីការសម្លាប់រង្គាល លីមែន ឡិចជីអះអាងថា គួរតែរាប់បញ្ចូលក្រុមសេដ្ឋកិច្ចសង្គមកិច្ចទៅក្នុងនិយមន័យរបស់អង្គការសហប្រជាជាតិ ពីព្រោះប្រទេសសូវៀតបានកំណត់យកកសិករ យូឡាក់ ជាទិសដៅបំផ្លិចបំផ្លាញ សូម្បីនៅពេលខ្វះការកំណត់និយមន័យរបស់អង្គការសហប្រជាជាតិនិយាយអំពីការវាយប្រហារណាមួយរបស់សូវៀតមកលើ យូឡាក់ ដែលប្រឆាំងនឹងជនជាតិភាគតិចនិងជនជាតិសូវៀតក៏ដោយ ។ ឡិចជីគាំទ្រនិយមន័យរបស់អង្គការសហប្រជាជាតិដែលមិនរាប់បញ្ចូលក្រុមនយោបាយ ។

សរុបឲ្យខ្លី អ្នកប្រាជ្ញជាច្រើននាក់ដូចជា ដ្រូស, ហ្វេន, យុបជី, ហ្វាហ្វ និង ហ្គឺរ, លិចជី និង ប៊ូអឺ គាំទ្រនិយមន័យរបស់អង្គការសហប្រជាជាតិច្រើនជាង ។ និយមន័យរបស់អង្គការសហប្រជាជាតិពិតជាមិនអត់ប្រយោជន៍ ។ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ និយមន័យនេះត្រូវបានយកមកប្រើប្រាស់ដើម្បីកាត់ទោសឧក្រិដ្ឋជននៃអំពើប្រល័យពូជសាសន៍អស់ជាច្រើននាក់ដោយមានការគាំទ្រពីអន្តរជាតិ ។ មានសេចក្តីសម្រេចច្បាប់ជាច្រើនត្រូវបានតាក់តែងឡើង ។ ប្រការនេះពង្រីកប្រសិទ្ធភាពនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ក្នុងការទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ ទោះបីជាយ៉ាងណាក៏

ដោយ នេះមិនមែនមានន័យថាពុំចាំបាច់មានការធ្វើវិសោធនកម្មច្បាប់នោះទេ ។ បញ្ហានៅតែមានទោះជាមានគំរូច្បាប់ចំនួនប៉ុន្មានត្រូវបានបង្កើតឡើងក៏ដោយ ។

## និយមន័យតាមផ្លូវច្បាប់និងតាមសង្គមវិទ្យា

មានភាពខុសប្លែកគ្នារវាងការកំណត់និយមន័យតាមផ្លូវច្បាប់និងតាមសង្គមវិទ្យា ។ និយមន័យតាមផ្លូវច្បាប់ត្រូវបានកំណត់យ៉ាងច្បាស់លាស់និងសំខាន់ជាងក្នុងការទប់ស្កាត់និងកំណត់អត្តសញ្ញាណបទឧក្រិដ្ឋខុសពីនិយមន័យតាមសង្គមវិទ្យាដែលទូលំទូលាយជាងក្នុងការជួយដល់ផ្នែកស្រាវជ្រាវ ។ ក៏ប៉ុន្តែ អ្នកប្រាជ្ញមួយចំនួនមិនបានធ្វើការវែកញែករកភាពខុសគ្នាឡើយ ។

អ្នកប្រាជ្ញជាច្រើនផ្តោតខ្លាំងលើហេតុការណ៍ជាប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ និងបង្កើតនិយមន័យដោយបញ្ចូលចរិតលក្ខណៈដែលករណីនីមួយៗចែករំលែកគ្នាទៅវិញទៅមក ។ អ្នកប្រាជ្ញទាំងនេះមិនមានការខ្វល់ខ្វាយអំពីថ្ងៃអនាគត និងមិនបានព្យាករណ៍ទុកជាមុនថាតើការកំណត់និយមន័យនោះស្របទៅតាមស្ថានភាពនាអនាគតឬទេ ហើយនោះជាកំហុសដែលអង្គការសហប្រជាជាតិធ្លាប់បានប្រព្រឹត្តគឺការមិនបានរាប់បញ្ចូលក្រុមនយោបាយ ។ ផ្ទុយទៅវិញ និយមន័យក្នុងអត្ថបទនេះគឺសំដៅឆ្ពោះទៅរកអនាគត មានសភាពទន់ភ្លន់ និងស្របតាមបទដ្ឋានសីលធម៌ខ្ពស់ ដោយសង្កត់ធ្ងន់ទៅលើភាពសាហាវយង់ឃ្នងជ្រុលក្នុងការបំផ្លិចបំផ្លាញសមាជិកក្រុមមួយដោយសារតែអត្តសញ្ញាណនៃសមាជិកក្រុមនោះ ។

អ្នកប្រាជ្ញជាច្រើននាក់បារម្ភអំពីការសិក្សាប្រៀបធៀបអំពើប្រល័យពូជសាសន៍និងការកំណត់ទ្រឹស្តីអំពើប្រល័យពូជសាសន៍សម្រាប់ការស្រាវជ្រាវសង្គមវិទ្យា ។ និយមន័យរបស់អ្នកប្រាជ្ញទាំងនោះផ្តោតយកចិត្តទុកដាក់តិចតួចបំផុតលើអំពើសាហាវយង់ឃ្នង និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍ ។ អំពើប្រល័យពូជសាសន៍ប្រហែលមិនមែនជាព្រឹត្តិការណ៍សង្គមថ្មីចម្លែកដែលអាចកំណត់ជាទ្រឹស្តីបានទេ ។ វាអាចជាការសម្លាប់រង្គាលបែបហួសសម័យដែលប្រព្រឹត្តក្នុងយុគសម័យបុរាណនិងយុគសម័យកណ្តាល ។ ដោយសារពេលនេះយើងកំពុងតែស្ថិតក្នុងសម័យទំនើបនិងមានសីលធម៌ខ្ពស់ជាងមុនអំពើប្រល័យពូជសាសន៍គាន់តែត្រូវបានស្អប់ខ្ពើមនិងយកចិត្តទុកដាក់ ។ និយមន័យអំពើប្រល័យពូជសាសន៍គួរតែអាចទប់ស្កាត់អំពើនេះបានប្រសិនបើយើងពិតជាចង់ទប់ស្កាត់អំពើប្រល័យពូជសាសន៍មិនឲ្យកើតមានឡើងមែន ។ ឥឡូវនេះមានច្រកបើកសម្រាប់ការកំណត់និយមន័យថ្មីហើយ ។

## តើគួរតែកំណត់និយមន័យថ្មីនៃអំពើប្រល័យពូជសាសន៍តាមរបៀបណា?

បើរំពឹកឡើងវិញ ចន្លោះឆ្នាំ១៩១៥ដល់ឆ្នាំ១៩១៨ ជនជាតិអារមេនីជាង១លាននាក់ រាប់បញ្ចូលទាំងស្ត្រីនិងកុមារ ត្រូវ


ជនរងគ្រោះមើលកន្លែងតម្កល់អដ្ឋិធាតុអ្នកស្លាប់ក្នុងរបបខ្មែរក្រហមនៅ

បានលុបបំបាត់ចេញពីទឹកដីកំណើតរបស់ខ្លួនតាមរយៈការសម្លាប់រង្គាលរបស់រដ្ឋាភិបាលទួរគី ។ ពីឆ្នាំ១៩៣៨ដល់ឆ្នាំ១៩៤៥ ជនជាតិជ្វីហ្វសញ្ជាតិអឺរ៉ុប៦លាននាក់ត្រូវណាហ្ស៊ីអាល្លឺម៉ង់សម្លាប់ក្នុងគោលបំណងបង្កើតអាណាចក្រអាល្លឺម៉ង់ដ៏អស្ចារ្យមួយដែលមានតែជនជាតិអាល្លឺម៉ង់សុទ្ធសាធ ។ ពីឆ្នាំ១៩៣២ដល់ឆ្នាំ១៩៣៣ មេដឹកនាំផ្តាច់ការ ស្តាលីន ស្រេកឃ្លាននិងការសម្លាប់ជនជាតិអ៊ុយក្រែនចំនួន៧លាននាក់ ដែលនោះជាផ្នែកមួយនៃអំពើប្រល័យ

ពូជសាសន៍បែបមនោគមវិជ្ជាដែលបណ្តាលឲ្យពលរដ្ឋសូវៀត៦៦ លាននាក់បាត់បង់ជីវិតនៅចន្លោះឆ្នាំ១៩១៧និងឆ្នាំ១៩៥៧ ។ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ខ្មែរក្រហមបានធ្វើឲ្យប្រជាជនខ្មែរជិតពីរលាននាក់បាត់បង់ជីវិតដោយអនុវត្តនូវផែនការជ្រុលនិយមប្រែក្លាយប្រទេសកម្ពុជាក្នុងរយៈពេលតែមួយយប់ឲ្យទៅជាដែនដីកសិកម្ម ។ ពីឆ្នាំ១៩៩២ដល់ឆ្នាំ១៩៩៥ ជនជាតិមូស្លីម២ម៉ឺននាក់ត្រូវជនជាតិស៊ែបសម្លាប់ក្នុងអតីតប្រទេសយូហ្គោស្លាវី ។ ក្នុងឆ្នាំ១៩៩៤ ជនជាតិទុតស៊ីនិងហ៊ូទូ៨សែននាក់ត្រូវបានកាប់សម្លាប់


វាលពិឃាតបឹងជើងឯក

នឹងកាំបិតក្នុងរយៈពេលតែបីខែ ។ ក្រៅពីរឿងហេតុជាក់ស្តែងទាំងនេះ មានរឿងហេតុតូចជាងនេះនិងមិនសូវដឹងឮជាច្រើនទៀតដែលបង្ហាញដោយ ស្តេតុន និង ហ្វារហ្វ និង ហ្គឺរ ។ រឿងហេតុទាំងឡាយកើតឡើងនៅពេលវេលា ទីកន្លែង និងស្ថានភាពសង្គមនយោបាយផ្សេងៗគ្នា ក៏ប៉ុន្តែមានចរិតលក្ខណៈរួមមួយ គឺការបំផ្លិចបំផ្លាញមិនរើសមុខនិងជាប្រព័ន្ធទៅលើសមាជិកនៃក្រុមមួយ ។ ដូច្នេះដើម្បីប្រើប្រាស់និយមន័យដែលមានស្រាប់និងដែលទទួលស្គាល់ជាផ្លូវការរបស់អង្គការសហប្រជាជាតិ គួរតែកំណត់និយមន័យថ្មីនៃអំពើប្រល័យពូជសាសន៍ដូចខាងក្រោមនេះ ៈ

អំពើណាមួយក្នុងចំណោមអំពើខាងក្រោមនេះដែលបានប្រព្រឹត្តដោយមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកនូវក្រុមមួយ ÷

ក) ការសម្លាប់សមាជិកនៃក្រុម

ខ) បង្កការឈឺចាប់និងខូចខាតជាដំណំខាងផ្នែករាងកាយឬសតិបញ្ញាទៅលើសមាជិកទាំងឡាយក្នុងក្រុម ។

គ) ដាក់បង្ខំនូវវិធានការនានាសំដៅរារាំងការផ្តល់កំណើតទារកនៅក្នុងក្រុម

គោលការណ៍ជាមូលដ្ឋាននៃនិយមន័យនេះគឺ ការបំផ្លិចបំផ្លាញមិនរើសមុខនិងជាប្រព័ន្ធ លើសមាជិកនៃក្រុមមួយ ដោយសារអ្នកទាំងនោះជាសមាជិកនៃក្រុមនេះ ។ អំពើប្រល័យពូជសាសន៍បែបនេះលំដាប់ថ្នាក់ ។ វាអាចកើតឡើងក្នុងទម្រង់ជាអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយតូច ដែលមានតែជនរងគ្រោះមួយចំនួនតូចត្រូវសម្លាប់រង្គាលក្នុងរយៈពេលដ៏ខ្លីមួយ ឬក៏កើតឡើងក្នុងទម្រង់ជាអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំ ដែលមានជនរងគ្រោះមួយចំនួនធំត្រូវសម្លាប់ក្នុងរយៈពេលវែង ។ អំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំរួមមានការសម្លាប់ជនជាតិអារមេនី ការសម្លាប់រង្គាលជនជាតិជ្វីហ្វ វាលពិឃាតនៅកម្ពុជា និងការកាប់សម្លាប់ដោយកាំបិតដែលជនជាតិទុតស៊ីប្រព្រឹត្តមកលើជនជាតិហ៊ូទូនៅក្នុងប្រទេសរ៉្វាន់ដា ។ ទោះបីជាយ៉ាងក៏ដោយ ចំនួនជនរងគ្រោះមិនអាចកំណត់ទំហំនៃអំពើប្រល័យពូជសាសន៍មួយថាសាហាវតិចឬខ្លាំងជាងអំពើប្រល័យពូជសាសន៍មួយទៀតឡើយ ។ ការចាត់លំដាប់អំពើប្រល័យពូជសាសន៍ក្រោមឈ្មោះតែមួយអាចដោះស្រាយបញ្ហាដែល ប៉ូអឺ ប្រឈមមុខក្នុងការផ្តាច់ហូឡូខូសចេញពីអំពើប្រល័យពូជសាសន៍ ។

និយមន័យនេះអាចដោះស្រាយបញ្ហានៃការកំណត់និយមន័យរបស់អង្គការសហប្រជាជាតិ បានដោយបញ្ចូលក្រុមជនរងគ្រោះឲ្យស្របតាមគំនិតដើមរបស់អង្គការសហប្រជាជាតិ និងកម្មវត្ថុដំបូងរបស់ លីមគីន ក្នុងការការពារគ្រប់ក្រុមមនុស្សទាំងអស់ និងដោយកំណត់ធាតុផ្សំដែលមិនរាប់បញ្ចូលនូវស្នាកស្នាម

ទាំងឡាយពីការសម្លាប់ជាតិពន្ធ ។ តាមនិយមន័យនេះ ការសម្លាប់ជាប្រព័ន្ធមិនចំពោះមុខណាមួយដែលប្រព្រឹត្តដោយក្រុមមួយប្រឆាំងនឹងក្រុមមួយទៀតក្នុងពេលសង្គ្រាមឬសន្តិភាព ក៏អាចចាត់ថាជាអំពើប្រល័យពូជសាសន៍បានដែរ ។ នៅពេលដែលក្រុមមួយមានផែនការបំផ្លិចបំផ្លាញក្រុមមួយផ្សេងទៀត លទ្ធផលនៃការបំផ្លិចបំផ្លាញនេះអាចមានជនរងគ្រោះលើសពីពីរបីនាក់ ។ គ្មានភាពចាំបាច់ណាមួយក្នុងការប្រើប្រាស់ពាក្យជំនួសដូចជា "ការសម្លាប់រង្គាលនៃអំពើប្រល័យពូជសាសន៍" មិនថាអំពើប្រល័យពូជសាសន៍នោះមានទំហំធំឬតូចឡើយ ។

របៀបដែលកន្សោមពាក្យនេះត្រូវបានកំណត់គឺសំខាន់ណាស់ ពីព្រោះថាឧក្រិដ្ឋជនអាចប្រើប្រាស់ចំណុចចន្លោះប្រហោងនេះ ដើម្បីបង្កើតក្រុមមួយដែលសង្គមអាចទទួលយកបាន និងដែលមើលទៅដូចជាក្រុមមួយប្រឆាំងនឹងសង្គមនិងទទួលខុសត្រូវលើការបំផ្លិចបំផ្លាញ ។ ក៏ប៉ុន្តែ ការកំណត់តាមរបៀបនេះមិនមាននិយាយក្នុងអត្ថបទនេះដែលពិភាក្សាអំពីអ្វីដែលបង្កើតឲ្យមានក្រុមមួយនោះទេ ។ ក្រុមពាក្យនៅទីនេះគឺសំដៅយកក្រុមដែលគាំទ្រសង្គម មិនមែនក្រុមដែលប្រឆាំងនឹងសង្គម ដូចជាក្រុមពលាវ៉ាសែ ក្រុមចោរ ឬក្រុមភេរវជនឡើយ ។ ក្រុមនៅទីនេះមានដូចជាជនជាតិ ជាតិពន្ធ ពូជសាសន៍ សាសនា នយោបាយ សង្គម និងសេដ្ឋកិច្ច ។

ទោះបីជាមានការលំបាកក្នុងការបង្ហាញនូវចេតនាក៏ដោយ វាគឺជាធាតុផ្សំផ្នែកគំនិតជាមូលដ្ឋានដែលត្រូវតែបង្ហាញឲ្យឃើញ ។ ក្នុងព្រឹត្តិការណ៍មួយចំនួនពុំចាំបាច់ស្វែងរកចេតនាជាលាយល័ក្ខអក្សរឡើយ ។ ចរិតលក្ខណៈនៃការបំផ្លិចបំផ្លាញជាប្រព័ន្ធលើក្រុមមួយរួមមានទាំងចេតនានិងអំពើ ។

ពាក្យថា "ទាំងស្រុងឬដោយផ្នែក" មានន័យថា នៅក្នុងព្រឹត្តិការណ៍ដែលផែនការបំផ្លិចបំផ្លាញសមាជិកទាំងអស់នៃក្រុមត្រូវបរាជ័យ ការបំផ្លិចបំផ្លាញដែលទទួលជោគជ័យតែលើផ្នែកណាមួយនៃក្រុមនេះក៏បង្កើតបានជាអំពើប្រល័យពូជសាសន៍ដែរ ។ ក្នុងករណីនេះ សមាជិកទាំងអស់ឬមួយផ្នែកនៃក្រុមនេះដែលបានទទួលរងគ្រោះត្រូវរាប់ថាជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ ។ ទោះបីជា ហ៊ីត្លែរ មិនបានសម្លាប់ជនជាតិជ្វីហ្វទាំងអស់តាមផែនការរបស់ខ្លួនក៏ពិតមែន ក៏ ហ៊ីត្លែរ នៅតែមានឈ្មោះជាអ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដដែល ។ ដាច់នេះទៅទៀត ផែនការបំផ្លិចបំផ្លាញដោយផ្នែកក៏បង្កើតជាអំពើប្រល័យពូជសាសន៍បានដែរ ។

និយមន័យនេះស្រដៀងនឹងការកំណត់និយមន័យរបស់សាស្ត្រាចារ្យច្បាប់ ភីធី អេនដ្រូស ដែលបានកំណត់និយមន័យអំពើប្រល័យពូជសាសន៍ថាជា "ការបំផ្លិចបំផ្លាញដោយចេតនាលើអាយុជីវិតមនុស្សម្នាក់ៗ ដោយមូលហេតុជនរងគ្រោះជាសមាជិកក្រុមណាមួយ" ។ បញ្ហាដែលទាក់ទិននឹងនិយមន័យរបស់ដ្រូស គឺថា ការកំណត់នេះមានទំនោរចាត់ទុកការសម្លាប់មនុស្សក្នុងចំនួនតិចតួចថាជាអំពើប្រល័យពូជសាសន៍ ។ បើពិចារណាលើលក្ខណៈនៃការសម្លាប់ជាប្រព័ន្ធនិយមន័យថ្មីនេះសមស្របទៅនឹងនិយមន័យខាងលើនេះ ។

និយមន័យនេះគឺខុសពីនិយមន័យរបស់ ហ្វេន ក្នុងឆ្នាំ១៩៨៤ លើចំណុចមួយដែលអ្នកស្រីបានកំណត់ថាអំពើប្រល័យពូជសាសន៍កើតឡើងក្នុងអំឡុងពេលមានវិបត្តិ ។ ដូចបានអះអាងបញ្ជាក់ពីខាងដើម វិបត្តិគឺជាលក្ខណៈទូទៅនៃជម្លោះ ។ គ្មានតម្រូវការចាំបាច់ណាមួយនិយាយអំពីវិបត្តិឡើយ ។ ការដាក់វិបត្តិក្នុងនិយមន័យច្បាប់ គឺជាភារៈមួយ ពីព្រោះនិយមន័យមួយត្រូវបង្ហាញពីវត្តមានវិបត្តិមួយដើម្បីបង្ហាញឲ្យឃើញនូវអំពើប្រល័យពូជសាសន៍ ។

និយមន័យនៅក្នុងអត្ថបទនេះគឺស្របទៅតាមគំរូនិយមន័យរបស់អង្គការសហប្រជាជាតិ ដោយសម្អាងលើហេតុផលជាច្រើន ។ ប្រសិនបើការកំណត់និយមន័យរបស់អង្គការសហប្រជាជាតិត្រូវបានរិះគន់ថាធ្វើឡើងក្រោមការសម្រុះសម្រួលផ្នែកនយោបាយដែលបណ្តាលឲ្យមានការលុបចោលនូវក្រុមនយោបាយ វាហាក់ដូចជាថាគ្រប់ភាគីទាំងអស់យល់ព្រមនឹងនិយមន័យនេះលើកលែងតែបញ្ហាក្រុមនយោបាយមួយ ។ ដូចនេះយើងអាចសន្និដ្ឋានបានថា បើគ្មានការសម្រុះសម្រួលផ្នែកនយោបាយ និយមន័យដ៏ត្រឹមត្រូវមួយគួរតែរួមបញ្ចូលក្រុមនយោបាយ ។

ជាការពិត បរាជ័យទាំងស្រុងនៃអនុសញ្ញាប្រល័យពូជសាសន៍ក្នុងការក្នុងបញ្ឈប់អំពើប្រល័យពូជសាសន៍ គឺដោយសារហេតុផលផ្សេងៗទៀតដូចជាអធិបតេយ្យភាពរបស់រដ្ឋនិងចំណាប់

អារម្មណ៍របស់រដ្ឋក្នុងការធ្វើអន្តរាគមន៍ ។ នៅពេលដែលភាគីរដ្ឋមួយ ដូចយ៉ាងសហរដ្ឋអាមេរិក មានចំណាប់អារម្មណ៍ក្នុងការធ្វើអន្តរាគមន៍ ឧទាហរណ៍ករណីថ្មីៗនៅប្រទេសអ៊ីរ៉ាក់ រដ្ឋនេះអាចរកបាននូវហេតុផលសមរម្យដើម្បីធ្វើបែបនេះបាន ។ ផ្ទុយទៅវិញ ប្រសិនបើគ្មានការចាប់អារម្មណ៍ទេនឹងគ្មានការបង្ហាញភ័ស្តុតាងគ្រប់គ្រាន់ពីអំពើប្រល័យពូជសាសន៍ហើយថែមទាំងបណ្តោយឲ្យយឺតយ៉ាវថែមទៀត ។ ក្នុងប្រទេសកម្ពុជា និងក្នុងការសម្លាប់ជនជាតិខ្មែរដោយខ្មែរក្រហមនិងពល មនុស្សជាច្រើនបានចោទជាសំណួរចំពោះភាពត្រឹមត្រូវតាមច្បាប់នៃកសិណរបស់ជនភៀសខ្លួនដែលចម្លងពីរបីគេ ក្នុងកិច្ចខិតខំប្រឹងប្រែងគាំទ្រភាពអសកម្មរបស់ខ្លួន ។ ប៉ុន្តែការទន្ទ្រានចូលទឹកដីអ៊ីរ៉ាក់គឺផ្អែកលើការស៊ើបអង្កេតមិនច្បាស់លាស់ ។ ជាក់ស្តែង ឥឡូវនេះការស៊ើបអង្កេតនោះត្រូវបានបង្ហាញថាមិនត្រឹមត្រូវ ។

ទោះជា ឃុបជី បានទិតៀននិយមន័យរបស់អង្គការសហប្រជាជាតិហើយក្រោយមកគាត់ទទួលស្គាល់និយមន័យនេះក៏ដោយ គាត់ហាក់ដូចជាដឹងអំពីស្ថិរភាពនៃនិយមន័យនេះ ។ ហេតុផលមួយដែលគាត់គាំទ្រនិយមន័យនេះប្រហែលជាចេញពីការអះអាងរបស់គាត់ដែលថាក្រុមនយោបាយនិងក្រុមដែលត្រូវបានការពារទាំងបួនទៀតមានទំនាក់ទំនងគ្នា ហើយដែលឧក្រិដ្ឋជនអាចសម្លាប់ជាតិពន្ធដោយបង្ហាញថាជាតិពន្ធទាំងនោះទាក់ទិននឹងនយោបាយ ។ ផ្ទុយទៅវិញ បើក្រុមនយោបាយនិងក្រុមដទៃទៀត មានទំនាក់ទំនងនឹងគ្នា ការសម្លាប់ក្រោមហេតុផលនយោបាយអាចចាត់ថាជាក្រុមពូជសាសន៍ឬជាតិពន្ធ នៅពេលដែលសមាជិកនៃក្រុមនោះត្រូវបានសម្លាប់ជាប្រព័ន្ធនិងដូចគ្នាៗ ។

## ការពន្យល់អំពីគំនិតជាមូលដ្ឋាន

តើហេតុអ្វីបានជាគោលការណ៍ "ការសម្លាប់ជាប្រព័ន្ធនិងមិនរើសមុខលើសមាជិកក្រុមមួយពីព្រោះជនរងគ្រោះជាជាសមាជិកនៃក្រុមនេះ" ធ្វើឲ្យអំពើប្រល័យពូជសាសន៍ក្លាយជាឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត? ការសម្លាប់សមាជិកនៃក្រុមបែបនេះ មិនគ្រាន់តែជាអំពើឃោរឃៅទេ ថែមទាំងជាការសម្លាប់មិនសមហេតុផលដែលមានទិន្នាការធ្វើឲ្យមានការបាត់បង់អាយុជីវិតដោយមូលហេតុជាច្រើន ។ មូលហេតុទីមួយ ដាក់បន្ទុកទទួលខុសត្រូវលើសមាជិកនៃក្រុមជនរងគ្រោះដោយបញ្ចូលការពិតជាមួយនឹងការគំរាមកំហែង ។ ដោយភ្ជាប់ជនស្លូតត្រង់ជាមួយនឹងសត្រូវពិតដែលគួរឲ្យស្អប់ ឆាល និង ចូណាសសាន់ យល់ឃើញថា ការសម្លាប់នេះប្រព្រឹត្តយ៉ាងឃោរឃៅមកលើសមាជិកនៃក្រុមជនរងគ្រោះដែលនេះជាលក្ខខណ្ឌមុនអំពើប្រល័យពូជសាសន៍ ។

មូលហេតុទីពីរនិងសំខាន់បំផុតគឺ ការសម្លាប់បែបនេះអាចនឹងកើតឡើងនិងមិនអាចគ្រប់គ្រងបានឡើយ ពីព្រោះមនោគមន៍វិជ្ជាឬការរកហេតុផលដែលគាំទ្រនឹងការសម្លាប់អាចនឹងត្រូវបានគាត់យល់យ៉ាងងាយថាត្រូវសម្លាប់ក្រុមនេះទាំងមូលឬត្រូវប្រើប្រាស់ក្រុមនេះដើម្បីប្រឆាំងនឹងក្រុមដទៃទៀត ។ ពីដំបូង ខ្មែរក្រហមមានគម្រោងសម្លាប់មន្ត្រីរដ្ឋការក្នុងរបបលន់នល់ ក៏ប៉ុន្តែបន្តិចក្រោយមក ប្រជាជនដែលរស់នៅទីក្រុងក៏ខ្មែរក្រហមសម្លាប់បន្ទាប់មកពួកខ្មែរក្រហមបោសសម្អាតកម្មាភិបាលក្នុងជួររបស់ខ្លួនឯងទៀត ។ ដាវីឌ ហកដកស្រង់ការយល់ឃើញរបស់ ហ្គាលប្រេតអំពីប្រសិទ្ធភាពនៃការសម្លាប់មិនរើសមុខទៅលើជនជាតិខ្មែរនៅក្នុងប្រទេសអ៊ីរ៉ាក់ក្រោមយុទ្ធការ អានហ្វាល ថា ÷

"បញ្ហាទាំងនេះបានកើតឡើងយ៉ាងលឿន... នៅពេលដែលកាន់អំណាចនៅឆ្នាំ១៩៣៣ ហ៊ីត្លែរ មិនមានផែនការសម្លាប់ជនជាតិជ្វីហ្វទាំងអស់នៅទ្វីបអឺរ៉ុបទេ ។ អំពើអាក្រក់ទទួលផលអាក្រក់... ក្នុងពេលនោះផែនការសម្លាប់ផ្តោតជាសំខាន់លើជនជាតិខ្មែរដែលរស់នៅតាមជនបទនិងទីក្រុងតូចៗ ។ ខ្ញុំគិតថាផែនការរបស់ ហ៊ីត្លែរ អាចឈានឡើងដល់ការលុបបំបាត់ជនជាតិខ្មែរទាំងអស់នៅប្រទេសអ៊ីរ៉ាក់" ។

មូលហេតុទីបី ការសម្លាប់មនុស្សដោយមិនបានពិនិត្យពិច័យធ្វើឲ្យមានការប៉ះពាល់ដល់សមាជិកនៃសហគមន៍ជនដែលដែលគ្មានការយល់ដឹងឲ្យយល់ថាការប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាឱកាសដ៏ត្រឹមត្រូវមួយ ។ ចំណុចនេះខុសពីទាហានម្នាក់ដែលមិនដឹងថាខ្លួនសម្លាប់ទាហានដទៃទៀតបន្ទាប់ពីស្ថិតនៅក្នុងសមរភូមិអស់រយៈពេលយ៉ាងយូរ ។ ឧក្រិដ្ឋជនអំពើប្រល័យពូជសាសន៍ដែលមិនបានដឹង នឹងមិនស្ទាក់ស្ទើរក្នុងការសម្លាប់ស្ត្រីនិងកុមារដែលជាក្រុមជនរងគ្រោះឡើយ ។ ឧទាហរណ៍ជាក់ស្តែងគឺការធ្វើអត្តឃាតរបស់ប្រជាជនប៉ាឡេស្ទីន ឬការបំផ្ទុះគ្រាប់

បែកនៅក្នុងទីប្រជុំជនអ៊ីស្រាអែល ។ លទ្ធផលស្ទែងចេញដោយផ្អែកនៅពេលថ្មីៗនេះខណៈដែលប្រធានាធិបតីថ្មីនៃប្រទេសអ៊ីរ៉ង់ លោក ម៉ាស់មូដ អាម៉ាឌីណឺហ្សាដ សន្យាថានឹងលុបប្រទេសអ៊ីស្រាអែលចេញពីផែនទីពិភពលោក ។ ប្រជាជនអ៊ីរ៉ង់មួយចំនួនធំគាំទ្រសម្តីរបស់ប្រធានាធិបតីរូបនេះ ។ ការពិត ក្រោមនិយមន័យដែលមាននិយាយនៅក្នុងអត្ថបទនេះ យុទ្ធនាការប្រើប្រាស់គ្រាប់បែកអត្តឃាតគឺជាអំពើប្រល័យពូជសាសន៍មួយ ។

មូលហេតុចុងក្រោយ នៅពេលដែលក្រុមជនរងគ្រោះត្រូវបានកំណត់ទូលំទូលាយដោយខក្រិដ្ឋជនប្រល័យពូជសាសន៍ដែលប៉ុនប៉ងសម្លាប់ដោយហេតុផលអត្តសញ្ញាណរួមរបស់ជនរងគ្រោះនេះជាវិបាកដែលមិនធ្លាប់មានពីមុន ដូចក្នុងករណីការលុបបំបាត់ជនជាតិយូឡាក់នៅសហភាពសូវៀត ។ អំពើប្រល័យពូជសាសន៍បែបនេះទាមទារឲ្យមានចំនួនជនរងគ្រោះច្រើនបំផុត ។ ទាក់ទិននឹងការសម្លាប់ក្រោមមនោគមវិជ្ជាកុម្មុយនិស្តជ្រុលនិយមដែលមើលឃើញសង្គមល្អបរិសុទ្ធដោយគ្មានក្រុមសង្គមជាក់លាក់មួយ ជនរងគ្រោះមិនចំពោះតែអ្នកដែលរស់នៅក្នុងសហភាពសូវៀតប៉ុណ្ណោះ ប៉ុន្តែថែមទាំងនៅក្នុងប្រទេសចិន កម្ពុជា និងបណ្តាប្រទេសដទៃទៀត ។

ដូចនេះ ការប្រើប្រាស់គោលការណ៍ជាមូលដ្ឋាននេះគាំទ្រអំពើប្រល័យពូជសាសន៍គឺគ្រប់គ្រាន់ក្នុងការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ ព្យាករណ៍អំពើប្រល័យពូជសាសន៍ ដែលនឹងពេញលក្ខណៈនៅពេលអនាគត និងទប់ស្កាត់អំពើប្រល័យពូជសាសន៍កុំឲ្យហួសពេល ។

## សេចក្តីសន្និដ្ឋាន

អត្ថបទនេះស្នើសុំយកការកំណត់និយមន័យអំពើប្រល័យពូជសាសន៍ចំនួនបី ។ ទីមួយ និយមន័យ"អំពើប្រល័យពូជសាសន៍"ដែលកំណត់ដោយអង្គការសហប្រជាជាតិមិនខុះខាតធ្ងន់ធ្ងរដូចដែលសាធារណជនទូទៅយល់ឃើញនោះទេ ទោះបីជានិយមន័យនេះលើកឡើងតែអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដា ហើយមិននិយាយដល់អំពើប្រល័យពូជសាសន៍ជាច្រើនទៀតដែលកើតឡើងតាំងពីក្រោយសង្គ្រាមលោកលើកទីពីរនោះក៏ដោយ ។ បញ្ហាទាំងនេះមាននៅក្នុងនិយមន័យរបស់អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ដូចជា ចេតនាបំផ្លាញទាំងស្រុងឬដោយផ្អែកលើរូបរាងកាយប៉ុន្តែមិនបណ្តាលឲ្យស្លាប់ និងការមិនរាប់បញ្ចូលក្រុមនយោបាយ ។ មូលហេតុដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនអាចបំពេញកាតព្វកិច្ចរបស់ខ្លួនបានកើតចេញពីបន្សំនៃកត្តាតូចៗជាច្រើន ។ កត្តាទាំងនោះគឺភាពមិនច្បាស់លាស់ក្នុងការកំណត់និយមន័យដែលលើកឡើងខាងលើកង្វះឆន្ទៈរបស់ភាគីរដ្ឋក្នុងការធ្វើអន្តរាគមន៍ និងលទ្ធផលនៃការមើលឃើញបំណកស្រាយមិនត្រឹមត្រូវអំពីអំពើប្រល័យពូជសាសន៍ទាំងសាធា



វាលពិឃាតបឹងជើងឯក

រណៈទាំងនៅក្នុងចំណោមបញ្ញវន្ត ។ មានអ្នកប្រាជ្ញមួយចំនួនគិតថា ចេតនានិងចំណង់គឺតែមួយ ។ អ្នកប្រាជ្ញមួយចំនួនទៀតគិតថាអំពើប្រល័យពូជសាសន៍ត្រូវតែមានទ្រង់ទ្រាយធំ រាប់បញ្ចូលទាំងគំនិតរបស់ ឃុបជឺ ដែលបង្កើតពាក្យ"ការសម្លាប់រង្គាលនៃអំពើប្រល័យពូជសាសន៍" ។ កត្តាទាំងបីនេះទំនងជាជួយបំពេញគ្នាទៅវិញទៅមកត្រង់ចំណុចដែលខ្វះខាត ។ ភាពមិនច្បាស់លាស់លើនិយមន័យបន្តិចបន្តួចនេះអាចឲ្យរដ្ឋបកស្រាយនិយមន័យនេះក្នុងន័យគាំទ្រភាពអសកម្ម ។ ជាឧទាហរណ៍ អំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយតូចៗត្រូវបានគេយល់ថាជាការគាបសង្កត់លើនយោបាយក្នុងស្រុក ។ ប្រសិនបើក្រុមនយោបាយត្រូវបានរាប់បញ្ចូលសហគមន៍អន្តរជាតិនឹងមានដែនសមត្ថកិច្ចស៊ើបអង្កេតការគាប

សង្កត់នេះ ។ ជាលទ្ធផល ពុំមានអន្តរាគមន៍លើអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយតូចឡើយ ក៏ប៉ុន្តែមានអន្តរាគមន៍ទៅលើអំពើប្រល័យពូជសាសន៍ដែលមានទ្រង់ទ្រាយធំ ដែលធ្វើឲ្យប្រជាជនភៀសខ្លួនទៅព្រំដែន ។ ការដែលអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ត្រូវបានបង្កើតឡើងដោយសារការមើលឃើញអំពើសម្លាប់ផ្តាច់ពូជជនជាតិអារមេនីនិងហូឡូខូសនៅទ្វីបអឺរ៉ុប នាំឲ្យមានជំនឿថា អំពើប្រល័យពូជសាសន៍ត្រូវតែមានទំហំធំ ។ លទ្ធផលចុងក្រោយគឺមនុស្សទាំងអស់ក៏យល់ឃើញថាអំពើប្រល័យពូជសាសន៍ត្រូវតែមានទំហំធំដែរ ។



និយមន័យទីពីរនៃ“អំពើប្រល័យពូជសាសន៍”គឺមិនមានការរៀបរាប់ពន្យល់គោលការណ៍ជាមូលដ្ឋានអំពីនិយមន័យរបស់អង្គការសហប្រជាជាតិទេ លើកលែងតែគំនិតសំខាន់របស់លីមគីន ស្តីពីអំពើឃោរឃៅនិងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងសេចក្តីសម្រេចស្តីពីអំពើប្រល័យពូជសាសន៍ចុះក្នុងខែធ្នូឆ្នាំ១៩៤៦ របស់អង្គការសហប្រជាជាតិ ។ ទោះជានិយមន័យដែលបានស្នើក្នុងអត្ថបទនេះ ធ្វើទៅតាមរបៀបកំណត់និយមន័យរបស់អង្គការសហប្រជាជាតិក៏ដោយ ក៏និយមន័យនេះមានគោលគំនិតជាមូលដ្ឋានច្បាស់លាស់ ។ នោះគឺការបំផ្លិចបំផ្លាញ ជាប្រព័ន្ធនិងមិនរើសមុខទៅលើសមាជិកនៃក្រុមមួយ ពីព្រោះជនរងគ្រោះជាសមាជិកនៃក្រុមនោះ ។

ជាទីបញ្ចប់ ចេញពីបរិបទនេះ អំពើប្រល័យពូជសាសន៍មានទំហំខុសៗគ្នា មានអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយតូច និងអំពើប្រល័យពូជសាសន៍ទ្រង់ទ្រាយធំ ។ ខុសពីអត្ថបទដទៃដែលប្រើប្រាស់ពាក្យផ្សេងសម្រាប់កំណត់ទំហំផ្សេងៗគ្នានៃអំពើប្រល័យពូជសាសន៍ និក្ខេបបទនេះមិនបានលើកឡើងនូវពាក្យស័ព្ទដោយឡែកផ្សេងទៀតនោះទេ ដោយសារមូលហេតុបីយ៉ាង ។ មូលហេតុទីមួយ ការសម្លាប់មនុស្សទោះក្នុងចំនួនតិចឬច្រើននៅក្រោមលក្ខខណ្ឌដូចគ្នាដែលបានរៀបរាប់ខាងលើ គឺមានលក្ខណៈធ្ងន់ធ្ងរស្មើគ្នា ។ ទីពីរ ការប្រើប្រាស់ពាក្យដូចគ្នាមិនបានផ្លាស់ប្តូរការយល់ឃើញរបស់សាធារណជនទាក់ទងទៅនឹងភាពធ្ងន់ធ្ងរនៃករណីនីមួយៗនៃអំពើប្រល័យពូជសាសន៍ឡើយ ។ ទីបី ខុសពីប៊ូអឺ ដែលព្យាយាមធ្វើឲ្យ ហូឡូខូស ខុសប្លែកពីអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែក្នុងនិក្ខេបបទនេះ អំពើប្រល័យពូជសាសន៍គឺដូចទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ និងជាកង្វល់របស់មនុស្សគ្រប់រូប ។

**រអេង កុកថាយ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ៖

- ◆វិទ្យុ FM១០២MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៧ៈ៣០-៧ៈ៤៥ល្ងាច ។
- ◆វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- ◆វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- ◆វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាមជ្ឈមណ្ឌលដែលប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លងនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

“ការិយាល័យព័ត៌មានសាធារណៈ” មានផ្តល់ជូននូវសេវា៤យ៉ាង ៖

**១) បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

**២) មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលនេះមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

**៣) ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃឹម តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ក្រុមអ្នកស្ម័គ្រចិត្តចូលទស្សនាសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

## សេចក្តីប្រកាសរួមស្តីអំពីការបើកឱ្យដំណើរការការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និងលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល**

ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកឲ្យ ដំណើរការក្នុងសប្តាហ៍នេះហើយ ចំណែកក្រុមការងាររួមក៏កំពុងចាប់ផ្តើមការងាររបស់ពួកគេដែរ ។ យើងខ្ញុំមានសេចក្តីរីករាយណាស់ក្នុងការទទួលស្វាគមន៍អ្នកសារព័ត៌មានជាលើកដំបូងនៅក្នុងទីតាំងអគារធ្វើការថ្មីរបស់យើង រួមមានអគារការិយាល័យមួយនិងសាលសវនាការមួយដែលប្រកបទៅដោយទីធ្លាធំទូលាយ ហើយឥឡូវនេះនឹងត្រូវបានដាក់ឲ្យប្រើប្រាស់ជាអគារធ្វើការសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សម្រាប់កាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។ យើងអាចនិយាយបានយ៉ាងច្បាស់ថា យើងបានឆ្លងពីដំណាក់កាលរៀបចំ ហើយឈានចូលដល់ការបង្កើតដាក់ស្តែងនូវអង្គជំនុំ ជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជា ឬអ៊ី.ស៊ី.ស៊ី.ស៊ី. ។

ឆ្លៀតក្នុងឱកាសនេះដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ម្ចាស់អំណោយទាំងអស់ ទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈអង្គការសហប្រជាជាតិ និងទាំងចំពោះអ្នកដែលបានចូលរួមវិភាគទានជាថវិកាតាមរយៈភាគីកម្ពុជា ដែលនៅខ្វះខាតប្រមាណ៩.៦លានដុល្លារទៀត ។ យើងខ្ញុំមានការជឿជាក់ថា មូលនិធិដែលនៅសេសសល់នឹងត្រូវបានធានាក្នុងពេលឆាប់ៗនេះ ហើយយើងខ្ញុំសូមធ្វើការអំពាវនាវម្តងទៀតសម្រាប់ការផ្តល់ជំនួយផ្នែកវិភាគទាននេះ ។

យើងខ្ញុំមិនបណ្តោយឲ្យកង្វះខាតនាពេលបច្ចុប្បន្នរាំងស្ទះដល់ការបើកឲ្យដំណើរការរបស់ការិយាល័យរដ្ឋបាលនិងផ្តើមការងាររបស់ក្រុមការងាររួមសម្រាប់ការិយាល័យរដ្ឋបាលនេះទេ ។ ដៃគូរបស់យើងខ្ញុំមកពីអង្គការសហប្រជាជាតិដែលដឹកនាំដោយលោកស្រី មីសែល លី អនុប្រធានការិយាល័យរដ្ឋបាល បានចាប់ផ្តើមធ្វើដំណើរមកដល់ទីក្រុងភ្នំពេញដើម្បីទទួលការងាររបស់ពួកគេនៅ អ៊ី.ស៊ី.ស៊ី.ស៊ី នេះ ។ ចំពោះផ្នែកច្បាប់និងតុលាការដំណាក់កាលចុងក្រោយនៃ ការតែងតាំងចៅក្រមជាតិនិងអន្តរជាតិ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត កំពុងតែដំណើរការ ហើយយើងខ្ញុំរំពឹងទុកថានឹងអាចប្រកាសឈ្មោះរបស់ពួកគេក្នុងពេលដ៏ឆាប់ខាងមុខ នេះ ។ កាលពីថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីសម្រេចមួយក្រោមការផ្តល់អនុសាសន៍ពីអគ្គលេខាធិការដែលសម្រេចថាចៅក្រមអន្តរជាតិ សហព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតអន្តរជាតិទាំងអស់ នឹងត្រូវចាត់ទុកជាមន្ត្រីរបស់អង្គការសហប្រជាជាតិ សម្រាប់បំពេញលើលក្ខខណ្ឌការងាររបស់ពួកគេ ហើយអនុម័តផ្តល់នូវនីតិសម្បទាឲ្យពួកគេដោយយោងលើលក្ខខណ្ឌនេះ ។

ចំពោះភាគីអង្គការសហប្រជាជាតិ មន្ត្រីតុលាការដែលត្រូវបានជ្រើសរើសនោះកំពុងត្រូវបានត្រួតពិនិត្យសុខភាព ហើយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានរំពឹងទុកថា នឹងផ្តល់បញ្ជីឈ្មោះអ្នកដែលត្រូវតែងតាំងដល់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់ការជ្រើសរើសចុងក្រោយ និងតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ យើងខ្ញុំសង្ឃឹមថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងប្រកាសក្នុងពេលជាមួយគ្នានូវឈ្មោះមន្ត្រីតុលាការកម្ពុជាដែលនឹងត្រូវតែងតាំង ។

ការត្រៀមលក្ខណៈផ្សេងៗទៀតក៏កំពុងតែដំណើរការដែរ ដូចជាការរៀបចំបោះពុម្ពឡើងវិញនូវកូនសៀវភៅការណែនាំស្តីពីការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម សម្រាប់ការផ្សព្វផ្សាយទូទាំងប្រទេស ការចងក្រងប្រមូលឯកសារច្បាប់ជាមូលដ្ឋានចំនួនជាង១០០ជាភាសាផ្លូវការនៅក្នុងតុលាការ និងកម្មវិធីផ្សព្វផ្សាយព័ត៌មានតាមតំបន់ (បានទទួលការឧបត្ថម្ភពីរដ្ឋាភិបាលប្រទេសអូស្ត្រាលីនិងប្រទេសន័រវេស) ។ យើងខ្ញុំដឹងថាភារកិច្ចនៅចំពោះមុខរបស់បុគ្គលិក និងមន្ត្រីតុលាការទាំងអស់ជាកិច្ចការមួយសំខាន់ដែលចាំបាច់ត្រូវប្រើឲ្យអស់លទ្ធភាពនូវបទពិសោធន៍ ការប្រឹងប្រែងនិងភាពអត់ធ្មត់ ប៉ុន្តែយើងខ្ញុំសន្យាថានឹងខិតខំឲ្យអស់ពីសមត្ថភាពដើម្បីទទួលខុសត្រូវនូវរាល់កាតព្វកិច្ចដែលបានប្រគល់ឲ្យក្នុងន័យសបញ្ជាក់ថា ភាពយឺតយូរក្នុងការរកយុត្តិធម៌នឹងមិនមានន័យថាមិនមានយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលបានទន្ទឹងរង់ចាំអស់ពេលជាយូរមកហើយនោះទេ ។

**ធ្វើនៅភូមិកន្ទោក ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០០៦, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

# កាត់ទោសឱ្យសមនឹងកំហុស

ខ្ញុំបាទឈ្មោះ សោម វណ្ណៈ មានស្រុកកំណើតនៅភូមិបាក់រនាស់ ឃុំសង្ឃ័រ ស្រុកស្វាយទាប ខេត្តស្វាយរៀង ។

លោកប្រធានសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា សមាគមការពារសិទ្ធិមនុស្សនៅកម្ពុជា តុលាការជាតិតុលាការអន្តរជាតិដែលមានភារកិច្ចក្នុងរឿងកាត់ទោសមេដឹកនាំខ្មែរក្រហម និងទស្សនាវដ្តីស្វែងរកការពិត!

ដ្បិតខ្ញុំបាទនៅមិនទាន់អស់ចិត្តចំពោះក្រុមមេដឹកនាំខ្មែរក្រហមមួយចំនួនដែលនៅមានមុខនិងនៅរស់រានមានជីវិតរហូតដល់បច្ចុប្បន្នដែលរួមមាន អៀង សារី, ខៀវ សំផន, នួន ជា, តាម៉ុក, ឌុច ព្រមទាំងមេដឹកនាំខ្មែរក្រហមសំខាន់ៗមួយចំនួនទៀតដែលខ្ញុំពុំអាចរៀបរាប់អស់ ។ អ្នកទាំងអស់នោះធ្លាប់ បានប្រព្រឹត្តអំពើឃោរឃៅអមនុស្សធម៌មកលើក្រុមគ្រួសារខ្ញុំនិងប្រជាជនស្លូតត្រង់រាប់លាននាក់ចាប់តាំងពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៧៩ ។ តទៅនេះខ្ញុំសូមបរិយាយរឿងដែលខ្ញុំបានចងចាំខ្លះៗកាលពីខ្ញុំរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ឆ្នាំ១៩៧៥ ខ្ញុំរស់នៅខេត្តស្វាយរៀង ។ កាលនោះខ្ញុំមានអាយុជាង១០ឆ្នាំ ។ ម៉ោងប្រហែល៥ព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលគឺក្រោយថ្ងៃបុណ្យចូលឆ្នាំថ្មីមួយថ្ងៃ ខ្ញុំបានឮសម្រែកជយឃោសលាន់សូររំពងនៅតាមបណ្តោយផ្លូវជាតិលេខ១ ព្រមទាំងឃើញរថពាសដែកនិងរថយន្តដឹកទ័ពច្រើនដើងបើកតម្រង់ទៅទិសខាងលិច ។ បុរសប្លែកមុខជាច្រើននាក់ស្លៀកពាក់ពណ៌ខ្មៅ បង់កក្រមា ប្រដាប់ដោយអាវុធនិងគ្រាប់រំសេវគ្រប់ដៃ ដើរចុះឡើងក្នុងភូមិអ្នកស្រុក ។ បុរសម្នាក់អាយុប្រហែល ៤០ឆ្នាំ មានកាំភ្លើងខ្លីសៀតនៅចង្កេះ រួមដំណើរជាមួយបុរស ៥-៦នាក់ទៀតដែលកាន់កាំភ្លើងវែងផងខ្លីផង បានចូលមកក្រោមផ្ទះរបស់ខ្ញុំ ។ បុរសម្នាក់ក្នុងចំណោមនោះបាននិយាយថា "សូមគោរពពុកម៉ែមិត្តយុវជននិងបងប្អូនទាំងអស់ ថ្ងៃនេះអង្គការបានមករំដោះពុកម៉ែបងប្អូនឲ្យរួចផុតពីរបបសក្តិភូមិជិះជាន់ហើយ" ។ ពីរថ្ងៃបន្ទាប់មក ខ្មែរក្រហមបានបណ្តេញក្រុមគ្រួសារខ្ញុំចេញពីផ្ទះ ឲ្យធ្វើដំណើរទៅទិសខាងកើតចម្ងាយមួយគីឡូម៉ែត្រ ។ ខ្មែរក្រហមបាននិយាយថា "អង្គការជម្លៀសពុកម៉ែបងប្អូនតែបីថ្ងៃទេដើម្បីទុកកន្លែងនេះបោសសម្អាតខ្មាំងក្បត់ជាតិមាន លន់ នល់, ចេង ហេង និង សិរិមតៈ" ។ ថ្ងៃទី២១-២២ ខែមេសា ភ្លៀងកក់ខែបានធ្លាក់ខ្លះៗកាត់បន្ថយភាពក្តៅហែងនៃខែចែត្រ ។ ប្រជាជនជម្លៀសខ្លះបានសង់ជម្រកជាបណ្តោះអាសន្ន ខ្លះទៀតបានសុំជ្រកក្រោមផ្ទះបងប្អូនប្រុសាច់ញាតិ ។ សម្ភារប្រើប្រាស់គ្រឿងឧបភោគបរិភោគដូចជា ស្រូវអង្ករ ប្រហុក ផ្អក និងសត្វចិញ្ចឹមដូចជា ជ្រូក មាន់ ទា គោ អាចបំពេញតម្រូវការរបស់គ្រួសារបានមួយរយៈ ។

ក្នុងរវាងឆ្នាំ១៩៧៦ ខ្មែរក្រហមបានចាប់ផ្តើមអនុវត្តរបៀបរបបសមូហភាពធ្វើរួមហូបរួម ។ គោក្របី ជ្រូក មាន់ទា ព្រមទាំងសម្ភារប្រើប្រាស់ត្រូវបានប្រមូលដាក់ជារបស់អង្គការ ។ ជាទូទៅ អង្គការបែងចែកកម្លាំងពលកម្មបីផ្នែកធំៗ ។ កម្លាំងទី១ គឺកងចល័តយុវជនដែលជាកម្លាំងស្រួចឈានមុខកម្លាំងទី២គឺវ័យកណ្តាល និងកម្លាំងទី៣កុមារ ។ ក្រៅពីនេះនៅមានកម្លាំងផ្សេងទៀតគឺយាយចាស់ៗ មានភារកិច្ចមើលថែទាំកុមារតូចៗ ចំណែកតាៗមានភារកិច្ចធ្វើការងារស្រាលៗដូចជា វេញខ្សែគោក្របី ធ្វើនង្គ័ល រនាស់ កាំបិត ជាដើម ។ និយាយរួម ចាប់តាំងពីពេលចាប់ផ្តើមអនុវត្តនយោបាយធ្វើរួមហូបរួមមក ខ្មែរក្រហមមិនទុកឲ្យនរណាម្នាក់ស្ថិតនៅក្នុងភាពទំនេរជាដាច់ខាត ។

ចុងឆ្នាំ១៩៧៥ ក្រុមគ្រួសារខ្ញុំរស់នៅក្នុងភូមិថ្មី ឃុំថ្មី ស្រុកប្រសូត្រ ខេត្តស្វាយរៀង ពេលនោះខ្ញុំមានអាយុជាង១០ឆ្នាំ ។ អង្គការបានចាត់ចែងប្រជាជនទាំងចាស់ទាំងថ្មីឲ្យធ្វើពលកម្មផ្សេងៗ គ្នាតាមទិសរបស់ថ្នាក់លើដែលដឹកនាំដោយសមមិត្ត ប៉ុល ពត ។ សម័យកាលនោះគ្មាននរណាម្នាក់បានស្គាល់ឈ្មោះឬឃើញមុខ ប៉ុល ពត ឡើយ ។ ខ្ញុំស្គាល់តែប្រធានភូមិថ្មីឈ្មោះ រីម គណៈឃុំឈ្មោះ សេង ហើយយូរៗម្តងខ្ញុំបានជួបគណៈស្រុកប៉ុន្តែខ្ញុំពុំដែលហ៊ានមើលមុខពួកគាត់ឡើយ ។ ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅរៀន

នៅក្នុងសាលារៀនមួយដែលស្ថិតនៅក្រោមម្លប់ឈើមានតែក្តារខៀនមួយនិងដុំឥដ្ឋសម្រាប់អង្គុយប៉ុណ្ណោះ ។ ខ្ញុំនិងកុមារប្រហែល ១០០នាក់បានរៀនសូត្រ២ម៉ោងក្នុងមួយថ្ងៃ ក្រោយពីនោះគឺចេញទៅឃ្វាលគោក្របីនិងរើសលាមកសត្វយកមកធ្វើជី ។ ពេលល្ងាចចប់ការងារ កុមារទាំងអស់ត្រូវប្រជុំគ្នាដើម្បីទិតៀន និងស្វ័យទិតៀន ។ អ្នកដែលហ៊ានទិតៀនខ្លួនឯងនិងទិតៀន អ្នកដទៃទើបហៅថាកុមារល្អ ។ អង្គការបានអប់រំកុមារឲ្យលះបង់កម្មសិទ្ធិសួនតួ ស្អប់ខ្ពើមរបបចាស់ និងឲ្យស្រលាញ់ អង្គការតែមួយប៉ុណ្ណោះ ។ បទចម្រៀងបដិវត្តមួយមានចំណងជើងថា «យើងខ្ញុំកុមារស្រលាញ់អង្គការឥតមានព្រំដែន» ជាបទចម្រៀងពេញនិយមរបស់កុមារគ្រប់រូបនៅក្នុងរបប ប៉ុលពត ។

មួយរយៈពេលបានកន្លងផុតទៅ ប្រព័ន្ធភ្លឺស្រែថ្មី ប្រព័ន្ធប្រឡាយទឹក បានក្លាយជាក្រឡាចត្រង្គជាបណ្តើរៗ ។ នៅតាមការដ្ឋានពុសំឡេងមេក្រូចាក់បទចម្រៀងបដិវត្តដែលមានខ្លឹមសារលើកសរសើរអំពីការដឹកនាំរបស់អង្គការ ។ ខ្ញុំពុំមានអារម្មណ៍ស្តាប់បទចម្រៀងស្អីនោះទេ រាល់វិនាទីខ្ញុំផ្ទៀងត្រចៀកស្តាប់ស្នូរជួងបាយនៅសហករណ៍តែប៉ុណ្ណោះ ។ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦ ខ្ញុំបានហូបឆ្អែត ពីព្រោះក្រុមគ្រួសារខ្ញុំមានលទ្ធភាពខ្លះៗក្នុងការចិញ្ចឹមមាន់ទាដាំបន្លែបន្ការផ្សេងៗដែលអាចឲ្យយើងលួចដាំស្ល ហូបកំបាំងពីភ្នែកអង្គការដែរ ។ ម្តាយនិងពូមីងខ្ញុំលួចធ្វើដំណើរទៅតំបន់ដីកូដាប់ព្រំដែនប្រទេសវៀតណាមដើម្បីដោះដូរសម្ភារហូបចុកដូចជាប៊ីចេង អំបិល ម្រេច ខ្ទឹម ស្ករ ថ្នាំពេទ្យ ជាដើមជាមួយប្រជាជនវៀតណាមដែលរស់នៅក្បែរនោះ ។ ក្រោយៗមកអង្គការបានរឹតបន្តឹងច្បាប់ទម្លាប់ធ្វើឲ្យគាត់គ្មានឱកាសទៅទៀតឡើយ ។ របស់របរដែលគាត់យកទៅតាមខ្លួនក៏ដោះដូរជិតអស់ របបអាហារក៏កាន់តែតិចទៅៗ ។ ក្នុងរវាងចុងឆ្នាំ១៩៧៦ និងដើមឆ្នាំ១៩៧៧ វៀតណាមបានវាយលុកចូលតំបន់ប្រសូត្រ រមាំងថ្កោល ក្រសាំងជ្រុំ ហើយកៀរប្រជាជនទៅទិសខាងកើត ។ ជាការឆ្លើយតបវិញ កងទ័ពខ្មែរក្រហមប្រចាំតំបន់បូព៌ាបានជម្លៀសប្រជាជននៅក្នុងតំបន់ទាំងនោះទៅទិសខាងលិចទន្លេវ៉ៃកូ ចាប់ពីខាងជើងវត្តព្រៃឆ្លាក់រហូតដល់ភូមិមេលោង ឃុំចេក ស្រុកស្វាយជ្រុំ ។

ឆ្លៀតពេលដែលកងទ័ពវៀតណាមបាញ់ស្កាក់តាមបណ្តោយផ្លូវជាតិលេខ១ពីគល់ស្ពានតាហោរហូតដល់ខាងកើតវត្តជម្ពូព្រឹក្សា និងតាមទំនប់ទឹកទន្លេវ៉ៃកូ ប្រជាជនមួយចំនួនបានរត់ទៅតាមកងទ័ពវៀតណាមទៅដល់ភូមិដីកូបាវិតដែលជាតំបន់វៀតណាមកាន់កាប់ ។ មានកម្មាភិបាលខ្មែរក្រហមមួយចំនួនដែលមានឧត្តមគតិស្នេហាជាតិបានសហការជាមួយកងទ័ពវៀតណាម ។ នៅឆ្នាំ១៩៧៧នេះជាលើកដំបូងដែលខ្ញុំបានដឹងថាមានការក្បត់នៅក្នុងជួរខ្មែរក្រហម ។ កម្មាភិបាលខ្មែរក្រហមដែលមកពីភូមិភាគនិរតី ខេត្តតាកែវដែលមានតាម៉ុកជាមេខ្លោងបានចេញប្រតិបត្តិការចាប់កម្មាភិបាលភូមិភាគបូព៌ា តាំងពីថ្នាក់ប្រធានភូមិ គណៈឃុំ គណៈស្រុកឡើងទៅយកទៅសម្លាប់ដោយប្រើពេលតែមួយរយៈខ្លីប៉ុណ្ណោះ ។ ពេលកំពុងឃ្វាលគោក្របីនៅក្បែរដើមពោធិតាហោស្ថិតនៅក្នុងឃុំ ពោធិតាហោ ទីរួមខេត្តស្វាយរៀង ខ្ញុំបានឃើញផ្ទាល់ភ្នែកនៅក្នុងផ្ទះល្វែងដ៏ស្ងាត់មួយ ដែលកងទ័ពភូមិភាគនិរតីចាប់កម្មាភិបាលភូមិភាគបូព៌ាចងដៃចងមុខម្តងម្នាក់ៗប្រកបញ្ចូលទៅក្នុងបាវក្រចៅ រួចធាក់ទម្លាក់ចូលទៅក្នុងរថយន្ត ហ្សេអឹមសេផលិតនៅប្រទេសចិន ដែលចតនៅជាប់នឹងបន្ទប់ ។ បន្ទាប់មករថយន្តនោះចេញដំណើរទៅទិសខាងលិចតាមបណ្តោយផ្លូវជាតិលេខ១ ។ ខ្ញុំពុំដឹងថារថយន្តនោះដឹកមនុស្សទាំងនោះយកទៅទីណាទេ ។ ខ្ញុំនិងកុមារមួយចំនួនដែលកំពុងឃ្វាលគោនៅទីនោះមើលឃើញទិដ្ឋភាពបែបនេះមានការភ័យខ្លាចជាខ្លាំង ។ ក្រោយពីការចាប់កម្មាភិបាលនិងបក្ខជននៅភូមិភាគបូព៌ាអស់ហើយ កម្មាភិបាលភូមិភាគនិរតីចោទប្រកាន់ប្រជាជននៅក្នុងខេត្តស្វាយរៀងថាមានក្បាលយួនខ្លួនខ្មែរ ហើយរឹតបន្តឹងច្បាប់ទម្លាប់កាន់តែខ្លាំងថែមទៀត ។

អង្គការបានជម្លៀសប្រជាជននៅខេត្តស្វាយរៀងឲ្យទៅរស់នៅបណ្តោះអាសន្ននៅក្នុងស្រុកកំពង់ត្របែក ខេត្តព្រៃវែង បន្ទាប់មកស្រាវជ្រាវរកក្រុមគ្រួសារណាដែលពាក់ព័ន្ធនិន្នាការរបបចាស់ ដូចជាក្រុមគ្រួសារដែលមានសមាជិកជាអតីតទាហាន ប៉ូលិស គ្រូបង្រៀន រួចហើយចាប់បញ្ជូនគ្រួសារទាំងនោះតាមកប៉ាល់ទៅពន្លិចទឹកសម្លាប់ចោលនៅជិតជើងភ្នំឈើកាច់ខេត្តព្រៃវែងនៅក្នុងរដូវទឹកឡើង ឆ្នាំ១៩៧៨ ។ ក្រុមគ្រួសារខ្ញុំមាន

ភ័ព្វសំណាងដែលពុំមានឈ្មោះនៅក្នុងបញ្ជីមច្ចុរាជ ។ យប់មួយ ឈ្លបខ្មែរក្រហមបីនាក់កាន់ចង្កៀងប្រេងកាតបុង១ ដើរតាមភ្លឺស្រែសំដៅមកផ្ទះរបស់ខ្ញុំ ។ ម្ដាយខ្ញុំមើលតាមបង្អួច គាត់តក់ស្លុតនិងភិតភ័យយ៉ាងខ្លាំង គិតថាយើងគ្មានជីវិតរស់នៅតទៅទៀតឡើយ ។ ពេលចូលមកដល់មុខផ្ទះ បុរសម្នាក់អាយុប្រហែល២៥ឆ្នាំកាន់បញ្ជីផ្ទៀងផ្ទាត់រកមើលឈ្មោះក្រុមគ្រួសារខ្ញុំ ដើម្បីបញ្ជូនឡើងកប៉ាល់ទៅភ្នំឈើកាច់នៅថ្ងៃស្អែក ប៉ុន្តែសំណាងល្អគ្មានឈ្មោះក្រុមគ្រួសារខ្ញុំទេ ។ យើងទាំងអស់គ្នាបានរួចផុតពីគ្រោះថ្នាក់មួយគ្រាប្រៀបដូចជាបានចាប់កំណើតម្ដងទៀត ។ ទោះបីក្រុមពេជ្ឈឃាតបានចេញដំណើរផុតផ្ទះយើងហើយក៏ដោយ ក៏យើងនៅតែភ័យតក់ស្លុតប្រៀបដូចជាមនុស្សបាត់វិញ្ញាណ ។

ព្រលឹមស្រាង១ឡើង ប្រជាជនដែលមានឈ្មោះក្នុងបញ្ជីបានចេញដំណើរទៅ ចំណែកប្រជាជនដែលគ្មានឈ្មោះនៅក្នុងបញ្ជីចេញទៅធ្វើការងាររៀង១ខ្លួនដោយស្ងៀមស្ងាត់ ។ បីថ្ងៃក្រោយមក យើងបានទទួលដំណឹងពីកុមារឃ្វាលគោក្របីថា មានសាកសពជាច្រើនសាត់អណ្ដែតមកទើរនៅលើមែកឈើ ដែលលិចទឹកនៅជិតជើងភ្នំឈើកាច់ ។ កុមារទាំងនោះរើសបានសម្ភារប្រើប្រាស់មួយចំនួនដែលអណ្ដែត តាមទឹកមានដូចជា ស្បែកជើង សម្លៀកបំពាក់ កន្ទេល ខ្នើយ ដងវែក ។ល។ ដោយសារបែកការណ៍អំពីសាកសពជនរងគ្រោះអណ្ដែតទឹកពេញជើងភ្នំ និងដោយសារកងទ័ពវៀតណាមវាយរុលចូលដល់តំបន់មួយចំនួនក្នុងខេត្តស្វាយរៀង អង្គការបានរិះរកវិធីដើម្បីជម្លៀសប្រជាជនបូព៌ាដែលនៅសេសសល់ទៅខេត្តពោធិសាត់និងបាត់ដំបងទៀត ។

ការធ្វើដំណើរថ្មើរជើងរែកផងទូលផងពិតជាលំបាក និងនឿយហត់ខ្លាំងណាស់ ។ ចំពោះមនុស្សពេញវ័យពុំសូវមានបញ្ហាអ្វីទេ ដោយឡែកខ្ញុំដែលទើបតែមានអាយុជាង១០ឆ្នាំ ត្រូវដើរផងរត់ផង ឲ្យទាន់មនុស្សចាស់ ។ យើងដើរពីខេត្តស្វាយរៀងទៅដល់តំបន់មួយជិតស្ពានស្ទឹងស្លូតទើបសម្រាកបានយូរថ្ងៃដើម្បីរង់ចាំផែនការពីអង្គការថ្នាក់លើ ។ ប្រជាជនជម្លៀសនៅកកកុញ ប៉ុន្តែយើងហាក់បីដូចជាមានអារម្មណ៍ធូរស្រាលខ្លះពីព្រោះនៅទីនោះមានទឹកស្ទឹងសម្រាប់ងូតនិងប្រើប្រាស់ ហើយថែមទាំងអាចចាប់ត្រីយកមកចម្អិនបរិភោគទៀតផង ។ អង្គការបានបែងចែកប្រជាជនជម្លៀសជាក្រុម១ ដើម្បីចុះកប៉ាល់នៅអ្នកលឿង ធ្វើដំណើរតាមទន្លេមេគង្គឆ្ពោះទៅភ្នំពេញ ។ កប៉ាល់នីមួយ១ដាក់ប្រជាជនប្រហែល១០០នាក់ ។ កងទ័ពខ្មែរក្រហមបើកបញ្ជីហៅឈ្មោះប្រជាជនម្ដងម្នាក់១ឲ្យចុះកប៉ាល់ ។ ក្រុមគ្រួសារខ្ញុំមានឈ្មោះចេញដំណើរជើងទីមួយ ។

នៅលើកប៉ាល់ កងទ័ពខ្មែរក្រហមកាន់អាវុធដែលមានចំពុះទុងឈរយាមយ៉ាងប្រុងប្រយ័ត្នខ្លាច ក្រែងប្រជាជនលោតចេញពីកប៉ាល់ ។ កងទ័ពបានដាក់បញ្ជាមិនឲ្យប្រជាជនណាម្នាក់និយាយស្ដីឡើយ ។ ពេលចង់បត់ដៃបត់ជើងប្រជាជនត្រូវតែសុំការអនុញ្ញាតពីអ្នកយាម ។ ប្រជាជនងឿងឆ្ងល់ហេតុអ្វីបានជាអង្គការមិនឲ្យយើងធ្វើដំណើរតាមរថយន្តនៅលើផ្លូវជាតិលេខ១ ? នេះគឺ ការលាក់ការណ៍របស់ខ្មែរក្រហម ។ ខ្ញុំនិងម្ដាយបានរំកិលខ្លួន ខិតជិតធុងសាំងទទេមួយ ហើយអ្នកផ្សេងទៀតក៏ត្រៀមខ្លួនទទួលហេតុការណ៍ដែលកើតឡើងដែរ ។ កប៉ាល់បានមកដល់ច្បារអំពៅហើយ ។ យើងបានឃើញទិដ្ឋភាពទីក្រុងភ្នំពេញដ៏ស្ងាត់ជ្រងំ គ្មានសំឡេងរថយន្ត គ្មានសំឡេងម៉ាស៊ីនភ្លើង ។ កប៉ាល់បានចូលចត កងទ័ពខ្មែរក្រហមដែលនិយាយរដឺន១ឈរបញ្ជាឲ្យប្រជាជននៅក្នុងកប៉ាល់ឡើងគោករង់ចាំទទួលរបបអាហារពេលថ្ងៃត្រង់និងបើកសម្ភារមួយចំនួនដើម្បីប្រញាប់ឡើងរថយន្តឆ្ពោះទៅស្ថានីយរថភ្លើងនៅទីក្រុងភ្នំពេញ ។ កងទ័ពខ្មែរក្រហមបានទទួលយើងយ៉ាងកក់ក្ដៅដែរ ប៉ុន្តែខ្ញុំពុំហ៊ានសម្លឹងមើលមុខឬទៅជិតពួកគេទេ ពីព្រោះ កងទ័ពទាំងនោះមានកាំភ្លើងគ្រប់ដៃ ។

យុវនារីខ្មែរក្រហមម្នាក់អាយុប្រហែល២០ឆ្នាំបានកាន់បញ្ជីហៅឈ្មោះប្រជាជនម្ដងម្នាក់១ ទៅបើកអាហារនិងសម្ភារ ។ ក្នុងមួយគ្រួសារទទួលបានបាយមួយកញ្ចប់ស្លឹកឈូកធំឬតូចទៅតាមចំនួនសមាជិកគ្រួសារ ត្រីកំប៉ុងចំហុយម្នាក់មួយ ភួយមួយ អាវក្រណាត់ចិនមួយ ក្រមាមួយ និងប្រេងកូឡាមួយប្រអប់ ។ ម៉ោង២រសៀល យើងបន្តធ្វើដំណើរតាមរថយន្តចិនបីគ្រឿងទៅស្ថានីយរថភ្លើងហើយឡើងជិះរថភ្លើង ឆ្ពោះទៅខេត្តពោធិ៍សាត់ ។ ពេលឡើងលើរថភ្លើង ខ្ញុំមានអារម្មណ៍ថាយើងបានឃ្លាតចាកចេញពីស្រុកកំណើតដែលធ្លាប់រស់នៅឃ្លាតចេញពីទីក្រុងភ្នំពេញ ដ៏ស្ងាត់ជ្រងំ ឃ្លាតពីក្រុមគ្រួសារយាយតាពូមីងដែលធ្លាប់រស់នៅ

ជួបជុំគ្នា ។ ម នោសញ្ចេតនាស្រឡាញ់រាប់អានគ្នានៅក្នុងក្រុមគ្រួសារបានឃ្លាតផុតបន្តិចម្ដងៗគ្មានសង្ឃឹមថានឹងបានវិលត្រឡប់មកវិញឡើយ ។ អ្នកកៀសខ្លួនទាំងអស់អង្គុយក្នុងទូររទេះភ្លើងក្នុងសភាពស្ងប់ស្ងាត់ ម្នាក់ៗមានទឹកមុខស្រងូតស្រងាត់អស់សង្ឃឹម ។ ខ្ញុំស្រេកទឹកនិងឃ្លានបាយណាស់ ខ្ញុំស្រាយបង្វេច រកកញ្ចប់និងត្រីចំហុយដែលនៅសល់ពីថ្ងៃមានក្លិនឈ្ងុយឆ្ងាញ់គួរឲ្យចង់ហូប មកបរិភោគជាមួយម្ដាយខ្ញុំ ។ ក្រោយពីបានចម្អែតក្រពះរួចហើយ ខ្ញុំអើតមើលតាមបង្អួចរថភ្លើងទើបដឹងថាជិតយប់ទៅហើយ ។ នៅសងខាងផ្លូវរថភ្លើងសុទ្ធសឹងព្រៃព្រឹក្សាដុះក្រាស់ឃ្មឹក ។

បន្ទាប់ពីចំណាយពេលអស់ជាច្រើនម៉ោង រថភ្លើងបាននាំយើងទៅដល់គោលដៅក្នុងខេត្តពោធិសាត់ ។ អង្គការបានបែងចែកប្រជាជនជម្លៀសជាក្រុមនិងបញ្ជូនទៅតាមសហករណ៍ ។ ក្រុមគ្រួសារខ្ញុំមានសមាជិក៩នាក់ត្រូវអង្គការបំបែកឲ្យទៅរស់នៅសហករណ៍ផ្សេងគ្នា ។ ពូមីងខ្ញុំ៦នាក់ធ្វើការនៅសហករណ៍ដំណាក់ត្រប់ ។ ចំណែកខ្ញុំនិងម្ដាយត្រូវអង្គការបញ្ជូនទៅធ្វើការនៅសហករណ៍ដំណាក់រុណ នៅក្នុងកងស្ត្រីមេម៉ាយនិងកុមារតូចៗ ។ ទៅនៅកងស្ត្រីមេម៉ាយបានបីថ្ងៃ អង្គការបញ្ជូនខ្ញុំនិងកុមារ១៦នាក់ទៀតទៅកងត្រជាក់ចិត្តដែលស្ថិតនៅក្នុងស្រុកស្វាយដូនកែវ ។ ខ្មែរក្រហមបានបង្ខំឲ្យយើងធ្វើការទាំងយប់ទាំងថ្ងៃ ហូបមិនឆ្អែត និងយកទៅសម្លាប់ ។ ជីតាខ្ញុំ ពូខ្ញុំនិងប្រពន្ធរបស់គាត់ ព្រមទាំងមីងខ្ញុំពីរនាក់ដែលនៅលីវ ត្រូវខ្មែរក្រហមសម្លាប់នៅសហករណ៍ដំណាក់ត្រប់ ។ នៅភ្នំត្រជាក់ចិត្តសំបូរដោយរណ្ដៅសាកសពរួម ។ ខ្ញុំទៅធ្វើពលកម្មនៅក្នុងព្រៃថ្ងៃណាក៏ធុំក្លិនស្អុយសាកសពដែរ ។ ដោយធ្វើការលំបាកពេកនិងដោយនឹកម៉ែផង ខ្ញុំនិងមិត្តភក្ដិបីនាក់បាននាំគ្នារត់ចេញពីសហករណ៍ត្រជាក់ចិត្តនៅពាក់កណ្ដាលអធ្រាត្រដើម្បីទៅជួបម្ដាយនៅសហករណ៍ចុងស្រល់ ។ ព្រលឹមឡើងខ្ញុំឃើញឈ្លបម្នាក់កាន់កាំបិតខ្មែរមួយជិះសេះសំដៅមករកយើងទាំងបួននាក់ដែលកំពុងតែស្រង់កំប្លោកនៅក្នុងស្រះ មួយតាមបញ្ជាប្រធានសហករណ៍ឈ្មោះតាឡឹម ។ មិត្តខ្ញុំម្នាក់ បានអង្វរ តាឡឹម ឲ្យជួយ ព្រោះបើត្រូវឈ្លបនោះចាប់ត្រឡប់ទៅសហករណ៍វិញ យើងទាំងបួននាក់ប្រាកដជាត្រូវសម្លាប់នៅពាក់ កណ្ដាលផ្លូវមិនខាន ។ ដោយយើងអង្វរខ្លាំងពេក តាឡឹម បានទៅ ជជែកជាមួយឈ្លបនោះមួយសន្ទុះទើបឃើញឈ្លបនោះជិះសេះត្រឡប់ទៅវិញ ។ យើងទាំងបួននាក់បានធូរចិត្ត ។ យើងទាំងអស់គ្នាខំប្រឹងធ្វើការដើម្បីកុំឲ្យប្រធានសហករណ៍បញ្ជូនខ្លួនទៅកន្លែងដើមវិញ ។ ខ្ញុំរស់នៅមិនបានប៉ុន្មានថ្ងៃផងម្ដាយខ្ញុំត្រូវអង្គការបញ្ជូនទៅសហករណ៍ត្រជាក់ចិត្ត ។ ខ្ញុំតក់ស្លុតណាស់ពេលឮដំណឹងថា អង្គការបញ្ជូនគាត់ទៅកន្លែងនោះ ។ ម៉ោង៤ទៀបភ្លឺខ្ញុំលួចរត់ ទៅជួបម្ដាយនៅសហករណ៍ត្រជាក់ចិត្ត យើងទាំងពីរនាក់ម្ដាយ និងកូនយំឱបគ្នា ។ ម្ដាយខ្ញុំមានរូបរាងកាយស្គាំងស្គម សក់ជ្រុះ ជិតអស់អង្គុយស្ទើរតែមិននឹងរង់ចាំតែថ្ងៃអង្គការយកទៅសម្លាប់ ។

ដើមឆ្នាំ១៩៧៩ អង្គការប្រកាសថានឹងធ្វើនំបញ្ចុកជប់លៀងឲ្យប្រជាជន ស្រាប់តែឃើញឈ្លបខ្មែរក្រហមស្ទុះស្ទាកម្មាភិបាលសំខាន់ៗដូចជា យាយណាត ប្រធានកងមេម៉ាយ យាយម៉ោញ មេសហករណ៍ចម្ការខ្នុរ ដែលត្រូវជាប្អូនរបស់យាយណាត កៀរប្រជាជនចុះទៅតាមជ្រោះមួយដោយចំណាយអស់រយៈពេលពេញមួយថ្ងៃ ។ ស្អែកឡើងជាថ្ងៃចូលឆ្នាំប្រពៃណីខ្មែរ អង្គការខ្មែរក្រហមបានធ្វើពិធីជប់លៀងតូចមួយដោយចែកបបរសណ្ដែកមួយវែកម្នាក់និងសាច់ជ្រូកមួយដុំប៉ុនមេដើង ។ ខ្ញុំត្រេកអរណាស់ ព្រោះខានភ្លក្សរសជាតិបែបនេះយូរហើយ ។ នៅពេលនោះ កម្មាភិបាលខ្មែរក្រហមសំខាន់ៗបានរត់គេចខ្លួនបាត់អស់ ។ ក្រោយពេលហូបរួចបានមួយម៉ោង កងទ័ពខ្មែរក្រហមម្នាក់ប្រកាសថា សូមបងប្អូនពុកម៉ែទាំងអស់បំបែកគ្នាទៅរកស្បៀងអាហារហូបចុកដោយខ្លួនឯងចុះ ពុំចាំបាច់មានកងទៀតទេ ។ ប្រជាជនសប្បាយរីករាយណាស់ ពីព្រោះយើងហាក់បីដូចជាមានសិទ្ធិសេរីភាពឡើងវិញទោះបីយើងគ្មានអ្វីហូបគ្រប់គ្រាន់ក៏ដោយ ។ ម្ដាយខ្ញុំកាន់ឈើច្រត់ដើររួមដំណើរជាមួយប្រជាជនបូព៌ាដែលនៅសល់ពីស្លាប់ធ្វើដំណើរមកទិសខាងកើតវិញ ។ ក្នុងទិដ្ឋភាពនេះ យើងបានធូរស្បើយច្រើន ពីព្រោះយើងបានឈប់សម្រាកពីការងារពលកម្មតាមបញ្ជាអង្គការ និងបានដាំបាយហូបរៀងៗខ្លួន ។ ព្រឹកថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៩ យើងឮស្នូរកាំភ្លើងតូច-ធំ មកពីទិសខាងកើតមិនដល់កន្លះម៉ោង

ដងក្បូនកងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និង កងទ័ពវៀតណាមបានចូលមកដល់តំបន់ដែលយើងរស់នៅ ។ ប្រជាជនក្មេងចាស់ ប្រុសស្រី នាំគ្នាត្រេកអរ ក្រមាមួក និង ទះដៃអបអរសាទរព្រឹត្តិការណ៍នេះ ។ ខ្ញុំនិងម្តាយបានធ្វើដំណើរជាមួយប្រជាជនយ៉ាងច្រើនកុះករពីក្នុងព្រៃជ្រៅនៃខេត្តពោធិសាត់ សំដៅមកស្រុកកំណើតវិញ ។ ម៉ែបានសម្រាកព្យាបាលជំងឺនៅក្នុងមន្ទីរពេទ្យខេត្តពោធិសាត់ មួយរយៈសិន ។ នៅក្នុងមន្ទីរពេទ្យមានអ្នកជំងឺជាច្រើន ដែលភាគច្រើនជាប្រភេទជំងឺបាក់កម្លាំងពីរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងគ្មានសល់អ្វីទៀតទេ សូម្បីតែផ្ទះសម្បែងក៏ត្រូវរុះរើខ្ទេចខ្ទីអស់ ហើយបងប្អូនរបស់ម៉ែ៦ នាក់ក៏ត្រូវខ្មែរក្រហមសម្លាប់អស់ដែរ ។

ខ្ញុំបាទសុំស្នើឲ្យអង្គការសិទ្ធិមនុស្សប្រចាំនៅកម្ពុជា តុលាការជាតិនិងអន្តរជាតិដែលមានភារកិច្ចក្នុងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហម ជួយរកយុត្តិធម៌និងកាត់ទោសមេដឹកនាំទាំងនោះតាមច្បាប់ឲ្យសមនឹងទង្វើរបស់មេដឹកនាំទាំងនេះដែលប្រព្រឹត្តមកលើប្រជាពលរដ្ឋខ្មែរនៅក្នុងអំឡុងឆ្នាំ ១៩៧៥ដល់ឆ្នាំ១៩៧៩ផង ។

**សោម ចណ្ណៈ**




*នៅវាលពិឃាតបឹងជើងឯក*

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែររៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ ។ កម្មវិធីនេះ សូមអំពាវនាវដល់សិស្ស និស្សិត និងប្រជាជនកម្ពុជាដែលរស់រានមានជីវិតពីរបបខ្មែរក្រហមដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេសឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮនិងទស្សនៈផ្ទាល់ខ្លួនរបស់លោកអ្នកចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ ÷

◆រួមចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់ឲ្យកូនចៅជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ជាវិធីមួយ ដើម្បីរំងាប់អារម្មណ៍ ដោយយកហេតុការណ៍សេចក្តីទុក្ខ ការខឹងគុំកួនមកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីមែល : dccam@online.com.kh ។ សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខ : ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។

សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ទួន ឆាន



សាន យិន

នាងខ្ញុំឈ្មោះ សាន យិន អាយុ៧០ឆ្នាំ រស់នៅភូមិរកា ឃុំរកាជន្ទីង ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល សូមសួររកកូនប្រុសច្បងឈ្មោះ ទួន ឆាន ហៅ ឃឿន ដែលបានចូលបដិវត្តន៍កាលពីឆ្នាំ១៩៧៣ ហើយបាត់ខ្លួនរហូតបច្ចុប្បន្ន ។ មុនពេលចូលបដិវត្តន៍ ឆាន បួសជាសង្ឃនៅវត្តស្វាយពោធិនៅក្នុងស្រុកកំណើត ។ បន្ទាប់មក ឆាន ធ្វើដំណើរទៅរៀនបន្តនៅវត្តគ្នោតឫស្សីស្រុកនៅខេត្តកំពង់ចាម ។ បីឆ្នាំក្រោយ ពេលដែល ឆាន អាយុ២៥ឆ្នាំ គឺនៅឆ្នាំ១៩៧៣ ឆាន បានសឹកពីបួសហើយចូលបម្រើបដិវត្តន៍ដោយមិនប្រាប់ ម្តាយឪពុកឲ្យដឹងឡើយ ។ នៅឆ្នាំ១៩៧៩ ស្រី នៅក្នុងភូមិជាមួយគ្នា បានប្រាប់ខ្ញុំថា គាត់បានជួប ឆាន នៅខេត្តកំពង់ឆ្នាំង ហើយបានបបួល ឆាន ត្រឡប់មកផ្ទះវិញ ប៉ុន្តែ ឆាន ប្រកែក ។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ គ្រួសារខ្ញុំបានទទួលសំបុត្រមួយពី ឆាន សួររកក្រុមគ្រួសារនៅភូមិកំណើត ប៉ុន្តែពេលនោះយើងទាំងអស់គ្នាមិនបានយកចិត្តទុកដាក់នឹងសំបុត្រនោះប៉ុន្មានទេ ព្រោះរវល់តែខ្វាយខ្វល់នឹងឪពុករបស់ ឆាន ដែលមានជំងឺជាទម្ងន់ ។ ក្រោយពេលធ្វើបុណ្យសពឪពុករបស់ ឆាន រួចមកសំបុត្រនោះក៏បាត់រហូត ហើយខ្ញុំក៏មិនបានទទួលដំណឹងអ្វីពី ឆាន ទៀតដែរ ។

បើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានដឹងដំណឹងអំពី ទួន ឆាន សូមមេត្តាទាក់ទងនាងខ្ញុំនៅភូមិឃុំខាងលើ ឬទាក់ទងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ទូរសារ ០២៣ ២១០ ៣៥៨ ឬតាមរយៈប្រអប់សំបុត្រ ១១១០ ភ្នំពេញ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ លឹម ឡុង

នាងខ្ញុំឈ្មោះ លឹម សុក អាយុ៥៣ឆ្នាំ រស់នៅភូមិកណ្តាច់ ឃុំចុងអំពិល ស្រុកកញ្ជៀច ខេត្តព្រៃវែង សូមសួររកប្អូនប្រុសឈ្មោះ លឹម ឡុង (កើតឆ្នាំមមី) បានចូលបម្រើបដិវត្តន៍តាំងពីឆ្នាំ១៩៧២ ពេលដែលគាត់មានអាយុ១៨ឬ១៩ឆ្នាំ ។ មុនពេលចូលបដិវត្តន៍ ឡុង ជាកងសេនាជនឃុំ ។ រយៈពេល១ខែក្រោយពេលខ្មែរក្រហមបានទទួលជ័យជម្នះទូទាំងប្រទេស ឡុង បានមកលេងផ្ទះម្តងក្នុងសម្លៀកបំពាក់កងទ័ព ។ ក្រោយពី ឡុង ត្រឡប់ទៅវិញក៏បាត់ដំណឹងរហូតមកដល់បច្ចុប្បន្ននេះ ។

បើបងប្អូនណាបានស្គាល់ឈ្មោះ លឹម ឡុង ឬសាមីខ្លួនបានឃើញសេចក្តីប្រកាសនេះ សូមទាក់ទងមកខ្ញុំតាមរយៈឈ្មោះ នុយ ដានី ទូរស័ព្ទលេខ ០១២ ១៨០ ២៦ ៥២ ឬផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬទូរសារលេខ ០២៣ ២១០ ៣៥៨ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកកូនប្រុសឈ្មោះ ម៉ាន ម៉ុន

យស ផេង អាយុ៧២ឆ្នាំ ត្រូវជាម្តាយ ព្រមទាំងកូនស្រី ម៉ាន ម៉ន អាយុ៤៥ឆ្នាំ សូមប្រកាសសួរកូនប្រុសឈ្មោះ ម៉ាន ម៉ុន ដែលបានចេញពីផ្ទះតាំងពីឆ្នាំ១៩៧៦ បាត់ដំណឹងរហូតដល់សព្វថ្ងៃ ។ ដើមឆ្នាំ១៩៧៦ ម៉ាន ម៉ុន ត្រូវខ្មែរក្រហមបង្ខំឲ្យសឹក បន្ទាប់មកត្រូវបានបញ្ជូនទៅធ្វើការក្នុងកងដំឡូងនៅម្តុំភ្នំពាមជាំង ស្រុកព្រះស្តេច ។ តាំងពីពេលនោះមក ម៉ាន់ ម៉ុន មិនបានត្រឡប់មកផ្ទះវិញទេ ។

ប្រសិនបើកូនបានឃើញសេចក្តីប្រកាសនេះ ឬញាតិមិត្តណាបានស្គាល់ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្តល់ព័ត៌មានមកនាងខ្ញុំតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាប្រអប់សំបុត្រលេខ១១១០ភ្នំពេញ ឬទូរស័ព្ទលេខ ៨៥៥ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ជុំ ម៉ាញ (អតីតអ្នកទោសគុកទួលស្លែង) និងដូនជី សូត្រធម៌បង្សុកូលជូនដល់វិញ្ញាណក្ខន្ធជនរងគ្រោះនៅវាលពិឃាតបឹងជើងឯក

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 74, February 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Royal Government of Cambodia, Prakas No.0291 P.M/99, 2 August 1999.